ក្រសួងអប់រំ យុវជន និងកីឡា

សៀវភៅពន្យឿនការសិក្សា

ភាសាខ្មែរ

ថ្នាក់ឆ្នាំទី ២



សម្រាប់គ្រូបង្រៀន

ព.ស. ២៥៥៨ គ.ស. ២០១៤



ក្រសួងអប់រំ យុវជន និងកីឡា

សៀវភៅពន្យឿនការសិក្សា

គណិតវិទ្យា

ថ្នាក់ឆ្នាំទី ២

ឯកសារសម្រាប់គ្រូ

បោះពុម្ពលើកទី ២
ឆ្នាំ ២០១៥

គណៈកម្មការត្រួតត្រង

ឯកឧត្តម ណាត ប៊ុនរឿន — លោក អ៊ុក សុវណ្ណ
ឯកឧត្តម អ៊ឹម កុច — លោក ចាន់ សុភា
ឯកឧត្តម សំ សេរីរតន៍ — លោក ជា វណ្ណេត

គណៈកម្មការនិពន្ធ

លោកស្រី ទូច សុភាព — លោកស្រី ឡុង ជាណែត
លោកស្រី សាន ណាវ៉ា — លោកស្រី ស៊ូ ណារិន
លោកស្រី ជាន់ សុគន្ធ — លោក ប៊ុន ស៊ីនួន
លោកស្រី អ៊ាវ ណារី

អ្នករៀបរៀងនិងរចនាចំណារ

លោកស្រី ខ្ងង់ គឹមទូច — លោក អាន រ៉ូប្រាវ

គណៈកម្មការត្រួតពិនិត្យ

លោក ជា វណ្ណេត — លោកស្រី ខ្ងង់ គឹមទូច
លោក អាន រ៉ូប្រាវ — លោកស្រី មិន វិចិត្រា
លោកស្រី ហ៊ុន សុជាតិ

បញ្ជីអត្ថបទ

អារម្ភកថា ១
ផ្នែកទី១៖ បំណែងចែកកម្មវិធីសិក្សា ២
ផ្នែកទី២៖ អត្ថបទស្តាប់ ៨
ផ្នែកទី៣៖ លំនាំនៃការបង្រៀន ១៩
ផ្នែកទី៤៖ សលាកប័ត្រជំពូកនិងមេរៀន ២៩
ជំពូកទី១ : សាលារៀនភូមិខ្ញុំ ៣០
ជំពូកទី២ : សិស្សល្អ ៣៦
ជំពូកទី៣ : ការកម្សាន្តរបស់យើង ៤០
ជំពូកទី៤ : កន្លែងកម្សាន្តនៅមាតុភូមិខ្ញុំ ៤៤
ជំពូកទី៥ : គ្រួសារខ្ញុំ ៥០
ជំពូកទី៦ : ការរស់នៅរបស់អ្នកភូមិខ្ញុំ ៥៣
ជំពូកទី៧ : ភូមិខ្ញុំនៅរដូវប្រាំងនិងរដូវវស្សា ៥៨
ជំពូកទី៨ : ពិធីបុណ្យផ្សេងៗនៅភូមិខ្ញុំ ៦២
ជំពូកទី៩ : ដំណាំនៅភូមិខ្ញុំ ៦៦
ជំពូកទី១០ : សត្វនៅភូមិខ្ញុំ ៦៨
ជំពូកទី១១ : កីឡានិងល្បែងកម្សាន្ត ៧២
ជំពូកទី១២ : សហគមន៍ជឿនលឿន ៧៧
ជំពូកទី១៣ : ការគួរសម ៨១
ជំពូកទី១៤ : រុក្ខជាតិប្រទេសយើង ៨៧
ជំពូកទី១៥ : មិត្តជិតស្និទ្ធ ៩២
ជំពូកទី១៦ : មធ្យោបាយធ្វើទំនាក់ទំនង ៩៧
ជំពូកទី១៧ : ម្ហូបអាហារខ្មែរ ១០០
ជំពូកទី១៨ : សណ្ឋានដីប្រទេសយើង ១០៥
ជំពូកទី១៩ : ប្រភពទឹកនៅកម្ពុជា ១០៩
ជំពូកទី២០ : សត្វនៅប្រទេសយើង ១១៣

អារម្ភកថា

ឯកសារជំនួយគ្រូ មុខវិជ្ជាភាសាខ្មែរថ្នាក់ឆ្នាំទី២ នេះត្រូវបានរៀបចំឡើងក្រោមកិច្ចសហប្រតិបត្តិការរវាងក្រសួងអប់រំ យុវជន និងកីឡា ជាមួយនឹងអង្គការដើម្បីភាពញញឹមនៃកុមារ នៅក្នុងគម្រោងចងក្រងសៀវភៅពន្លឿនការសិក្សាសម្រាប់សាលាបឋមសិក្សា។ ឯកសារនេះ ត្រូវបានចងក្រងឡើងដោយគណៈកម្មការនិពន្ធក្នុងគម្រោងនេះ និងដោយមានការចូលរួមពីលោកគ្រូអ្នកគ្រូដែលបង្រៀនថ្នាក់ពន្លឿនការសិក្សា នៅអង្គការដើម្បីភាពញញឹមនៃកុមារ។

ឯកសារនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងសម្រួលដល់ការបង្រៀនមុខវិជ្ជាភាសាខ្មែរថ្នាក់ឆ្នាំទី២ របស់លោកគ្រូអ្នកគ្រូ។ ខ្លឹមសារសំខាន់នៃឯកសារនេះមានការបង្ហាញពីកម្មវិធីពន្លឿនការសិក្សា នៅសាលាបឋមសិក្សាលំនាំនៃការបង្រៀនតាមសមត្ថភាពនីមួយៗនិងសលាកប័ត្រជំពូកនិងមេរៀន ពិសេសផ្តោតទៅលើចម្លើយរបស់សំណួរ និងកំណែលំហាត់ដែលផ្តល់នូវភាពងាយស្រួលសម្រាប់លោកគ្រូអ្នកគ្រូ ក្នុងការប្រើប្រាស់សៀវភៅពន្លឿនការសិក្សា។

ក្នុងការបង្រៀន គណៈកម្មការយើងមិនទាមទារឱ្យលោកគ្រូអ្នកគ្រូអនុវត្តឯកសារនេះទាំងស្រុងនោះទេ។ ប៉ុន្តែកត្តាសំខាន់គឺជំរុញឱ្យការសិក្សារបស់សិស្សទទួលបានលទ្ធផលល្អប្រពៃ ដោយពឹងផ្អែកលើចំណេះដឹង បទពិសោធក្នុងការរៀបចំវិធីបង្រៀន បំណិនប្រសប់ក្នុងការប្រើប្រាស់វាក្យស័ព្ទ និងសម្ភារឧបទេសក្នុងការបង្រៀនរបស់លោកគ្រូអ្នកគ្រូ។

ក្រោយពីបញ្ចប់មេរៀននីមួយៗ លោកគ្រូអ្នកគ្រូធ្វើរង្វាយតម្លៃលើកម្រិតយល់ដឹងរបស់សិស្ស ដោយធ្វើសំណួរសរសេរ ឬសំណួរផ្ទាល់មាត់ ឬលំហាត់អនុវត្ត ព្រោះវាអាចបង្ហាញឱ្យគ្រូដឹងពីលទ្ធផលបង្រៀន ដើម្បីឱ្យលោកគ្រូអ្នកគ្រូជ្រើសរើសនិងកែសម្រួលវិធីសាស្ត្របង្រៀនឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។

គណៈកម្មការនិពន្ធសង្ឃឹមថា ឯកសារជំនួយគ្រូភាសាខ្មែរថ្នាក់ឆ្នាំទី២ នេះនឹងបានជាប្រយោជន៍ច្រើនដល់ការបង្រៀនរបស់គ្រូ ដើម្បីរួមចំណែក ក្នុងការលើកកម្ពស់គុណភាពរៀននិងបង្រៀនប្រកបដោយប្រសិទ្ធភាព។

គណៈកម្មការនិពន្ធ

ផ្នែកទី១
បំណែងចែកកម្មវិធីសិក្សា

កម្មវិធីសិក្សាថ្នាក់ពន្លឿនការសិក្សា មុខវិជ្ជា ភាសាខ្មែរ ថ្នាក់ឆ្នាំទី២នេះ គឺជាការសំយោគបញ្ចូលគ្នារវាងកម្មវិធីសិក្សា មុខវិជ្ជា ភាសាខ្មែរ ថ្នាក់ទី៣និងថ្នាក់ទី៤ នៃកម្មវិធីសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា។ មុខវិជ្ជា ភាសាខ្មែរ ថ្នាក់ឆ្នាំទី២នេះ មានចំនួន១៣ម៉ោងសិក្សាក្នុង១សប្តាហ៍ ដែល១ម៉ោងសិក្សាមានរយៈពេល៤០នាទី។

ជំពូក	មេរៀន	ប្រភេទមេរៀន	ចំណងជើងមេរៀន	រយៈពេល
ទី១៖ សាលារៀនភូមិខ្ញុំ	១	បំណិន	ការប្រើបទានុក្រម	២ម៉
	២	អំណាន	ចេះមកពីរៀន	២ម៉
	៣	សំណេរ	សកម្មភាពនៅសាលារៀន	៣ម៉
	៤	វេយ្យាករណ៍	សញ្ញាខណ្ឌ (។)	២ម៉
	៥	អំណាន	មេសូត្រ៖ គុណគ្រូ (បទកាកគតិ)	២ម៉
	៦	ស្តាប់	រឿង អាគីមើលអក្សរ	២ម៉
	៧	សំណេរ	គុណគ្រូ និងឪពុក ម្តាយ	៣ម៉
	៨	អំណាន	រឿង សិស្សដឹងគុណ	២ម៉
	៩	សំណេរ	ពណ៌នាពីគ្រូបង្រៀន	៣ម៉
	១០	អំណាន	សាលារៀនខ្ញុំ	២ម៉
	១១	សំណេរ	ពណ៌នាពីសាលារៀន	៣ម៉
ទី២៖ សិស្សល្អ	១	អំណាន	សិស្សឧស្សាហ៍	២ម៉
	២	វេយ្យាករណ៍	នាម	២ម៉
	៣	អំណាន	មេសូត្រ៖ ច្បាប់ល្បីកថ្មី (បទកាកគតិ)	២ម៉
	៤	សំណេរ	ពណ៌នាពីសិស្សល្អ	៣ម៉
	៥	ស្តាប់	រឿង ការីរៀហារសន្ធម៉ុក	២ម៉
	៦	អំណាន	ការកម្សាន្តនៅពេលទំនេរ	២ម៉
	៧	កិច្ចការស្រាវជ្រាវ	ប្រវត្តិរបស់ការីរៀហារសន្ធម៉ុក	៣ម៉
ទី៣៖ ការកម្សាន្តរបស់យើង	១	អំណាន	ទិដ្ឋភាពថ្ងៃរៀបអស្តង្គតនៅប្រាសាទអង្គរវត្ត	២ម៉
	២	សំណេរ	ពណ៌នាពីទិដ្ឋភាពរមណីយដ្ឋាន	៣ម៉
	៣	ស្តាប់	រឿង ណាស៊ីកុមារផ្ចាត់គ្រាប់ក្រួស	២ម៉
	៤	និយាយ	ការរៀបរាប់ពីការកម្សាន្តដែលខ្លួនចូលចិត្ត	២ម៉
	៥	វេយ្យាករណ៍	គុណនាម	២ម៉
	៦	អំណាន	ត្រូវចេះជ្រើសរើសការកម្សាន្ត	២ម៉
	៧	សំណេរ	រៀបរាប់ ការកម្សាន្តដែលមានសុវត្ថិភាព	៣ម៉
ទី៤៖	១	អំណាន	មេសូត្រ៖ បារាយណ៍ទឹកថ្លា (បទ៣ក្យប្រាំពីរ)	២ម៉

កន្លែងកម្សាន្តនៅមាតុភូមិខ្ញុំ	២	សំណេរ	ពណ៌នាពីដំបន់ទេសចរណ៍នៅខេត្តសៀមរាប	៣ម៉ោ
	៣	និយាយ	ការផ្តល់ការណែនាំឱ្យស្គាល់ទីកន្លែង	២ម៉ោ
	៤	វេយ្យាករណ៍	កិរិយា	២ម៉ោ
	៥	អំណាន	ប្រាសាទអង្គរវត្ត	២ម៉ោ
	៦	សំណេរ	ពណ៌នាពីទិដ្ឋភាពភ្នំបាខែង	៣ម៉ោ
	៧	ស្តាប់	ទេសភាពជើងភ្នំ	២ម៉ោ
	៨	អំណាន	ផ្លូវទៅកាន់អង្គរ	២ម៉ោ
	៩	សំណេរ	ពណ៌នាពីទិដ្ឋភាពផ្លូវទៅកាន់អង្គរ	៣ម៉ោ
	១០	អំណាន	រឿង ពូរស់ទៅលេងសៀមរាប	២ម៉ោ
	១១	សំណេរ	ពណ៌នាពីទិដ្ឋភាពប្រាសាទព្រះវិហារ	៣ម៉ោ
ទី៥៖ គ្រួសារខ្ញុំ	១	ស្តាប់	ការផ្សព្វផ្សាយការប្រមូលកុមារចូលរៀន	២ម៉ោ
	២	អំណាន	រឿង បងប្អូនគំរូពីរនាក់	២ម៉ោ
	៣	សំណេរ	រៀបរាប់ពីសកម្មភាពកូនល្អ	៣ម៉ោ
	៤	អំណាន	មេសូត្រ៖ ច្បាប់បណ្តាំបិតា (បទកាកគតិ)	២ម៉ោ
ទី៦៖ ការរស់នៅរបស់អ្នកភូមិខ្ញុំ	១	អំណាន	ទីធ្លាចិញ្ចឹមសត្វ	២ម៉ោ
	២	និយាយ	ការរៀបរាប់អំពីមុខរបរអ្នកភូមិ	២ម៉ោ
	៣	ស្តាប់	ព័ត៌មានអំពីខ្យល់ព្យុះ	២ម៉ោ
	៤	វេយ្យាករណ៍	សញ្ញាសួរ (?)	២ម៉ោ
	៥	អំណាន	មេសូត្រ៖ មុខរបរអ្នកភូមិ (បទកាកគតិ)	២ម៉ោ
	៦	អំណាន	រឿង ការងារជាកំណប់ទ្រព្យ	២ម៉ោ
	៧	សំណេរ	រៀបរាប់ពីមុខរបរអ្នកចិញ្ចឹមសត្វ	៣ម៉ោ
ទី៧៖ ភូមិខ្ញុំនៅរដូវប្រាំងនិងរដូវវស្សា	១	អំណាន	ការងារអ្នកភូមិខ្ញុំ	២ម៉ោ
	២	សំណេរ	រៀបរាប់ពីព្រឹត្តិការណ៍ដែលធ្លាប់ជួបប្រទះ	៣ម៉ោ
	៣	ស្តាប់	រឿង កំណប់ឪពុក	២ម៉ោ
	៤	វេយ្យាករណ៍	សញ្ញា [អ] ឬសញ្ញាធ្មេញកណ្តុរ [◌]	២ម៉ោ
	៥	អំណាន	មេសូត្រ៖ ត្រូវឧស្សាហ៍ដាំដំណាំ (បទព្រហ្មគីតិ)	២ម៉ោ
	៦	សំណេរ	រៀបរាប់ពីសកម្មភាពថែទាំដំណាំ	៣ម៉ោ
ទី៨៖ ពិធីបុណ្យផ្សេងៗនៅភូមិខ្ញុំ	១	អំណាន	បុណ្យផ្កានៅភូមិខ្ញុំ	២ម៉ោ
	២	និយាយ	ការបង្ហាញព័ត៌មានតាមគម្រោងគំនិត	២ម៉ោ
	៣	វេយ្យាករណ៍	សញ្ញា [អិ] ឬសញ្ញាសក់ ក " ◌ិ "	២ម៉ោ

	៤	អំណាន	បុណ្យចូលឆ្នាំខ្មែរ	២ម៉
	៥	សំណេរ	រៀបរាប់ពីពិធីបុណ្យ	៣ម៉
ទី៩៖ ដំណាំនៅភូមិខ្ញុំ	១	ស្តាប់	រឿង ផ្លែឈើចម្លែក	២ម៉
	២	អំណាន	មេសូត្រ៖ បន្លែនិងផ្លែឈើយើង (បទពាក្យប្រាំពីរ)	២ម៉
	៣	សំណេរ	រៀបរាប់ពីការដាំដំណាំ	៣ម៉
ទី១០៖ សត្វនៅភូមិខ្ញុំ	១	ស្តាប់	រឿង ឆ្កែនិងសេះ	២ម៉
	២	និយាយ	ការពន្យល់អត្ថន័យនៃរូបគំនូរ	២ម៉
	៣	វេយ្យាករណ៍	សញ្ញាបន្តក់ " ◌ំ "	២ម៉
	៤	អំណាន	មេសូត្រ៖ គោខ្ញុំ (បទកាកគតិ)	២ម៉
	៥	សំណេរ	ពណ៌នាអំពីសត្វ	៣ម៉
ទី១១៖ កីឡានិងល្បែងកម្សាន្ត	១	បំណិន	ព្រឹត្តិការណ៍នៃរឿង	២ម៉
	២	អំណាន	រឿង យ៉ារីមើលថែប្អូន	២ម៉
	៣	បំណិន	ចរិតលក្ខណៈរបស់តួអង្គ	២ម៉
	៤	បំណិន	ការប៉ាន់ស្មានហេតុការណ៍ដែលកើតឡើងបន្ទាប់	២ម៉
	៥	ស្តាប់	រឿង ទន្សាយនិងខ្យង	២ម៉
	៦	វេយ្យាករណ៍	នាមសាធារណ៍ ឬសាធារណនាម	២ម៉
	៧	អំណាន	កីឡានិងល្បែងមានសុវត្ថិភាព	២ម៉
	៨	អំណាន	រឿង ជ័យជម្នះរបស់តុលា	២ម៉
	៩	និយាយ	ការណែនាំអំពីការលេងល្បែង	២ម៉
ទី១២៖ សហគមន៍ជឿនលឿន	១	បំណិន	តួអង្គនិងកាលអាកាស	២ម៉
	២	អំណាន	រឿង គ្រូពេទ្យភូមិយើង	២ម៉
	៣	បំណិន	បរិបទបញ្ជាក់ ឬទីសេចក្តីបញ្ជាក់	២ម៉
	៤	អំណាន	សមាគមវាយនកម្ម	២ម៉
	៥	អំណាន	សហគមន៍ថ្មី	២ម៉
	៦	សំណេរ	តួនាទីសមាជិកក្នុងសហគមន៍	៣ម៉
ទី១៣៖ ការគួរសម	១	អំណាន	ការគោរពឪពុកម្តាយ	២ម៉
	២	សំណេរ	ទម្រង់នៃការសរសេរកថាខណ្ឌ	៣ម៉
	៣	ស្តាប់	រឿង សេដ្ឋីនិងអ្នកលក់ធ្យូង	២ម៉
	៤	បំណិន	ដំណើររឿងនិងព្រឹត្តិការណ៍សំខាន់ៗនៃរឿង	២ម៉
	៥	អំណាន	រឿង កុមារចេះគួរសម	២ម៉

	៦	វេយ្យាករណ៍	អព្ភន្តរសញ្ញា ឬសញ្ញាក្បៀសបិទបើក "..."ឬ «...»	២ម៉
	៧	អំណាន	មេសូត្រ៖ ច្បាប់ប្រុស (បទព្រហ្មគីតិ)	២ម៉
	៨	សំណេរ	សំណេរកថាខណ្ឌ	៣ម៉
	៩	សំណេរ	ការសរសេររឿងខ្លី	៣ម៉
ទី១៤៖ រុក្ខជាតិប្រទេសយើង	១	បំណិន	រឿងពិត ឬពិតកថា	២ម៉
	២	អំណាន	ការផ្សព្វផ្សាយពីផលអាក្រក់នៃថ្នាំជក់	២ម៉
	៣	វេយ្យាករណ៍	នាមអសាធារណ៍	២ម៉
	៤	អំណាន	ភូមិពណ៌បៃតង	២ម៉
	៥	សំណេរ	ពណ៌នាអំពីដើមត្នោត	៣ម៉
	៦	បំណិន	ប្រធានបទរបស់កថាខណ្ឌ	២ម៉
	៧	អំណាន	ដំណាំស្រូវ	២ម៉
	៨	សំណេរ	អត្ថបទព័ត៌មាន	៣ម៉
ទី១៥៖ មិត្តជិតស្និទ្ធ	១	បំណិន	តម្លៃអប់រំនៃរឿង	២ម៉
	២	អំណាន	រឿង ស្មាន់ ទីទុយ និងអណ្តើក	២ម៉
	៣	សំណេរ	កថាខណ្ឌពណ៌នាអំពីមនុស្ស	៣ម៉
	៤	បំណិន	ការពណ៌នាអំពីតួអង្គ	២ម៉
	៥	ស្តាប់	រឿង នាយល្អ	២ម៉
	៦	វេយ្យាករណ៍	សព្វនាម	២ម៉
	៧	អំណាន	កល្យាណមិត្ត	២ម៉
	៨	និយាយ	ការពណ៌នាអំពីមិត្ត	២ម៉
	៩	សំណេរ	អត្ថបទពណ៌នាអំពីមនុស្ស	៣ម៉
ទី១៦៖ មធ្យោបាយធ្វើទំនាក់ទំនង	១	វេយ្យាករណ៍	សញ្ញាអស្តា ឬសញ្ញាលេខប្រាំបី (៏)	២ម៉
	២	អំណាន	កំណាព្យ៖ មធ្យោបាយទាក់ទងគ្នា (បទពាក្យប្រាំពីរ)	២ម៉
	៣	សំណេរ	ការទទួលព័ត៌មាន	៣ម៉
	៤	អំណាន	ទំនាក់ទំនងនៅសម័យវិទ្យាសាស្ត្រ	២ម៉
	៥	និយាយ	ការនិយាយទូរស័ព្ទទៅកាន់មិត្ត	២ម៉
	៦	សំណេរ	ការសរសេររឿងនិទាន	៣ម៉
ទី១៧៖ ម្ហូបអាហារខ្មែរ	១	បំណិន	ទំនាក់ទំនងរវាងហេតុនិងផល	២ម៉
	២	អំណាន	ការបរិភោគអាហារនៅភោជនីយដ្ឋាន	២ម៉

	៣	សំណេរ	ការបំពេញបែបបទងាយៗ	៣ម៉
	៤	ស្តាប់	ជំងឺផ្តាសាយថ្មី អេ អេច១ អិន១ (A/H1 N1)	២ម៉
	៥	វេយ្យាករណ៍	គុណកិរិយា	២ម៉
	៦	អំណាន	រឿង អន្ទង់វែងឆ្នាំងវែង	២ម៉
	៧	អំណាន	មេសូត្រ៖ បញ្ជីម្ហូបអាហារខ្មែរ (បទកាកគតិ)	២ម៉
	៨	និយាយ	ការសម្តែងការចូលចិត្តនិងមិនចូលចិត្ត	២ម៉
ទី១៨៖ សណ្ឋានដីប្រទេសយើង	១	អំណាន	មេសូត្រ៖ សម្រស់ទឹកដីកម្ពុជា (បទកាកគតិ)	២ម៉
	២	ស្តាប់	សម្រស់បរិស្ថាន(បទពាក្យប្រាំពីរ)	២ម៉
	៣	វេយ្យាករណ៍	ល្បះនិងផ្នែកទាក់ទងនៃល្បះ	២ម៉
	៤	អំណាន	ទេសភាពភ្នំបូកគោ	២ម៉
	៥	អំណាន	រឿង កំណើតភ្នំនិងទន្លេ	២ម៉
	៦	សំណេរ	ការពណ៌នាអំពីទីកន្លែង	៣ម៉
ទី១៩៖ ប្រភពទឹកនៅកម្ពុជា	១	អំណាន	ការសន្សំសំចៃទឹក	២ម៉
	២	ស្តាប់	ការពារប្រភពទឹក	២ម៉
	៣	វេយ្យាករណ៍	សញ្ញាបដិសេធ ឬទណ្ឌាឃាត(ំ)	២ម៉
	៤	អំណាន	មេសូត្រ៖ ទំនួញព្រះគង្គា (លំនាំបកាកគតិ)	២ម៉
	៥	និយាយ	ការសម្តែងមតិអំពីទឹកស្អាត	២ម៉
	៦	សំណេរ	ការពណ៌នាអំពីប្រយោជន៍នៃទឹក	៣ម៉
ទី២០៖ សត្វនៅប្រទេសយើង	១	បំណិន	កំណាព្យបទកាកគតិ	២ម៉
	២	អំណាន	មេសូត្រ៖ ប្រយោជន៍នៃសត្វស្រុក (លំនាំបទកាកគតិ)	២ម៉
	៣	សំណេរ	រៀបឃ្លាកំណាព្យ	៣ម៉
	៤	បំណិន	គំនិតសំខាន់	២ម៉
	៥	អំណាន	រឿង កង្រោងនិងមាន់ចៃ	២ម៉
	៦	ស្តាប់	ត្រូវការពារសត្វព្រៃ	២ម៉
	៧	វេយ្យាករណ៍	សញ្ញាលេខទោ " ៗ "	២ម៉
	៨	អំណាន	ជីវិតសត្វព្រៃ	២ម៉

សរុបម៉ោងក្នុងមួយឆ្នាំសិក្សា

- សរុបម៉ោងទាំងអស់ ១៣ម៉ × ៣៨សប្តាហ៍ = ៤៩៤ ម៉ោងសិក្សា
- សរុបម៉ោងបង្រៀន ៣១២ ម៉ោងសិក្សា
- សរុបម៉ោងសល់ ១៨២ ម៉ោង

ផ្នែកទី២៖
អត្ថបទស្តាប់

ជំពូកទី១

អត្ថបទស្តាប់ ៖ រឿង អាគីមើលអក្សរ

ថ្ងៃមួយ អ្នករត់សំបុត្របានយកសំបុត្រមួយច្បាប់មកជូនដីជូនខ្ញុំ។ ដីជូនខ្ញុំបានយកវ៉ែនតាពីហោប៉ៅមកពាក់។ គាត់ហែកស្រោមសំបុត្រហើយដកយកសំបុត្រមកអាន។ លោកយាយយកដៃអេះក្បាលទឹកមុខរីករាយខុសពីធម្មតា។ គាត់ដាក់សំបុត្រចុះទៅលើកៅអី ដោះវ៉ែនតាដាក់សង្កត់លើសំបុត្រ រួចដើរចូលទៅក្នុងផ្ទះ ស្រែកប្រាប់ម្តាយខ្ញុំថា គាត់បានទទួលដំណឹងល្អមួយ។

ពេលនោះ ឆ្មារបស់លោកយាយឈ្មោះអាចំរើន ឃើញសំបុត្រដាក់ចោល ក៏លើកជើងខាងមុខទាំងពីរដាក់លើសំបុត្រហើយនិយាយទៅកាន់អាគីឆ្កែថា៖

- ខ្ញុំចង់ដឹងថា តើគេសរសេរអំពីអ្វីខ្លះនៅលើក្រដាសនេះ?
- គេសរសេរអំពីដំណឹងល្អ (អាគីឆ្លើយ)។
- ខ្ញុំដឹងហើយតែដំណឹងល្អនោះជាដំណឹងអ្វី?
- បងគីឯងអាយុ៦ឆ្នាំ ហើយមិនចេះមើលអក្សរទៀត គួរខ្មាសគេណាស់ ! (ចំរើន)។
- ពិបាកអ្វីគ្រាន់តែមើលអក្សរ! ឯងឃើញម្ចាស់យើងធ្វើអ្វីទេ?

ថាហើយ អាគីយកសំបុត្រមកអាន យកជើងអេះត្រចៀកហើយនៅស្ងៀម។ វាប្រើឱ្យចំរើនហុចវ៉ែនតាឱ្យវាពាក់។ វាយកជើងអេះត្រចៀក... ហើយនៅស្ងៀមដដែល។

ចំរើនឃើញដូច្នោះ ក៏និយាយបង្អាប់៖ **"បងឯងគ្មានចេះអ្វីទេ ...បានតែអួត"។**

អាគីខ្មាសចំរើនណាស់។ វានៅស្ងៀមលែងនិយាយស្តី។ វាគិតតែក្នុងចិត្ត៖ **"ការអានអក្សរពិបាកណាស់តើ! អញត្រូវតែខំរៀនសូត្រ ទើបចេះអាននិងសរសេរ"។**

(ដកស្រង់ចេញពីសៀវភៅគ្រូថ្នាក់ទី៣ចោះពុម្ពឆ្នាំ២០១១)

ជំពូកទី២

អត្ថបទស្តាប់ ៖ រឿង ការីរ៉ោហាសន្ធម៉ុក

កុមារម៉ុកបានបែកពីឪពុកម្តាយ រស់នៅជាក្មេងកំព្រា។ ម៉ុកមានរូបសម្បត្តិអាក្រក់ មុខសុសដោយស្នាមអុត។ ម៉ុកមានមាឌតូច ដៃទាំងពីរក្រងែង។ អាយុបាន១១ឆ្នាំ ម៉ុកបានចូលខ្លួនទៅរស់នៅជាមួយព្រះចៅអធិការ **"វត្តគុក"** ក្នុងស្រុកឧដុង្គ។ ម៉ុកជាក្មេងឧស្សាហ៍ព្យាយាម ខំយកចិត្តទុកដាក់បម្រើព្រះគ្រូ មិនឱ្យព្រះអង្គទាស់ព្រះទ័យឡើយ។ ពេលយប់ ម៉ុកបានយកសំរាមសួតៗ ដុតដាំទឹកប្រគេនលោកគ្រូ និងហាត់រៀនអាន សរសេរក្រោមពន្លឺភ្លើងជើងក្រានដោយយកធ្យូងប្រើជំនួសដីស។ ព្រះចៅអធិការបានបំបួសម៉ុកជាសាមណេរ លុះគម្រប់ឆ្នាំក៏បំបួសជាភិក្ខុ។ អាស្រ័យដោយភិក្ខុម៉ុកមានសំឡេងពីរោះនិងមានសំនួនវោហារ ពូកែនិយាយជាពាក្យចួនភ្លាមៗ ឧបាសកឧបាសិកាចំណុះជើងវត្ត បានហៅម៉ុកតាមកាយសម្បទារបស់គាត់ថា" **ម៉ុកក្រងែង ឬម៉ែងក្រងុក"**។ ក្រោយពីភិក្ខុម៉ុកលាចាកសិក្ខាបទ ព្រះគ្រូបាននាំម៉ុកទៅថ្វាយហ្លួងសម្តេចព្រះនរោត្តម។ ព្រះអង្គសព្វព្រះទ័យនឹងម៉ុកណាស់ ក៏តែងតាំងម៉ុកជាចាងហ្វាងកឹងអាល័ក្ស។ ព្រះអង្គតែងតែប្រើឱ្យនិយាយជាពាក្យចួនភ្លាមៗ នៅពេលមានអ្នកយកតង្វាយមកថ្វាយព្រះអង្គ ឬនៅពេលមានហេតុការណ៍កើតឡើង។ ក្រោយមក ព្រះអង្គបានតែងតាំងឋានៈឡើងពីកឹងអាល័ក្ស ទៅជា **"ឧកញ៉ាសន្ធរោហាម៉ុក"**។ ព្រះអង្គបានត្រាស់ហៅម៉ុកថា **"ម៉ែង"** រួចឱ្យម៉ុកឆ្លើយថា **"ក្រងុក"**។ ក្រោយមក ម៉ុកបានរៀបការជាមួយនាងសម ។ លោកមានបុត្រ៥នាក់ ប្រុស៤នាក់ និងស្រី១នាក់ ។

សន្ធម៉ុក បានទទួលមរណភាព នៅទីក្រុងភ្នំពេញក្នុងឆ្នាំ១៩០៨ ។

(ដកស្រង់ចេញពីសៀវភៅគ្រូថ្នាក់ទី៣ចោះពុម្ពឆ្នាំ២០១១)

ជំពូកទី៣

អត្ថបទស្តាប់៖ រឿង ណាស៊ីកុមារផ្ចាត់គ្រាប់ក្រួស

មានកុមារកំព្រាម្នាក់ពិការស្ងិតជើងទាំងសងខាងឈ្មោះណាស៊ី។ វារស់នៅជាមួយអ្នកជិតខាង។ ពីព្រឹកទល់ល្ងាច ណាស៊ីអង្គុយតែមួយកន្លែង ហើយផ្ចាត់គ្រាប់ក្រួសទៅរកទិសដៅមួយជាច្រើនដងក្នុងមួយថ្ងៃៗ។ មិនយូរប៉ុន្មាន វាជំនាញខាងផ្ចាត់គ្រាប់ក្រួស។ វាផ្ចាត់មិនដែលខុសទិសដៅទេ។ កុមារាកុមារីជាច្រើនចូលចិត្តលេងជាមួយណាស៊ីណាស់។ ពួកគេ បានធ្វើរទេះតូចមួយមានកង់បួនសម្រាប់អូសណាស៊ីទៅជាមួយទៀតផង។ ថ្ងៃមួយ ពួកគេអូសរទេះរបស់ណាស៊ីទៅឈប់ក្រោមម្លប់ដើមពោធិ៍ ហើយប្រមូលគ្រាប់ក្រួសមួយគំនរទុកក្បែរណាស៊ី រួចអង្គុយជំកង់ ចាំមើលណាស៊ីផ្ចាត់ ណាស៊ីផ្ចាត់គ្រាប់ក្រួសទម្លុះស្លឹកពោធិ៍ជារូបដំរី បន្ទាប់មកជារូបចៀម និងរូបក្របី។ ពេលត្រូវឆ្លងកាត់ពន្លឺថ្ងៃស្លឹកឈើទាំងនោះ ចោលស្រមោលរូបសត្វទាំងនោះមកលើដី ដោយសភាពស់រវើកគួរឱ្យស្រប់ស្មែង។

ថ្ងៃមួយ ពេលកំពុងលេង ស្រាប់តែមានក្បួនដង្កែស្តេចកាត់តាមទីនោះ។ ឃើញដូច្នោះ ពួកគេនាំគ្នាពួន។ ស្តេចឃើញម្លប់ពោធិ៍ត្រជាក់ស្រួល បញ្ជាក្បួនឱ្យឈប់សម្រាក។ ពេលនោះ ស្តេចឃើញស្រមោល រូបសត្វកំពុងរេរាំនៅលើដី ទ្រង់នឹកសរសើរដល់ទេពកោសល្យអ្នកចោះស្លឹកឈើនោះណាស់ ក៏បញ្ជាអាមាត្យឱ្យដើរកេ។ អាមាត្យបានដើរកេឃើញណាស៊ី ហើយនាំមកគាល់ស្តេច។ ណាស៊ីរៀបរាប់ពីវិធី ដែលខ្លួនបានធ្វើរូបសត្វទាំងនោះ។ ស្តេចបញ្ជាឱ្យណាស៊ីធ្វើ។ ណាស៊ីកាន់គ្រាប់ក្រួសមួយក្តាប់ ហើយផ្ចាត់ទៅលើម្តងមួយៗរហូតបានជារូបសត្វនៅលើស្លឹកពោធិ៍។ ស្តេចនិងនាម៉ឺនទាំងអស់ កោតសរសើរស្នាដៃដ៏ចម្លែកនេះណាស់ ។ ព្រះអង្គបាននាំណាស៊ីទៅនៅក្នុងវាំង។

ថ្ងៃមួយ ស្តេចបញ្ជាអ្នកបម្រើឱ្យចងវាំងននខាងក្រោយកៅអីទ្រង់អង្គុយ ដោយចោះប្រហោងតូចមួយនៅលើវាំងននោះ។ ស្តេចបង្គាប់ណាស៊ីឱ្យអង្គុយក្រោយវាំងនន រួចប្រាប់៖ **"បន្តិចទៀត មានបុរសម្នាក់មកអង្គុយចំពីមុខយើង។ ពេលគាត់ហាមាត់និយាយ ឯងត្រូវផ្ចាត់ដីមួយដុំតូចឱ្យចូលក្នុងមាត់គាត់ឮទេ?"**។ ពេលនោះ ទីប្រឹក្សាទាំងអស់អញ្ជើញមកដល់។

ការប្រជុំចាប់ផ្តើម។ លោកទីប្រឹក្សាដែលធ្លាប់និយាយច្រើន ក៏ចាប់ផ្តើមភ្លាមដៃរ។ តែនៅពេលគាត់ហាមាត់និយាយ ណាស៊ីផ្ចាត់ដីមួយដុំតូចចូលមាត់គាត់ផ្តុក។ គាត់សំងំស្ងៀមសិន ដោយស្មានថាសត្វល្អិតហើរចូលក្នុងមាត់។ ប៉ុន្តែលើកណាដែលគាត់ហាមាត់និយាយ ព្រឹត្តិការណ៍ដដែលនេះកើតឡើងជានិច្ច។ ស្តេចបានឱ្យទីប្រឹក្សាឯទៀតបញ្ចេញយោបល់ដោយរីករាយ។ ចុងក្រោយបង្អស់ ស្តេចសួរទីប្រឹក្សាដែលនិយាយច្រើន៖ **"លោកមានរឿងអ្វីត្រូវរាយការណ៍ឬទេ? យើងពុំបានទទួលព័ត៌មានអ្វីពីលោកសោះ ថ្ងៃនេះ!"**។ លោកទីប្រឹក្សាតបវិញ៖ **"ទូលបង្គំមានរឿងរ៉ាវច្រើនណាស់ ដែលត្រូវរាយការណ៍។ ប៉ុន្តែរាល់ ពេលទូលបង្គំហាមាត់និយាយសត្វល្អិតចេះតែហើរចូលមាត់ ធ្វើឱ្យទូលបង្គំនិយាយពុំកើតសោះ"**។ ស្តេចឆ្លើយ៖" **នេះជាមេរៀនរបស់លោក! ក្រោយៗនៅពេលបើកអង្គប្រជុំ លោកច្បាស់ជាយល់ថាអស់លោកឯទៀតក៏មានរឿងសំខាន់ដូចលោកដែរ"**។ ចាប់ពីពេលនោះមក គាត់តែងតែស្តាប់សេចក្តីរាយការណ៍របស់ទីប្រឹក្សាដទៃទៀតនិងរង់ចាំវេនគាត់ ត្រូវរាយការណ៍ទើបគាត់និយាយ។ ស្តេចក៏ឈប់មានកង្វល់ពីរឿងនេះទៀតដែរ។ ឯណាស៊ីក៏បានរស់នៅក្នុងវាំងយ៉ាងសុខសាន្តរៀងទៅ។

«វិជ្ជាអ្វីដែលចេះប្រាកដនឹងធ្វើឱ្យមានអនាគតល្អ»

(ដកស្រង់ចេញពីសៀវភៅគ្រូថ្នាក់ទី៣ចោះពុម្ពឆ្នាំ២០១១)

ជំពូកទី៤

អត្ថបទស្តាប់៖ កំណាព្យ ទេសភាពជើងភ្នំ (បទ៣ក្យ៧)

ខ្ញុំធ្លាប់រស់នៅក្បែរជើងភ្នំ ឮសូរសត្វយំឆ្លងឆ្លើយគ្នា
ក្រអូបផ្កាព្រៃសែនរមនា រំភាយគន្ធាពីចម្ងាយ។
រសៀលត្រជាក់ធ្លាក់ជំនោរ សំឡេងទឹកហូរនៅមិនឆ្ងាយ
ទេសភាពជើងភ្នំគន់មិនណាយ អារម្មណ៍ស្រស់ស្រាយនឹងធម្មជាតិ។
ពេលនេះរូបខ្ញុំនៅឆ្ងាយក្រៃ តែនៅស្រមៃមិនចង់ឃ្លាត
ចង់ឃើញទេសភាពទីនោះទៀត សម្រស់ធម្មជាតិជក់ជាប់ចិត្ត។

(ដកស្រង់ចេញពីសៀវភៅគ្រូថ្នាក់ទី៣បោះពុម្ពឆ្នាំ២០១១)

ជំពូកទី៥

អត្ថបទស្តាប់៖ ការផ្សព្វផ្សាយការប្រមូលកុមារចូលរៀន

សាលាបឋមសិក្សាភូមិយើងសូមជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ថានៅថ្ងៃទី១ ខែតុលា ខាងមុខនេះគឺជាថ្ងៃចូលរៀនក្នុងឆ្នាំសិក្សាថ្មី។

អាស្រ័យហេតុនេះ សូមបងប្អូនដែលជាមាតាបិតា ឬអាណាព្យាបាលកុមារទាំងអស់នាំកូនចៅដែលមានអាយុគ្រប់៦ឆ្នាំទៅចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សាភូមិយើងចាប់ពីពេលនេះតទៅឱ្យបានគ្រប់ៗគ្នាកុំបីខាន។ សូមបញ្ជាក់ថាការចុះឈ្មោះចូលរៀនពុំមានបង់ប្រាក់ទេ។

(ដកស្រង់ចេញពីសៀវភៅគ្រូថ្នាក់ទី៣បោះពុម្ពឆ្នាំ២០១១)

ជំពូកទី៦

អត្ថបទស្តាប់៖ ព័ត៌មានអំពីខ្យល់ព្យុះ

ពូសុខរស់នៅតំបន់មាត់សមុទ្រ។ បន្ទាប់ពីគាត់បានស្តាប់វិទ្យុស្តីពីព័ត៌មានខ្យល់ព្យុះ គាត់បានផ្សព្វផ្សាយបន្តដូចតទៅ៖

វិទ្យុបានផ្សាយថា នៅព្រឹកថ្ងៃស្អែកនឹងមានព្យុះធំមួយបក់ចេញពីប្រទេសចិន។ ព្យុះនេះនឹងឆ្លងកាត់ប្រទេសវៀតណាម ហើយចូលមកប្រទេសកម្ពុជា ក្នុងពេលមួយដែលមិនអាចកំណត់បាន។ ព្យុះនេះនឹងបោកបក់មកប៉ះតំបន់មួយចំនួននៅក្នុងខេត្តកោះកុង ក្រុងព្រះសីហនុ ...។

រាជរដ្ឋាភិបាលធ្វើសេចក្តីអំពាវនាវដល់ប្រជាជន ដែលរស់នៅតាមតំបន់មួយចំនួនខាងលើ ឱ្យប្រុងប្រយ័ត្ន និងហាមប្រជាជនចេញនេសាទក្នុងសមុទ្រ ធ្វើដំណើរតាមផ្លូវទឹកនិងផ្លូវអាកាសដើម្បីចៀសវាងគ្រោះថ្នាក់។

(ដកស្រង់ចេញពីសៀវភៅភាសាខ្មែរថ្នាក់ទី៥បោះពុម្ពឆ្នាំ១៩៩៧)

ជំពូកទី៧

អត្ថបទស្តាប់៖ រឿង កំណប់ឪពុកខ្ញុំ

កាលពីព្រេងនាយ មានកសិកររោះម៉ាយម្នាក់ មានកូនកំលោះបីនាក់។ គាត់ជាមនុស្សឆ្លាប់តែដុតដៃដុតជើងក្នុងការប្រកបការងារ មិនដែលបណ្តោយឱ្យពេលវេលាកន្លងទៅឥតប្រយោជន៍ឡើយ។ កសិករនោះបាននិយាយប្រាប់គេឯងថា គាត់មានកូនកំលោះបីនាក់ ជាយុវជនប្រកបដោយរូបកាយមាំមួន កម្លាំងខ្លាំងក្លា រូបសម្បត្តិស្អាតបាត តែអ្នកទាំងបីនោះមិនទម្លាប់ធ្វើការរសោះ។ គេចូលចិត្តអង្គុយជជែកគ្នាលេងឥតប្រយោជន៍ក្រោមម្លប់ឈើ ឬក៏ទៅស្ទូចត្រីលេង

នៅមាត់បឹង។ គេតែងនិយាយ៖ "យើងចាំបាច់ធ្វើការងារធ្វើអ្វីទៀត ទ្រព្យមានមិនខ្វះ តាមអីពុកគាត់ជាមនុស្សរពឹសដៃរពឹសជើង"។

ពេលវេលាចេះតែកន្លងទៅ ឪពុកកំសត់កាន់តែជរា កម្លាំងកាន់តែខ្សោយ គាត់មិនអាចធ្វើការងារដូចមុនៗឡើយ។ ច្បារដំណាំស្ងិតរញម ដុះស្មៅទ្រុបទ្រុលក្នុងចម្ការដោយគ្មានអ្នកថែទាំ។

បុរសឪពុកព្រួយបារម្ភ ពិបាកចិត្ត ចំពោះអាកប្បកិរិយារបស់កូនគាត់ ដែលមិនសម្របខ្លួនធ្វើការងារអ្វីសោះ ទម្លាប់ខ្លួនតែជជែកគ្នាលេងឥតប្រយោជន៍ ឬទៅស្ងួចត្រីលេងនៅមាត់បឹង។ គាត់ក៏ធ្លាក់ខ្លួនឈឺចុះខ្សោយជាលំដាប់។

នៅពេលដែលដឹងខ្លួនថានឹងត្រូវសូន្យសង្ខារ ក្នុងពេលដ៏ខ្លីនេះ គាត់ក៏ហៅកូនទាំងបីមកជួបជុំគ្នា ហើយនិយាយ៖ **បើអត់ពីពុក តើកូននឹងរស់នៅយ៉ាងដូចម្តេច?** កូនទាំងបីរន្ធត់យ៉ាងខ្លាំង ហើយកូនច្បងអង្វរឪពុក៖ **ពុក! តើកូនត្រូវធ្វើដូចម្តេច? ពុកមានប្រសាសន៍ប្រាប់កូនផង! ល្អហើយកូន! ពុកនឹងនិយាយរឿងសម្ងាត់ប្រាប់កូន។ កាលម្តាយឯងនៅរស់ ពុកនិងម៉ែឯងបានរកស៊ី សន្សំបានកាក់មាសមួយកូនក្រឡ។ ពុកបានយកក្រឡទៅកប់ក្នុងដីចម្ការជិតផ្ទះយើង។ ពេលនោះពុកមិនច្បាស់ថានៅកន្លែងណាទេ។**

កូនត្រូវខំរកកំណប់នោះណាកូន! ហើយត្រូវអត់ធ្មត់ទម្លាប់ខ្លួនក្នុងការងារលំបាកនោះផង។ បើកូនរកឃើញកំណប់នោះ កូនអាចរស់នៅយ៉ាងសុខសាន្ត គ្មានកង្វះខាតទេ។ ផ្តាំកូនរួចហើយ ឪពុកកំសត់ក៏រលត់សង្ខារ លាចាកលោកនេះទៅ។ ក្រោយពីបញ្ចុះសពឪពុករួចហើយ កូនច្បងនិយាយទៅកាន់ប្អូនទាំងពីរ៖ **"ប្អូននៅចាំបណ្តាំឪពុកយើងទេ? ទៅយើងនាំគ្នារកកំណប់ឪពុកយើង"** ។ ទាំងបីនាក់បងប្អូននាំគ្នាកកាយដីជិតៗផ្ទះ តែមិនឃើញអ្វីសោះ។ អ្នកទាំងបីនាំគ្នាទៅជីកគាស់កកាយដីជុំវិញផ្ទះ ក្នុងច្បារក្នុងចម្ការទៀតក៏រកពុំឃើញក្រឡមាសសោះ។ កូនពៅបាននិយាយឡើង៖ **"ពុក! បើគាត់កប់ក្រឡមាស គាត់មិនដែលកប់រាក់នោះទេ ប្រាកដជាកប់ជ្រៅហើយ។ មក! យើងទៅគាស់ត្រឡប់ដីនេះម្តងទៀតឱ្យជ្រៅៗគង់តែឃើញទេ"**។ ម្តងនេះ យុវជនទាំងបីនាក់ ខំពុះពារយ៉ាងសស្រាក់សស្រាំមិនមើលបំណាំគ្នា ទ្រាំនឹងការលំបាក ប្រឹងគាស់ត្រឡប់ដីមិនសំចៃកម្លាំង។ គេខំគាស់អស់ចិត្តអស់ចង់ មិនប្រទះកំណប់សោះ។ បងប្អូនទាំងបីនាក់អង្គុយសម្រាកក្រោមម្លប់ឈើមួយ ហើយសំឡឹងមើលដីចម្ការរបស់គេដោយស្ងៀមស្ងាត់។

កូនច្បងបាននិយាយឡើង៖ **"ដីយើងល្អណាស់មិនអាចទុកចោលបានទេ។ យើងនាំគ្នាព្រោះស្រូវទៅ យើងមិនខាតបង់កម្លាំងចោលអសារឥតការដែរ"។** ស្រុះស្រួលគ្នាហើយ គេក៏នាំគ្នាសាបព្រោះស្រូវពេញដី ហើយនាំគ្នាថែរក្សាយ៉ាងយកចិត្តទុកដាក់។ ដើមស្រូវដុះលូតលាស់ត្រកុំត្រកាល បែកគុម្ពត្រសុំត្រសាយ ចេញកួរពាសពេញស្រែ ហាក់ដូចកម្រាលព្រំពណ៌មាស។

កសិផលបានច្រើនលើសលប់ យុវជនទាំងបីនាក់បងប្អូនយកផលស្រូវទៅលក់ បានប្រាក់ច្រើនក្រាស់ក្រែលណាស់។ ពេលនោះ កូនច្បងលាន់មាត់៖ **"យើងទម្លាប់តស៊ូប្រឹងគាស់កាប់ធ្លាដីយើងនេះ ជាការប្រសើរណាស់ គឺយើងរកកំណប់ដែលពុកយើងបានប្រាប់ មុនពេលគាត់អនិច្ចកម្មទៅនោះហើយ"។**

(ដកស្រង់ចេញពីសៀវភៅភាសាខ្មែរថ្នាក់ទី៧បោះពុម្ពឆ្នាំ២០០៩)

ជំពូកទី៩

អត្ថបទស្តាប់ ៖ រឿង ផ្លែឈើចម្លែក

ពេលត្រឡប់មកពីមើលពិព័រណ៌ជាតិវិញ ភារីមានទឹកមុខរីករាយជាងធម្មតា។ ភារីទៅជិតម្តាយនាងហើយនិយាយថា៖ **"ម៉ាក់ៗ! កូនទៅមើលពិព័ណ៌សប្បាយណាស់ ព្រោះមានវត្ថុប្លែកៗជាច្រើន"!។** ម្តាយសួរកូនថា៖ **"តើកូនចាប់អារម្មណ៍អ្វីជាងគេ?** ភារីតបថា៖ **"ចាសម៉ាក់! កូនឃើញដើមចេកស្រុកយើង ផ្លែ១០០ស្និត។ ស្នងវាមកទល់នឹងដីណាម៉ាក់"។** ម្តាយភារីក៏តបថា **"អូ! ពិតជាប្លែកមែន"។** ប៉ាភារីឮហើយក៏និយាយថា ៖ **"លើលោកនេះ មានវត្ថុចម្លែកច្រើនយ៉ាងណាស់។ ប៉ាបានអានអត្ថបទកាសែតមួយនិយាយអំពីផ្លែល្ពៅចម្លែកមួយនៅប្រទេសអាមេរិក។ វាមានទម្ងន់៤៨១**

គីឡូក្រាម។ គិតទៅធ្ងន់ជាងប៉ាដល់ទៅ ៨ដងឯណោះ ឯម្ចាស់ផ្លែល្មៅនោះ ប្រកួតឈ្នះគេបានប្រាក់យ៉ាងច្រើនសន្ធឹកទៀតផង"។ ឪពុកនិយាយរួចក៏ហុចរូបថតនៅក្នុងកាសែតទៅឱ្យកូនមើល ។ ការមើលហើយក៏លាន់មាត់ថា៖ **"ឃើ! ពិតជាធំមែន។ លោកប៉ា! បើយើងដាំអ្វីបានល្អចម្លែក តើយើងអាចយកទៅដាក់តាំងពិព័ណ៌បានដែរឬទេ?"** ឪពុកងក់ក្បាលតបថា៖ **"ប្រាកដជាបាន"**។ ការមានទឹកមុខញញឹមប្រហែលជានាងមានសង្ឃឹមថានឹងអាចធ្វើអ្វីបានល្អប្លែកជាមិនខាន។

(ដកស្រង់ចេញពីសៀវភៅគ្រូភាសាខ្មែរថ្នាក់ទី២បោះពុម្ពឆ្នាំ១៩៩៧)

ជំពូកទី១០
អត្ថបទស្តាប់ ៖ រឿង ឆ្កែនិងសេះ

ឆ្កែនិងសេះជាសម្លាញ់នឹងគ្នា។ ពួកវារស់នៅជាមួយអ្នកជ្រលក់ម្នាក់។ យប់មួយ ម្ចាស់វាដេកលក់ស៊ប់មិនដឹងខ្លួន។ ពេលនោះ មានចោរម្នាក់លបចូលទៅក្នុងផ្ទះលួចយក ទ្រព្យសម្បត្តិរបស់ម្ចាស់វា។ សេះឃើញហើយក៏និយាយទៅកាន់ឆ្កែ៖ **"នែសម្លាញ់! នេះជាមុខងារឯងហើយ។ ហេតុអ្វីបានជាឯងមិនព្រុសឱ្យម្ចាស់យើងភ្ញាក់"?** ឆ្កែឆ្លើយ៖**"ខ្ញុំថែរក្សាផ្ទះនេះទាំងយប់ទាំងថ្ងៃ។ ឯងក៏ដឹងដែរ។ ម្ចាស់យើងក៏បានសុខយូរណាស់មកហើយ តែគាត់ពុំសូវគិតគូរពីចំណីអាហារខ្ញុំឡើយ"។** សេះក៏បន្ទោសឆ្កែ៖**"យើអាចង្រៃ! ម្តេចក៏ឯងនិយាយអ៊ីចឹង នេះជាភារកិច្ចរបស់ឯងដែលជាអ្នកបម្រើ"។** សេះមិនសប្បាយចិត្តសោះ។ វាស្រែកឡើងយ៉ាងខ្លាំង ដើម្បីឱ្យម្ចាស់វាភ្ញាក់។

ពេលនោះ ម្ចាស់ភ្ញាក់ក្រញាង ហើយនឹកខឹងនឹងសេះដែលធ្វើឱ្យដាច់ដំណេករបស់ខ្លួន។ បុរសនោះទាញយកដំបង រួចស្ទុះចេញមកខាងក្រៅ វាយសេះយ៉ាងខ្លាំង។ សេះឈឺចាប់ណាស់។ សាច់វាញាក់ទទ្រើក។ សេះហួសចិត្តនឹងម្ចាស់ខ្លួនក៏ងិនក្បាលជ្រប់ទៅដី។

(ដកស្រង់ចេញពីសៀវភៅគ្រូភាសាខ្មែរថ្នាក់ទី២បោះពុម្ពឆ្នាំ១៩៩៧)

ជំពូកទី១១
អត្ថបទស្តាប់៖ រឿង ទន្សាយនិងខ្យង

មាននិទានតំណាលថា សម័យថ្ងៃមួយ មានទន្សាយចុះមកផឹកទឹកត្រពាំង។ ទន្សាយផឹកទឹកមិនទាន់ឆ្អែតផង ក៏ប្រទះឃើញខ្យងមួយកំពុងអណ្តែតខ្លួននៅលើផ្ទៃទឹក។ ទន្សាយឃើញដូច្នេះក៏ស្អប់ខ្ពើមខ្យងជាខ្លាំង។ ទន្សាយបានគេចខ្លួនទៅផឹកទឹកនៅប្រឡង់មួយផ្សេងទៀតដែលស្ថិតនៅក្បែរនោះដែរ។ ខ្យងឃើញអាកប្បកិរិយាទន្សាយដូច្នេះក៏ស្រដីទៅទន្សាយថា៖ " **អេ! បងទន្សាយ បងមកផឹកទឹកនៅទីនេះ មានបានសុំអ្នកណាហើយឬនៅ?** " ទន្សាយឆ្លើយតបទៅវិញទាំងមួហ្មងដោយកំបុតៗថា៖ " **ត្រពាំងនេះគ្មានម្ចាស់ទេ ! "យើងមិនចាំបាច់សុំអ្នកណាក៏បានដែរ!** " ខ្យងស្រដីទៅកាន់ទន្សាយវិញថា៖ " **យើងជាអ្នកថែរក្សាទឹកនេះយូរណាស់មកហើយ បើចង់ផឹកត្រូវតែសុំខ្ញុំសិន** " ។ ទន្សាយឮខ្យងពោលពាក្យដូច្នេះ កើតក្តីក្តៅក្រហាយក៏ពោលចំអកខ្លាំងៗថា៖ នែខ្យង! ឯងមិនដែលបានស្គាល់ទីវាលដីស្រែចម្ការឯណាឆ្ងាយផង យកតែមាត់ធ្វើជាជើង ស្គាល់តែប្រឡង់ទឹកប៉ុណ្ណឹង អួតថាខ្លួនឯងជាអ្នកថែរក្សាទឹកនេះផងហ្អឺ។ ខ្យងឆ្លើយតបវិញថា៖ ខ្ញុំគ្មានជើងពិតមែន ហើយក៏មិនស្គាល់ទីវាលដីស្រែចម្ការឆ្ងាយៗដូចបងថាមែន តែបើបងទន្សាយចង់ភ្នាល់ យើងរត់ប្រណាំងគ្នាទៅខ្ញុំមិនខ្លាចបងទេ។

ទន្សាយឮខ្យងភ្នាល់រត់ប្រណាំងគ្នាបែបនេះ កាន់តែក្តៅក្រហាយឡើងនឹកក្នុងចិត្តថា មិនគួរអោខ្យងនេះហ៊ាននិយាយពាក្យដូច្នេះសោះ នរណាៗក៏ដឹងដែរថា ខ្លួនអញជាអ្នកមានប្រាជ្ញា ហើយរត់លឿន និងរហ័សជាងគេបំផុត។ ទន្សាយប្រាប់ខ្យងថា៖ ចុះខ្ញុំមានទៅខ្លាចអីខ្យងឯងនោះ! ព្រឹកស្អែក យើងជួបគ្នានៅទីនេះ។ យើងរត់ប្រណាំងគ្នាបីជុំត្រពាំងនេះ។ បើខ្ញុំចាញ់ ខ្ញុំឈប់ផឹកទឹកត្រពាំងនេះ។ ឯខ្យងឯងបើចាញ់ខ្ញុំវិញ ក៏ត្រូវតែឈប់រស់នៅក្នុងទឹកត្រពាំងនេះដែរ។ ពោលចប់ទន្សាយ ក៏ដើរចេញទៅ។

ចំណែកខ្យង ពេលឃើញទន្សាយចេញទៅបាត់ ក៏ហៅគ្នីគ្នាមកប្រជុំ ហើយណាត់គ្នាថា៖ " **ព្រឹកស្អែកយើងត្រូវរាយបណ្តាក់គ្នា តាមមាត់ត្រពាំងនេះ ។ បើឮទន្សាយស្រែកហៅ អ្នកដែលនៅខាងមុខត្រូវតែឆ្លើយថា កូក** " ។ ស្អែកឡើងទន្សាយបានមកដល់ ឃើញខ្យងនៅចាំនៅនឹងកន្លែងណាត់គ្នារួចជាស្រេច។ ទន្សាយ និងខ្យងក៏ចាប់ផ្តើមរត់ប្រណាំងគ្នា។ ទន្សាយរត់បានមួយដុំត្រពាំងក៏ស្រែកប្រកូកហៅខ្យងវ៉ីយ! ខ្យង! ។ ខ្យងនៅពីមុខទន្សាយស្រែកឡើង"**កូក**"។ ទន្សាយឮសំឡេងខ្យង ឆ្លើយនៅមុខដូច្នេះ នឹកស្មានថាខ្យងរត់លឿនជាងខ្លួនមែន ក៏ខំរត់ពេញទំហឹង។ លុះរត់បានមួយដុំទៀត ទន្សាយស្រែកហៅខ្យងម្តងទៀត។ សំឡេង " **កូក** " លាន់ឮនៅខាងមុខដដែល។ ទន្សាយពុំបានគិតថា នេះជាល្បិចកលរបស់ខ្យងឡើយ វាគិតថា ខ្យងរត់លឿនជាងវាមែន។ ទន្សាយក៏ខំបន្ថែមល្បឿនអស់ពីកម្លាំងកាយចិត្ត។ គ្រប់បីដុំទន្សាយមកដល់ទីណាត់។ ប៉ុន្តែជាការខកចិត្តសម្បើមណាស់ ព្រោះទីនោះ ខ្យងបានរង់ចាំទន្សាយមុនជាស្រេច។ ទន្សាយក៏យល់ព្រមចាញ់ ទន្សាយក៏នឹកខ្មាសខ្លួនឯងយ៉ាងខ្លាំង ដែលខ្លួនរត់ចាញ់ខ្យង។ វាក៏រត់ចេញពីទីនេះ ហើយប្តេជ្ញាចិត្តឈប់ផឹកទឹកត្រពាំងជារៀងរហូត។

ចាប់តាំងពីពេលនោះមក គេសង្កេតឃើញសត្វទន្សាយ ឈប់ផឹកទឹកត្រពាំងមែន រហូតមកដល់សព្វថ្ងៃនេះ ហើយក៏ទន្សាយមិនដែលផឹកទឹកដែរ ។ ឯខ្យងក៏រស់នៅក្នុងត្រពាំងយ៉ាងសុខសាន្តជារៀងរហូតមក។

"ចេះឯង ឱ្យក្រែងចេះគេ"

(ដកស្រង់ពីសៀវភៅភាសាខ្មែរសម្រាប់គ្រូថ្នាក់ទី២ បោះពុម្ពឆ្នាំ១៩៩៧)

ជំពូកទី១៣

អត្ថបទស្តាប់៖ រឿង សេដ្ឋីនិងអ្នកលក់ធ្យូង

ព្រឹកនេះ នៅពេលចេញលេង កុមារវាសនាដែលជាកូនសេដ្ឋីបានឈ្លោះជជែក ដណ្តើមសៀវភៅមើលមួយពីកុមារគីមដែលជាកូនអ្នកលក់ធ្យូង។ វាសនាដណ្តើមសៀវភៅមិនបាន ខឹងពេកក៏ស្រែកតិះដៀលឱ្យគីមថា៖

- ឪពុកឯងជាអ្នកទីទ័លក្រ រកស៊ីលក់ធ្យូង ថោកទាបណាស់ គ្មានពូជអម្បូរទេ!
- គីមឮសម្តីនេះ មានការអៀនខ្មាសជាខ្លាំង មុខវាឡើងក្រហម។ វាខាំមាត់សម្រក់ទឹកភ្នែក អួលដើមករកឆ្លើយអ្វីទៅវិញពុំរួច។ មកដល់ផ្ទះ គីមនិយាយរឿងហេតុ និងពាក្យតិះដៀលរបស់វាសនាទាំងអស់ ប្រាប់ឪពុកវាៗអាក់អន់ចិត្តរកអ្វីប្រៀបគ្មាន។

រសៀលថ្ងៃដដែល ឪពុកគីមបណ្តើរគីមទៅសាលារៀន ដើម្បីរាយការណ៍ប្តឹងដល់លោកគ្រូតាមដំណើររឿង។ គាប់ជួនពេលនោះ លោកសេដ្ឋីក៏បានជូនកូនមកដល់មុខបន្ទប់រៀនដែរ។ សេដ្ឋីឮសំឡេងជជែកគ្នា ស្តីពីឈ្មោះគាត់ក៏ដើរចូលមក។

- លោកសេដ្ឋី (លោកគ្រូនិយាយ) អ្នកលក់ធ្យូងនេះបានមកប្តឹងខ្ញុំ ដើម្បីរកយុត្តិធម៌អំពីរឿងកូនលោក និយាយតិះដៀល ចំពោះរូបគាត់ថា៖ **"ឪពុកឯងជាអ្នកទីទ័លក្រ រកស៊ីលក់ធ្យូង ថោកទាបណាស់ គ្មានពូជអម្បូរទេ !"។** លោកសេដ្ឋីជ្រួញចិញ្ចើម ទឹកមុខស្លូត ងាកមកសួរកូនគាត់ថា៖
- តើពាក្យទាំងនេះ ជាពាក្យពិតដូចឯងថាមែនឬ?

  វាសនាឈរស្ងៀមឱនមុខជ្រប់។ ឃើញដូចនោះ សេដ្ឋីទាញដៃកូនឱ្យឈរទល់មុខគីម ហើយបង្គាប់ថា៖
- និយាយសុំទោសមិត្តឯងភ្លាមទៅវាសនា!

  មុខវាសនាឡើងក្រហមដោយអាម៉ាស់ វាឈ្ងោកមុខចុះ ឥតនិយាយស្តី។ សេដ្ឋីប្រាប់កូនម្តងទៀតថា៖
- ម្តេចមិននិយាយសុំទោសមិត្តឯងភ្លាមទៅ? ឥឡូវចាំថាតាមពុក៖ **"អត់ទោសឱ្យខ្ញុំចុះគីម នូវពាក្យពុំគប្បីដែលខ្ញុំបានមើលងាយដល់ឪពុកឯង ហើយដែលនៅពេលនេះ ឪពុកខ្ញុំនឹងសុំឪពុកឯង ធ្វើជាមិត្តទៅអនាគត"។**

អ្នកលក់ធ្យូងឮដូច្នោះ ក្រោកឡើងលើកដៃហាមវាសនាមិនឱ្យនិយាយ តែលោកសេដ្ឋីមិនយល់ស្របតាម។ វាសនាងើបមុខសម្លឹងឪពុកវាបន្តិចទើបពោលតិចៗថា៖

- អត់ទោសឱ្យខ្ញុំចុះគឺមនូវពាក្យពុំគប្បីដែលខ្ញុំបានមើលងាយដល់ឪពុកឯង ហើយដែលនៅពេលនេះ ឪពុកខ្ញុំនឹងសុំឪពុកឯងធ្វើជាមិត្តទៅអនាគត។

វាសនាពោលចប់ សេដ្ឋីស្ទុះទៅចាប់ដៃអ្នកលក់ធ្យូងច្របាច់យ៉ាងណែន និងយ៉ាងស្និទ្ធស្នាល រួចច្រានស្មាវាសនាឱ្យទៅឱបគីម។ បន្ទាប់មក លោកងាកមកនិយាយនឹងលោកគ្រូថា៖

- អនុគ្រោះឱ្យខ្ញុំម្តងចុះ! សូមលោកគ្រូមេត្តាដាក់កុមារទាំងពីរនេះ ឱ្យអង្គុយតុជាមួយគ្នា ចាប់ពីពេលនេះតទៅ។

លោកគ្រូញញឹម ទទួលយល់ព្រម រួចប្រាប់គីមឱ្យយកសម្ភៀតសៀវភៅមកអង្គុយតុខាងមុខជាមួយវាសនា។ ចប់សព្វគ្រប់ហើយសេដ្ឋីក៏លាអ្នកលក់ធ្យូង និងលោកគ្រូវិលទៅគេហដ្ឋានវិញ ដោយរីករាយ។

អ្នកលក់ធ្យូងឈរទ្រឹងស្ងៀម អល់អែកក្នុងចិត្ត។ គាត់សម្លឹងមុខកុមារទាំងពីរ ដែលអង្គុយជិតគ្នាហើយដើរមកទះស្មាវាសនាតិចៗ ប្រកបដោយសមានចិត្ត និងក្តីអាណិតរួចក៏លាលោកគ្រូចេញទៅបាត់ទៅ។

- នេះជាមេរៀនដ៏ប្រពៃសម្រាប់ថ្ងៃនេះ (លោកគ្រូនិយាយទៅកាន់សិស្សទាំងអស់) និងជាមេរៀនជាក់ស្តែងដែលមានពួកឯងរាល់គ្នា ធ្វើជាកសិណសាក្សី។ ចូរឯងចាំឱ្យច្បាស់ថា៖ **"មិនថាក្រ ឬមានយើងត្រូវរួបរួមសាមគ្គីស្រឡាញ់គ្នារាប់អានទៅវិញទៅមក"។**

(ដកស្រង់ចេញពីសៀវភៅគ្រូភាសាថ្នាក់ទី៣ពោះពុម្ពឆ្នាំ១៩៩៣)

ជំពូកទី១៥
អត្ថបទស្តាប់ ៖ រឿង នាយល្អ

មានមេព្រាបមួយ បានដឹកនាំរ៉ូងព្រាបទៅរកចំណី។ ពួកវាប្រទះឃើញស្រូវអង្ករយពាសពេញ ទីកន្លែងមួយ។

ពេលឃើញចំណីច្រើនសន្ធឹកសន្ធាប់យ៉ាងនេះ ពួកព្រាបបម្រុងនឹងចុះស៊ីចំណីទាំងនោះ តែមេហ្វូងព្រាបបានឃាត់ថា៖ **"នែ! សម្លាញ់ទាំងអស់! ចំណីអាហារដែលយើងបានឃើញដោយងាយយ៉ាងនេះ ពុំមានជាចំណីដែលគួរឱ្យចុះទៅបរិភោគឡើយ ព្រោះវាអាចជានុយសម្រាប់ចាប់ពួកយើងក៏សឹងមាន"។** រ៉ូងព្រាបក៏ឮហើយក៏តបថា **"ពួកយើងខំហើរកចំណី ។ ពេលប្រទះចំណីហើយ ហេតុអ្វីបានជាលោកនាយយើងមិនឱ្យបរិភោគដូចនេះ ។ តើយើងទៅរកឯណាទៀតព្រោះចំណីនេះយើងរកបានដោយកម្រ"។** គិតហើយរ៉ូងព្រាបក៏នាំគ្នាចុះស៊ីចំណី។ ព្រានឃើញក៏កន្ត្រាក់លប់។ ព្រាបទាំងអស់ជាប់ក្នុងលប់។ មេហ្វូងឃើញក្តីអន្តរាយ ហើយក៏រិះគិត រកមធ្យោបាយជួយរ៉ូងព្រាបទាំងអស់។

មេហ្វូងនិយាយទៅកាន់រ៉ូងព្រាបថា៖ **"ពួកយើងត្រូវតែស្រុះគ្នាឡើង ហើយខំទះស្លាបហើរព្រមៗគ្នា ដើម្បីឱ្យរួចជីវិតពីអន្ទាក់ព្រាន ។ ឥឡូវស្តាប់ខ្ញុំ កាលណាឮខ្ញុំរាប់ដល់បី អ្នកទាំងអស់ត្រូវទះស្លាបព្រមៗគ្នាឡើង"។** ថាហើយ មេរ៉ូងក៏ស្រែកថា៖ **"មួយ! ពីរ! បី!"**ដោយកម្លាំងទះស្លាបហើរព្រមគ្នា រ៉ូងព្រាបបានហើរឡើងទៅលើអាកាស ជាប់ទាំងលប់ទៅជាមួយផង។ រ៉ូងព្រាបបានចុះត្រង់ដំបូកមួយ ដែលជាជម្រកនៃស្តេចកណ្តុរសេ។ ស្តេចកណ្តុរឃើញហើយ ក៏ចេញទៅជួយកាត់ផ្តាច់ខ្សែលប់។ រ៉ូងព្រាបក៏បានរួចជីវិតដោយសារមេរ៉ូង។ តាំងពីថ្ងៃនោះមក រ៉ូងព្រាបបានហៅមេរ៉ូងថានាយល្អរហូតមក។

(ដកស្រង់ចេញពីសៀវភៅគ្រូភាសាខ្មែរថ្នាក់ទី៣ពោះពុម្ពឆ្នាំ១៩៩៨)

ជំពូកទី១៧

អត្ថបទស្តាប់៖ ជំងឺផ្តាសាយថ្មី អេ អេច១ អ៊ិន១ (A/H1 N1)

នៅសតវត្សទី២០ ពិភពលោកធ្លាប់មានការរាតត្បាត ជាសកលនៃជំងឺផ្តាសាយបក្សីចំនួន៣លើក រួចមកហើយគឺ៖

- នៅឆ្នាំ ១៩១៨-១៩១៩ : សម្លាប់មនុស្សចំនួន ៤០-៥០លាននាក់ នៅទូទាំងពិភពលោក។
- នៅឆ្នាំ ១៩៥៧ : សម្លាប់មនុស្សចំនួន ០១លាននាក់
- នៅឆ្នាំ ១៩៦៨ : សម្លាប់មនុស្សចំនួន ០១លាននាក់

នាបច្ចុប្បន្ន មេរោគនៃជំងឺផ្តាសាយបក្សីបានរាតត្បាតឡើង ដំបូងនៅទីក្រុងហុងកុងក្នុងឆ្នាំ១៩៩៧។ អាជ្ញាធរទីក្រុងហុងកុងបានសម្លាប់មាន់ ទាជាច្រើនលានក្បាលដោយគិតថា គេអាចគ្រប់គ្រងមេរោគនេះបាន។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយជំងឺ នេះបានផ្ទុះឡើងជាថ្មីម្តងទៀតនៅក្នុងឆ្នាំ២០០៤ ក្នុងចំណោមមាន់ទានៅតាមប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍។ ជំងឺផ្តាសាយបក្សីគឺជាជំងឺបង្កឡើងដោយវីរុស H5N1 ដែលបង្កជំងឺលើសត្វបក្សីទាំងសត្វបក្សីព្រៃនិងសត្វបក្សីស្រុក។ បច្ចុប្បន្នមេរោគនេះ មានលទ្ធភាពឆ្លងទៅមនុស្សដែលបង្កឱ្យមានជំងឺធ្ងន់ធ្ងរនិងបង្កឱ្យស្លាប់។

រោគសញ្ញាមួយចំនួននៃជំងឺផ្តាសាយបក្សីដែលកើតនៅលើបក្សីមានដូចជា សំកុកមិនស៊ីចំណី ក្បាលជាំពណ៌ស្វាយ ហើមសរ ណង់ និងជើង ពិបាកដកដង្ហើម ហៀរសំបោរ រាគពីពណ៌បៃតងទៅពណ៌ស ដាមឈាមស្រទាប់ក្រោមស្បែកនិងស្រទាប់ខ្លាញ់ពោះ។ រយៈពេលសំងំជំងឺមានរហូតដល់២១ថ្ងៃ។

មនុស្សភាគច្រើនឆ្លងជំងឺផ្តាសាយបក្សីតាមរយៈ ការប៉ះពាល់ផ្ទាល់ជាមួយមេរោគជំងឺផ្តាសាយបក្សីដែលនៅក្នុងច្រមុះ ទឹកមាត់ ឈាម និងលាមករបស់សត្វបក្សី ដែលឈឺឬងាប់ហើយចូលមកក្នុងខ្លួនមនុស្សតាមរយៈផ្លូវដង្ហើម មាត់ច្រមុះ ភ្នែក និងការទទួលទានអាហារសាច់សត្វស្លាបព្រៃ ឬស្រុកដែលចម្អិនមិនបានឆ្អិនល្អ។ ក្រោយពីបានទទួលមេរោគផ្តាសាយបក្សីក្នុងចន្លោះពី១ទៅ៧ថ្ងៃអ្នកជំងឺនឹងមានអាការៈស្រដៀងនឹងជំងឺផ្តាសាយធម្មតាដែរ គឺមានគ្រុនក្តៅខ្លាំង ឈឺក្បាល រួយដៃជើង អស់កម្លាំង ឈឺក ក្អក ហៀរសំបោរ ដកដង្ហើមថប់ៗ។

ដើម្បីបង្ការជំងឺនេះ យើងត្រូវរាយការណ៍ដល់អាជ្ញាធរភូមិជាបន្ទាន់ ប្រសិនបើ ឃើញមានសត្វបក្សីងាប់ខុសពីធម្មតានៅក្នុងភូមិ។ មិនត្រូវរើសយកមាន់ ឬទា ដែលងាប់ដោយយកថាហេតុនៅក្នុងភូមិមកធ្វើជាអាហារនោះទេ។ មិនត្រូវឱ្យកុមារប៉ះពាល់ មាន់ ទា ឬសត្វស្លាបផ្សេងៗឡើយជាពិសេសសត្វស្លាបដែលឈឺ ឬងាប់។ ត្រូវឧស្សាហ៍លាងដៃនិងសម្អាតខ្លួនប្រាណឱ្យបានញឹកញាប់។

បច្ចុប្បន្ននេះ មេរោគផ្តាសាយបក្សីមិនទាន់បំប្លែងខ្លួនវានិងមានលទ្ធភាពចម្លងពីមនុស្សទៅមនុស្សនៅឡើយ។ ប៉ុន្តែប្រសិនបើវាមានលទ្ធភាពចម្លងពីមនុស្សទៅមនុស្សនោះ វានឹងអាចឆ្លងរីករាលដាលជុំវិញពិភពលោក ហើយមនុស្សមួយចំនួននឹងស្លាប់ដោយជំងឺនេះ ការឆ្លងរាលដាលពីមនុស្សទៅមនុស្សនៃមេរោគផ្តាសាយបក្សី ជុំវិញពិភពលោកនេះត្រូវបានគេហៅថា ការឆ្លងរាលដាលជាសកល។ ពេលជំងឺកំពុងរាលដាល អង្គការសុខភាពពិភពលោក បានធ្វើសេចក្តីណែនាំមួយចំនួនដូចជា ស្នាក់នៅតែក្នុងផ្ទះចៀសវាងនៅកន្លែងដែលអ៊ូអរ និងចាប់ដៃគ្នា មិនទៅជិតអ្នកក្អក ឬកណ្តាស់ត្រូវពាក់ម៉ាស់ការពារ លាងសម្អាតដៃឱ្យបានស្អាតជានិច្ច រាយការណ៍ជាបន្ទាន់អំពីស្ថានភាពរាតត្បាតជំងឺនិងអ្នកស្លាប់ចៀសវាងទៅសួរសុខទុក្ខអ្នកជំងឺផ្តាសាយ។

(ដកស្រង់ពីសៀវភៅបង្កើនការយល់ដឹង និងវិធានការបង្ការជំងឺផ្តាសាយបក្សីសម្រាប់មធ្យមសិក្សារបស់នាយកដ្ឋានសុខភាពសិក្សា បោះពុម្ពឆ្នាំ ២០០៧)

ជំពូកទី១៨

អត្ថបទស្តាប់៖ មេសូត្យ ៖ សម្រស់បរិស្ថាន (បទពាក្យ៧)

រុក្ខជាតិព្រៃភ្នំល្អអនេក ផ្ទាំងថ្មល្អប្លែករាយជុំជិត
អមដោយបុប្ផារីកប្រណិត ទឹកហូរប្រកិតប្រដេញគ្នា។
បក្សាបក្សីស្រែកអឺងកង ឆ្ងាត់ឆ្ងែលត្រសងពេញព្រឹក្សា
ហិចហោះបោលលេងតាមរុក្ខា ដោយក្តីស្នេហាតាមគូវា។
រីហ្វូងមច្ឆានៅក្នុងទឹក ច្រើនក្រៃសន្ធឹកពេញគង្គា
ហែបហែលទៅមកប្រទាក់គ្នា នោះប្រាកដជារកចំណី។
ឯខ្យល់អាកាសសែនបរិសុទ្ធ ស្រូបហើយបានសុខគ្មានគិតអ្វី
កើតក្តីសុខស្រួលពុំមានភ័យ រស់ក្នុងលោកីយ៍យ៉ាងអស្ចារ្យ។
ទិដ្ឋភាពទាំងនេះល្អពេកក្រៃ ញុំាងចិត្តភក្តីសែនស្នេហា
ទឹកដីមាតុភូមិស្រស់សង្ហា គ្រប់ៗអាត្មាតែងចង់បាន។
ទាំងអស់នេះហើយជាបរិស្ថាន កុមារគ្រប់ប្រាណត្រូវរក្សា
ខិតខំការពារទាំងអស់គ្នា នេះហើយគឺជាធន្ធៈយើង។

(ដកស្រង់ចេញពីឯកសារណែនាំគ្រូស្តីពីការអប់រំបរិស្ថានកម្រិតបឋមបោះពុម្ពឆ្នាំ២០០៥)

ជំពូកទី១៩

អត្ថបទស្តាប់៖ មេសូត្រ ៖ ការពារប្រភពទឹក (បទពាក្យប្រាំពីរ)

ទឹកជាភាវៈដែលចាំបាច់ តែងជួយសម្រេចរាល់កិច្ចការ
ដូចជាធ្វើស្រែនិងចម្ការ ចម្អិនអាហារនិងចំណី។
ទឹកមានសារៈជួយស្រោចស្រព ដំណាំផងសព្វគ្រប់ទិសទី
ទទួលបានផលយ៉ាងមូលមីរ ដល់យើងជាទីគួរីករាយ។
ការដឹកជញ្ជូនដែលនាំទៅ ដល់គ្រប់លំនៅទោះជិតឆ្ងាយ
សត្វរស់ក្នុងទឹកដោយសប្បាយ រស់នៅរីករាយជាប្រក្រតី។
ទឹកមានប្រយោជន៍ដល់យើងខ្លាំង តែយើងកុំភ្លាំងភ្លេចស្មារតី
មិនបានគិតពីគ្រោះថ្នាក់អី ទឹកអាចផ្តល់ភ័យដល់យើងបាន។
បើទឹកកខ្វក់មានជាតិពុល យើងគិតទៅដល់ក្តីវិនាន
មនុស្សរុក្ខជាតិនោះនឹងបាន ទទួលមិនខាននូវគ្រោះថ្នាក់។
បើទឹកច្រើនហួស ឬរីងស្ងួត សុទ្ធតែអំនួតបំផ្លាញជាក់
មនុស្ស សត្វ សង្គម វណ្ណៈ ឱ្យខ្វាត់ខ្វាយធ្លាក់ពីពសុធា។
យើងជាកូនខ្មែរត្រូវគិតយល់ ចំពោះទៅដល់កិច្ចការងារ
រាល់ប្រភពទឹកដែលស្រស់ថ្លា តែងត្រូវការពារជាពន្លឹក។
កុំចាក់សំរាមកាកសំណល់ រឹងរាវទៅដល់ប្រភពទឹក
គីមីថ្នាំពុលមានសន្ធឹក ប្រើមិនបាននឹកជ្រាបក្នុងដី។

(ដកស្រង់ចេញពីឯកសារណែនាំគ្រូស្តីពីការអប់រំបរិស្ថានកម្រិតបឋមបោះពុម្ពឆ្នាំ២០០៥)

ជំពូកទី២០

អត្ថបទស្តាប់ ៖ ត្រូវការពារសត្វព្រៃ

សត្វព្រៃជាធនធានធម្មជាតិមួយ ក្នុងចំណោមធនធានធម្មជាតិសំខាន់ៗ របស់ប្រទេសកម្ពុជា។ ដោយសារលក្ខណៈសណ្ឋានដី អាកាសធាតុមានអំណោយផល ទើបបង្កឱ្យប្រទេសយើងសម្បូរព្រៃឈើដែលជាមូលដ្ឋានទ្រទ្រង់ដល់ការរស់រានៃសត្វព្រៃ។ គេប្រទះឃើញសត្វព្រៃជាច្រើនប្រភេទរស់នៅក្នុងព្រៃតាមតំបន់ខុសៗគ្នា។

គេប្រទះឃើញសត្វព្រៃមួយចំនួនធំដូចជា ដំរី ក្តាន់ ទន្សោង គោព្រៃ ក្របីព្រៃ រមាំង ខ្លឹង ខ្លាឃ្មុំ ខ្លាធំ ខ្លារខិន ប្រើស ឈ្លូស ជ្រូកព្រៃ ឆ្កែព្រៃ... រស់នៅជាហ្វូងៗ នៅភូមិភាគឦសានតំបន់ខ្ពង់រាបខាងជើងនិងជួរភ្នំក្រវាញ។ នៅរដូវប្រាំង សត្វទាំងអស់នេះតែងប្រមូលផ្តុំជាហ្វូងធំៗស្វែងរកអាហារតាមចង្កេះភ្នំ ជើងភ្នំ និងរហូតដល់ទំនាបកណ្តាលតាមមាត់បឹង ស្ទឹងទៀតផង។ នៅរដូវវស្សា សត្វទាំងនោះនាំគ្នារស់នៅតំបន់ខ្ពស់វិញ ដើម្បីគេចពីទឹកជំនន់។ ឯបក្សាបក្សីនៅតំបន់ទាំងនេះសម្បូរដោយក្លាន មាន់ព្រៃ ខ្លែងស្រោក ទីទុយ កុក ត្មាត លលកខ្មោច -ល-។

តំបន់ទំនាបនៅប្រទេសកម្ពុជា សម្បូរដោយរុក្ខជាតិព្រិចតូចៗ ជាព្រៃលិចទឹកដែលជាអំណោយផលដល់សត្វទាំងឡាយរស់នៅ។ តំបន់ជុំវិញទន្លេសាប គេប្រទះឃើញពពួកឧរង្គសត្វ ឋនិកសត្វ ដូចជាក្រពើ ក្រពា ទន្សង កន្ធាយ អណ្តើក ពង្រូល ពស់ និងពពួកពានរ ទន្សាយ ប្រើស ជ្រូកព្រៃ ឆ្កែព្រៃ រស់នៅជាហ្វូងៗ ទាំងក្រុមៗ។ បក្សាបក្សីមានមាន់ព្រៃរស់នៅតាមព្រៃរនាមតាមមាត់បឹង ពិសេសមាត់បឹងទន្លេសាប ដែលជាកន្លែងសម្បូរទៅដោយចំណីអាហារជាងគេ។

ដើម្បីការពារសត្វព្រៃទាំងនោះឱ្យបានគង់វង្ស យើងត្រូវចូលរួមដាំដើមឈើនិងឈប់បរបាញ់សត្វខុសច្បាប់។

(ដកស្រង់ចេញពីសៀវភៅភាសាខ្មែរថ្នាក់ទី៧បោះពុម្ពឆ្នាំ១៩៩៦)

ផ្នែកទី៣
លំនាំនៃការបង្រៀន

សេចក្តីណែនាំ

ផ្អែកតាមលទ្ធផលសិក្សារបស់សិស្សប៉ុន្មានឆ្នាំកន្លងមកនេះ យើងឃើញថាសិស្សបឋមសិក្សាមានមូលដ្ឋាននៃការអាននិងសរសេរនៅមានកម្រិតទាបគួរឱ្យបារម្ភ។ ដើម្បីពង្រឹងគុណភាពនៃការអាននិងសរសេរឱ្យកាន់តែប្រសើរ គណៈកម្មការបានធ្វើការសម្របសម្រួល វិធីសាស្ត្រនិងកែលម្អឯកសារបង្រៀនភាសាខ្មែរថ្នាក់ទី៣ថ្នាក់ទី៤ របស់ក្រសួងអប់រំយុវជននិងកីឡា មកជាសៀវភៅពន្លឿនការសិក្សាថ្នាក់ឆ្នាំទី២ ដើម្បីឱ្យសិស្សក្នុងកម្រិតនេះ អាចអានភាសាខ្មែរឆាប់ចេះក្នុងទិសដៅឆ្លើយតបទៅនឹងកម្មវិធីពន្លឿនការសិក្សា។ សម្រាប់កម្រិតសិក្សាថ្នាក់ឆ្នាំទី២នេះត្រូវមានបំណិនមូលដ្ឋានរឹងមាំផ្នែកភាសាខ្មែរពោលគឺ៖ ចេះអានសរសេរបានច្បាស់លាស់។

សៀវភៅសម្រាប់បង្រៀនភាសាខ្មែរកម្រិតសិក្សាថ្នាក់ឆ្នាំទី២ នេះរៀបរៀងឡើង ដើម្បីសម្រួលដល់ការរៀននិងបង្រៀនភាសាខ្មែរដោយដកស្រង់ខ្លឹមសារមួយចំនួននិងយកលំនាំសៀវភៅថ្នាក់ទី៣និងថ្នាក់ទី៤ របស់ក្រសួងអប់រំយុវជន និងកីឡាមកធ្វើបច្ចុប្បន្នភាពឱ្យស្របតាមបរិបទថ្មីៗ។ សៀវភៅនេះចាប់ផ្តើមពីការរៀន**អំណាន មេសូត្រ និយាយ ស្តាប់ សំណេរ វេយ្យាករណ៍ បំណិន**ដើម្បីឱ្យសិស្សមានបំណិនរឹងមាំក្នុងការអាននិងសរសេរ។

ដើម្បីជាជំនួយដល់ការប្រើប្រាស់សៀវភៅពន្លឿនការសិក្សានេះបានត្រឹមត្រូវ គណៈកម្មការបានរៀបចំសេចក្តីណែនាំដោយផ្តោតលើ៖

១. ការប្រើប្រាស់សម្ភារៈ

២. លំនាំបង្រៀន

I. ការប្រើប្រាស់សម្ភារៈ

ក្នុងការបង្រៀនលោកគ្រូអ្នកគ្រូគប្បីប្រើប្រាស់សម្ភារឧបទេស ពីព្រោះវាជាមធ្យោបាយមួយទាក់ទាញទឹកចិត្តសិស្សឱ្យចូលចិត្តរៀនមានការចងចាំតាមរយៈការលើកបង្ហាញនិងចង្អុល ធ្វើឱ្យសិស្សបានសប្បាយហើយថែមទាំងយល់មេរៀនបានច្បាស់លាស់ (យល់ន័យពាក្យ ល្បះ និងអត្ថបទ) ទៀតផង។

សម្ភារៈដែលចាំបាច់បំផុតសម្រាប់បង្រៀនអាននិងសរសេរគឺ មានរូបភាពនិងវត្ថុដាក់ស្តែងផ្សេងទៀតទៅតាមពាក្យ ល្បះ ឬអត្ថបទដែលត្រូវបង្រៀន។

II. លំនាំបង្រៀន

១. បំណិន

សកម្មភាពទី១៖ ទំនាក់ទំនង

- សរសេរចំណងជើងមេរៀនដាក់លើក្តារខៀន
- សួរសំណួរបំផុសទាក់ទងនឹងចំណងជើង

សកម្មភាពទី២៖ ដាក់បញ្ហា

- ដាក់បញ្ហាផ្ទាល់មាត់ទាក់ទងនឹងបញ្ញត្តិ
- សួរឡើងវិញពីបញ្ហា
- សរសេរ ឬបិទបញ្ហាលើក្តារខៀនរួចឱ្យសិស្សអាន
- សួរកវត្ថុបំណងនៃបញ្ហា តើបញ្ហានេះចង់ឱ្យប្អូនធ្វើអ្វី?
- កែតម្រូវចម្លើយរបស់សិស្ស

សកម្មភាពទី៣៖ ការប៉ាន់ស្មាន

- ឱ្យសិស្សប៉ាន់ស្មាន
- សរសេរចម្លើយសិស្សដាក់លើក្តារខៀននៅជ្រុងម្ខាង

- សួរបញ្ជាក់ពីចម្លើយរបស់សិស្ស តើប្អូនដឹងថាការប៉ាន់ស្មានរបស់ប្អូនពិតជាត្រឹមត្រូវឬទេ? បើមិនទាន់ដឹងច្បាស់ទេ តើអ្នកត្រូវធ្វើដូចម្តេចទៀត? (ពិភាក្សាក្រុម)

សកម្មភាពទី៤៖ ពិភាក្សាក្រុម

- បិទឧទាហរណ៍លើក្តារខៀន
- ឱ្យសិស្សស្វែងយល់ន័យពាក្យទាំងនោះ បើសិស្សមិនយល់គ្រូត្រូវពន្យល់ពាក្យនោះ
- ណែនាំរបៀបពិភាក្សា៖ តាមរយៈឧទាហរណ៍លើក្តារខៀនប្អូនត្រូវអាន សង្កេត តក់ត្រាទាញជាបញ្ញត្តិ
- ឱ្យសិស្សនិយាយការណែនាំពិភាក្សាឡើងវិញឱ្យបាន២ ឬ៣នាក់
- ចែកក្រុមពិភាក្សាដោយមានប្រធានក្រុម លេខាកត់ត្រា និងអ្នកបកស្រាយ
- ឱ្យសិស្សឡើងយកសម្ភារៈ (ហ្វឺត ក្រដាស...)
- កំណត់រយៈពេល
- ដើរពិនិត្យតាមក្រុមដើម្បីណែនាំបន្ថែមចំពោះការខ្វះចន្លោះរបស់សិស្សពេលពិភាក្សាក្រុម

សកម្មភាពទី៥៖ របាយការណ៍ក្រុម

- ឱ្យតំណាងក្រុមនីមួយៗយកកិច្ចការរបស់ខ្លួនមកបិទលើក្តារខៀន
- ឱ្យតំណាងក្រុមឡើងបកស្រាយ
- ឱ្យសិស្សនៃក្រុមដទៃទៀតស្តាប់ការបកស្រាយរបស់ក្រុមហើយបើមានចំណុចណាដែលមិនច្បាស់ក្រុមនោះត្រូវសួរ រីឯក្រុមបកស្រាយត្រូវឆ្លើយ។ បើសិនជាមិនអាចឆ្លើយបាននោះ សិស្សឯទៀត ឬគ្រូត្រូវចូលរួមបកស្រាយទាល់តែបានច្បាស់
- សរសេរការបូកសរុបលើក្តារខៀន

សកម្មភាពទី៦៖ ផ្ទៀងផ្ទាត់ការប៉ាន់ស្មាន

- ដឹកនាំសិស្សផ្ទៀងផ្ទាត់ការប៉ាន់ស្មាន
- លើកសរសើរសិស្សដែលប៉ាន់ស្មានបានត្រឹមត្រូវ

សកម្មភាពទី៧៖ កសាងបញ្ញត្តិ

- ចោទជាសំណួរដើម្បីបង្កើតបញ្ញត្តិ
- គ្រូសំយោគនិងកែលម្អចម្លើយរបស់សិស្ស (ករណីដែលការបូកសរុបមានខ្លឹមសារអាចទទួលយកបានហើយគ្រូអាចយកជាបញ្ញត្តិតែម្តង)
- ឱ្យសិស្សអានបញ្ញត្តិ

២. បង្រៀនអំណាន

សកម្មភាពទី១៖ បំផុសចំណងជើង

- គ្រូសួរសំណួរបំផុសមួយចំនួន ដើម្បីឱ្យសិស្សនិយាយអំពីអ្វីដែលគេធ្លាប់ដឹងទាក់ទងនឹងមេរៀនថ្មី
- បង្ហាញរូបភាពក្នុងសៀវភៅសិស្ស រួចសួរសំណួរបំផុសរកចំណងជើង
- សរសេរចំណងជើងដាក់នៅក្តារខៀន រួចឱ្យសិស្សអាន

សកម្មភាពទី២៖ ប៉ាន់ស្មានខ្លឹមសារ

- ឱ្យសិស្សប៉ាន់ស្មានខ្លឹមសារមេរៀនតាមរយៈរូបភាពនិងចំណងជើង
- កត់ចម្លើយប៉ាន់ស្មានលើជ្រុងម្ខាងនៃក្តារខៀន។

សកម្មភាពទី៣៖ អំណានស្ងាត់លើកទី១

- ឱ្យសិស្សអានអត្ថបទដោយស្ងៀមស្ងាត់ដើម្បីរកពាក្យពិបាកអាននិងពិបាកយល់ន័យ

- ឱ្យសិស្សសរសេរពាក្យទាំងនោះនៅលើក្តារខៀន (បើមានអត្ថបទនៅលើក្តារខៀនឬបណ្ណអត្ថបទគ្រូគប្បីឱ្យសិស្សឡើងគូសពីក្រោមពាក្យទាំងនោះ)។

សកម្មភាពទី៤៖ ការអានពាក្យពិបាកនិងពន្យល់ពាក្យ

- ឱ្យសិស្សដែលចេះអាន អានពាក្យពិបាកឱ្យសិស្សឯទៀតស្តាប់និងថាតាម (បើសិស្សទាំងអស់គ្នាមិនចេះអានពាក្យណាមួយគ្រូដឹកនាំសិស្សអាន)
- ហៅសិស្សខ្សោយឱ្យអានពាក្យពិបាកឡើងវិញ
- ដឹកនាំសិស្សឱ្យយល់ន័យពាក្យពិបាកដោយ ប្រើរូបភាព កាយវិការ លើកឧទាហរណ៍ ប្រៀបធ្រៀប សំណួរបំផុស ឬប្រើបទានុក្រម។

សកម្មភាពទី៥៖ អំណានឮ

- ឱ្យសិស្សអានសំណួរក្នុងសៀវភៅដោយប្រាប់ថា ពួកគេនឹងឆ្លើយសំណួរទាំងនេះនៅពេលអានអត្ថបទរួច
- ឱ្យសិស្សពូកែម្នាក់អានអត្ថបទជាគំរូ ឬគ្រូអានជាគំរូដោយឱ្យសិស្សទាំងអស់ស្តាប់
- ឱ្យសិស្សចូលក្រុមអានបណ្តាក់ក្នុងក្រុមដើម្បីជួយសិស្សខ្សោយ
- ឱ្យសិស្សអានបណ្តាក់ជាបុគ្គលនិងជាក្រុមតូចៗ
- ដើរសម្របសម្រួលការងារក្រុម
- លើកសរសើរក្រុមដែលអានបានល្អ

សកម្មភាពទី៦៖ អំណានស្ងាត់លើកទី២

- ឱ្យសិស្សម្នាក់ៗអានអត្ថបទដោយស្ងៀមស្ងាត់ ដើម្បីស្វែងយល់ខ្លឹមសាររបស់អត្ថបទ
- ឱ្យសិស្សឆ្លើយសំណួរម្តងមួយៗបើសិស្សមិនអាចឆ្លើយនឹងសំណួរណាមួយបានត្រូវឱ្យសិស្សអានត្រង់វគ្គដែលទាក់ទងនឹងសំណួរនោះឡើងវិញ ដើម្បីយល់និងអាចឆ្លើយបាន
- សម្របសម្រួលចម្លើយសិស្ស

សកម្មភាពទី៧៖ ផ្ទៀងផ្ទាត់ចម្លើយប៉ាន់ស្មាន

- ដឹកនាំសិស្សផ្ទៀងផ្ទាត់ចម្លើយប៉ាន់ស្មានទៅនឹងខ្លឹមសារអត្ថបទ។
- លើកសរសើរសិស្សដែលប៉ាន់ស្មានបានត្រឹមត្រូវ

សកម្មភាពទី៨៖ សំយោគខ្លឹមសារ

- សួរសំណួរក្តោបខ្លឹមសារអត្ថបទ ឬបិទសំណួរលើក្តាខៀន
- ឱ្យសិស្សផ្តល់ចម្លើយជាបុគ្គល ឬជាក្រុម (កំណត់រយៈពេល)
- សំយោគខ្លឹមសាររួចសរសេរលើក្តារខៀនក្រោមពន្យល់ពាក្យ
- ឱ្យសិស្សអានខ្លឹមសារសរុប

៣. បង្រៀនមេស្រួត

សកម្មភាពទី១៖ បំផុសចំណាងជើង

- គ្រូសួរសំណួរបំផុសមួយចំនួន ដើម្បីឱ្យសិស្សនិយាយអំពីអ្វីដែលគេធ្លាប់ដឹងទាក់ទងនឹងមេរៀនថ្មី
- បង្ហាញរូបភាពក្នុងសៀវភៅសិស្ស រួចសួរសំណួរបំផុសរកចំណាងជើង
- សរសេរចំណាងជើងដាក់នៅក្តារខៀន រួចឱ្យសិស្សអាន

សកម្មភាពទី២៖ ប៉ាន់ស្មានខ្លឹមសារ

- ឱ្យសិស្សប៉ាន់ស្មានខ្លឹមសារមេរៀនតាមរយៈរូបភាពនិងចំណងជើង
- កត់ចម្លើយប៉ាន់ស្មានលើជ្រុងម្ខាងនៃក្តារខៀន។

សកម្មភាពទី៣៖ អំណានស្ងាត់លើកទី១

- ឱ្យសិស្សសូត្រមេសូត្រដោយស្ងៀមស្ងាត់ ដើម្បីរកពាក្យពិបាកអាននិងពិបាកយល់ន័យ
- ឱ្យសិស្សសរសេរពាក្យទាំងនោះនៅលើក្តារខៀន (បើមានអត្ថបទនៅលើក្តារខៀន ឬបំណ្ណអត្ថបទគ្រូគប្បីឱ្យសិស្សឡើងគូសពីក្រោមពាក្យទាំងនោះ)។

សកម្មភាពទី៤៖ ការអានពាក្យពិបាកនិងពន្យល់ពាក្យ

- ឱ្យសិស្សដែលចេះអានអានពាក្យពិបាកឱ្យសិស្សឯទៀតស្តាប់និងថាតាម (បើសិស្សទាំងអស់គ្នាមិនចេះអានពាក្យណាមួយគ្រូដឹកនាំសិស្សអាន)
- ហៅសិស្សខ្សោយឱ្យអានពាក្យពិបាកឡើងវិញ
- ដឹកនាំសិស្សឱ្យយល់ន័យពាក្យពិបាកដោយ ប្រើរូបភាព កាយវិការ លើកឧទាហរណ៍ ប្រៀបធ្យៀប សំណួរបំផុស ឬប្រើបទានុក្រម។

សកម្មភាពទី៥៖ អំណានឮ

- ឱ្យសិស្សអានសំណួរក្នុងសៀវភៅដោយប្រាប់ថា ពួកគេនឹងឆ្លើយសំណួរទាំងនេះនៅពេលអានអត្ថបទរួច
- ឱ្យសិស្សពូកែម្នាក់សូត្រមេសូត្រជាគំរូ ឬគ្រូសូត្រជាគំរូដោយឱ្យសិស្សទាំងអស់សូត្រតាមខ្សឹបៗ
- ឱ្យសិស្សចូលក្រុមសូត្របណ្តាក់ក្នុងក្រុម ដើម្បីជួយសិស្សខ្សោយ
- ឱ្យសិស្សសូត្របណ្តាក់ជាបុគ្គលនិងជាក្រុមតូចៗ
- ដើរសម្របសម្រួលការងារក្រុម
- លើកសរសើរក្រុមដែលសូត្របានល្អ

សកម្មភាពទី៦៖ អំណានស្ងាត់លើកទី២

- ឱ្យសិស្សម្នាក់ៗអាន ឬសូត្រអត្ថបទកំណាព្យដោយស្ងៀមស្ងាត់ ដើម្បីស្វែងយល់ខ្លឹមសាររបស់អត្ថបទ
- ឱ្យសិស្សឆ្លើយសំណួរម្តងមួយៗបើសិស្សមិនអាចឆ្លើយនឹងសំណួរណាមួយបានត្រូវឱ្យសិស្សអានត្រង់វគ្គដែលទាក់ទងនឹងសំណួរនោះឡើងវិញ ដើម្បីយល់និងអាចឆ្លើយបាន។
- សម្របសម្រួលចម្លើយសិស្ស

សកម្មភាពទី៧៖ ផ្ទៀងផ្ទាត់ចម្លើយប៉ាន់ស្មាន

- ដឹកនាំសិស្សផ្ទៀងផ្ទាត់ចម្លើយប៉ាន់ស្មានទៅនឹងខ្លឹមសារអត្ថបទ។
- លើកសរសើរសិស្សដែលប៉ាន់ស្មានបានត្រឹមត្រូវ

សកម្មភាពទី៨៖ សំយោគខ្លឹមសារ

- សួរសំណួរក្តោបខ្លឹមសារអត្ថបទ ឬបិទសំណួរលើក្តារខៀន
- ឱ្យសិស្សផ្តល់ចម្លើយជាបុគ្គល ឬជាក្រុម (កំណត់រយៈពេល)
- សំយោគខ្លឹមសាររួចសរសេរលើក្តារខៀនក្រោមពន្យល់ពាក្យ
- ឱ្យសិស្សអានខ្លឹមសារសរុប

៤. បង្រៀនស្តាប់

សកម្មភាពទី១៖ បំផុសចំណងជើង

- សួរសំណួរបំផុសមួយចំនួន ដើម្បីឱ្យសិស្សនិយាយអំពីអ្វីដែលគេធ្លាប់ដឹងទាក់ទងនឹងមេរៀនថ្មី
- បង្ហាញរូបភាពក្នុងសៀវភៅសិស្ស រួចសួរសំណួរបំផុសរកចំណងជើង
- សរសេរចំណងជើងដាក់នៅក្តារខៀន រួចឱ្យសិស្សអាន

សកម្មភាពទី២៖ ប៉ាន់ស្មានខ្លឹមសារ

- ឱ្យសិស្សប៉ាន់ស្មានខ្លឹមសាររឿងតាមរយៈរូបភាពនិងចំណងជើង
- កត់ចម្លើយប៉ាន់ស្មានលើជ្រុងម្ខាងនៃក្តារខៀន

សកម្មភាពទី៣៖ និទានរឿង

- ឱ្យសិស្សអានសំណួរដោយដើម្បីត្រៀមឆ្លើយនៅពេលគ្រូនិទានចប់
- និទានរឿង១ទៅ២ចប់ឱ្យសិស្សស្តាប់ព្រមទាំងបង្ហាញរូបភាពម្តងមួយផ្ទាំងៗតាមសាច់រឿង
- សរសេរពាក្យពិបាកមួយចំនួននៅក្នុងអត្ថបទដែលគ្រូគិតថាសិស្សមិនទាន់យល់ន័យ
- ដឹកនាំសិស្សអាននិងពន្យល់ន័យដោយប្រើរូបភាព រកន័យដូច រកន័យផ្ទុយ សំណួរបំផុស...

សកម្មភាពទី៤៖ សួរសំណួរ

- ឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្ស បើសិស្សឆ្លើយសំណួរណាមួយមិនបានគ្រូត្រូវនិទានរឿងត្រង់ផ្នែកនោះឡើងវិញ ដើម្បីឱ្យសិស្សស្តាប់ឡើងវិញ និងអាចឆ្លើយបាន
- សួរសំណួរថ្មីបន្ថែមផ្សារភ្ជាប់បទពិសោធដែលសិស្សរៀនរួចទៅនឹងបទពិសោធជាក់ស្តែង ដែលសិស្សជួបប្រទះក្នុងការរស់នៅ។

សកម្មភាពទី៥៖ ផ្ទៀងផ្ទាត់ចម្លើយប៉ាន់ស្មាន

- ដឹកនាំសិស្សផ្ទៀងផ្ទាត់ចម្លើយប៉ាន់ស្មានទៅនឹងខ្លឹមសាររឿង
- លើកសរសើរសិស្សដែលប៉ាន់ស្មានបានត្រឹមត្រូវ

សកម្មភាពទី៦៖ សំយោគខ្លឹមសារ

- សួរសំណួរក្តោបខ្លឹមសាររឿង ឬបិទសំណួរលើក្តាខៀន
- ឱ្យសិស្សផ្តល់ចម្លើយជាបុគ្គល ឬជាក្រុម (កំណត់រយៈពេល)
- សំយោគខ្លឹមសាររួចសរសេរលើក្តារខៀនក្រោមពន្យល់ពាក្យ
- ឱ្យសិស្សអានខ្លឹមសារសរុប

៥. បង្រៀនឥឡូយ

សកម្មភាពទី១៖ ទំនាក់ទំនងមេរៀន

- សួរសំណួរបំផុស ដើម្បីស្ទាបស្ទង់ចំណេះដឹងសិស្សដែលមានស្រាប់ដោយឱ្យសិស្សនិយាយ ឆ្លើយ ឬបង្ហាញពីអ្វីដែលពួកគេធ្លាប់ដឹងរួចមកហើយទាក់ទងនឹងមេរៀនថ្មី
- សរសេរចំណងជើងមេរៀនលើក្តារខៀន
- សួរសំណួរបំផុសទាក់ទងនឹងចំណងជើង
- ឱ្យសិស្សប៉ាន់ស្មានខ្លឹមសារតាមរយៈចំណងជើងនិងរូបភាព
- សរសេរចម្លើយប៉ាន់ស្មាននៅក្តារខៀន

សកម្មភាពទី២៖ សន្ទនាលើកទី១

- ឱ្យសិស្សអានសំណួរក្នុងសៀវភៅសិស្ស
- ជ្រើសរើសសិស្សតាមចំនួនតួអង្គមកដើរតួ ដោយឱ្យសិស្សទាំងនោះដើរតួជាតួអង្គតាមខ្លឹមសារនៃបទសន្ទនា និងស្វែងយល់អត្ថបទគំរូ។ ឯសិស្សទៀតតាមដានស្តាប់ទាំងខ្លឹមសារនិងការលើកដាក់សំឡេង។
- សួរសំណួរលម្អិតអត្ថបទ (សំណួរក្នុងសៀវភៅសិស្ស) ដើម្បីស្ទាបស្ទង់ការយល់ដឹងរបស់សិស្ស
- សួរសំណួរទាក់ទងនឹងសំនួន ឬពាក្យចាំបាច់ដែលត្រូវសន្ទនា
- ផ្ទៀងផ្ទាត់ចម្លើយប៉ាន់ស្មានទៅនឹងខ្លឹមសារអត្ថបទ។

សកម្មភាពទី៣៖ សន្ធនាលើកទី២

- ចែកសិស្សជាក្រុមតូចៗ (សមាជិកក្រុមអាចប្រែប្រួលទៅតាមប្រធានបទ) រួចឱ្យក្រុមនីមួយៗហ្វឹកហាត់សន្ធនាតាមអត្ថបទគំរូក្នុងសៀវភៅដោយចាត់គ្នាពីរ ឬបីនាក់ម្តង(តាមខ្លឹមសារនៃបទសន្ធនា) រហូតចេះចាំស្ទាត់គ្រប់ៗគ្នាដោយជួយគ្នានៅក្នុងក្រុម
- ដើរសម្របសម្រួលនិងកែលម្អតាមក្រុម។

សកម្មភាពទី៣៖ សន្ធនាលើកទី៣(ល្បែងដើរតួ)

- ឱ្យសិស្សរៀបចំការសន្ធនាដោយប្រើប្រាស់ប្រយោគផ្ទាល់ខ្លួនតាមក្រុម
- ឱ្យសិស្សក្នុងក្រុមនីមួយៗសាកល្បងសន្ធនានៅនឹងកន្លែងរៀងៗខ្លួន
- បិទ ឬគូសតារាងវាយតម្លៃលើក្តារខៀនរួចពន្យល់ពីរបៀបវាយតម្លៃ

ល.រ.	លក្ខខណ្ឌនៃការវាយតម្លៃ	ខ្សោយ	មធ្យម	ល្អ	ល្អណាស់
១	កាយវិការ				
២	ការលើកដាក់សំឡេង				
៣	ខ្លឹមសារ				
៤	ការបញ្ចេញសំឡេង				

- ឱ្យសិស្សឯទៀតគូសតារាងក្នុងសៀវភៅរបស់ខ្លួន
- ឱ្យក្រុមនីមួយៗឡើងសន្ធនាដោយមានគ្នា (តាមខ្លឹមសារនៃបទសន្ធនា)
- ឱ្យសិស្សទាំងអស់ចូលរួមកែលម្អដោយប្រើតារាងវាយតម្លៃខាងលើ នៅពេលក្រុមនីមួយៗសន្ធនាចប់
- ឱ្យសិស្សជ្រើសរើសក្រុមដែលសម្តែងបានល្អជាងគេ
- លើកសរសើរក្រុមដែលសម្តែងបានល្អ រួចឱ្យសិស្សទះដៃអបអរសាទរ

សម្គាល់៖ តារាងលក្ខខណ្ឌនៃការវាយតម្លៃអាចប្រែប្រួលទៅតាមខ្លឹមសារនៃប្រធានបទ។

៦. បង្រៀនវេយ្យាករណ៍

បញ្ជាក់៖ សម្រាប់ការបង្រៀនវេយ្យាករណ៍សូមយកលំនាំតាមការបង្រៀនបំណិន។

៧. បង្រៀនសំណេរ

ក. រៀបរាក្យក្នុងប្រអប់ឱ្យទៅជាឃ្លុះ

សកម្មភាពទី១៖ បង្ហាញ

- ឱ្យសិស្សបើកសៀវភៅ រួចឱ្យសិស្ស២ ឬ៣នាក់អានលំណែនាំលំហាត់ រួចពន្យល់បន្ថែមអំពីរបៀបធ្វើលំហាត់នោះ
- ឱ្យសិស្សអានពាក្យក្នុងប្រអប់ទី១
- សួរថា៖ តើពាក្យក្នុងប្រអប់នោះជាឃ្លុះស្តាប់បានឬនៅ? (សួរបញ្ជាក់ទីតាំងនៃសញ្ញាខណ្ឌ)
- ឱ្យសិស្សសាកល្បងតែងពាក្យក្នុងប្រអប់នោះជាឃ្លុះ២ ឬ៣នាក់
- សរសេរឃ្លុះទាំងនោះលើក្តារខៀន
- ឱ្យសិស្សអានឃ្លុះនីមួយៗរួចធ្វើការប្រៀបធៀប
- សួរសិស្ស៖ តើឃ្លុះទាំងអស់ ឃ្លុះណាមួយដែលមានន័យស្តាប់បានជាងគេ
- លើកសរសើរដល់សិស្សដែលតែងបានល្អត្រឹមត្រូវ

សកម្មភាពទី២៖ រៀបពាក្យក្នុងប្រអប់

- ចម្លងលំហាត់ដាក់លើក្តារខៀនរួចឱ្យសិស្ស២ ឬ៣នាក់អានឯសិស្សដទៃទៀតតាមដានស្តាប់ដោយយកចិត្តទុកដាក់។

- ណែនាំសិស្សបន្ថែមពីរបៀបធ្វើលំហាត់រៀបពាក្យក្នុងប្រអប់រួចឱ្យសិស្សនិយាយឡើងវិញពីលំហាត់។
- ឱ្យសិស្សសាកល្បងរៀប និងអានល្បះដែលរៀបហើយនោះ
- កែលម្អចំណុចខ្វះខាត

ចំណាំ៖ សម្រាប់ប្រអប់បន្ទាប់ធ្វើតាមលំនាំប្រអប់ទី១

ខ. បែបបំពេញល្បះឬតែងល្បះតាមរូបភាព

សកម្មភាពទី១៖ បង្ហាញរូបភាពឬល្បះ

- លើករូបភាពបង្ហាញឬបិទនៅលើក្តារខៀនរួចសួរ៖ តើនេះជារូបភាពអ្វី? អ្នកឃើញមានអ្វីខ្លះ? ឱ្យសិស្សអានល្បះទី១រួចសួរ៖ តើអ្នកយល់ល្បះនេះឬទេ? តើអ្នកធ្វើដូចម្តេចដើម្បីយល់ល្បះនេះ? (ចម្លើយ៖ ត្រូវបំពេញពាក្យក្នុងចន្លោះល្បះ)។ តើអ្នកបំពេញយ៉ាងដូចម្តេច? (ត្រូវអានពាក្យក្នុងប្រអប់មុននឹងបំពេញ) តើអ្នកអានដើម្បីអ្វី? ដើម្បីដឹងថាត្រូវជ្រើសរើសយកពាក្យណាមួយមកបំពេញឱ្យត្រូវន័យនៃល្បះនិងរូបភាពនីមួយៗនោះ។

សកម្មភាពទី២៖ តែង ឬបំពេញល្បះ

- ចម្លងលំហាត់ដាក់លើក្តារខៀនរួចឱ្យសិស្ស២ ឬ៣នាក់អានឯសិស្សដទៃទៀតតាមដានស្តាប់ដោយយកចិត្តទុកដាក់។
- ណែនាំសិស្សបន្ថែមពីរបៀបធ្វើលំហាត់បំពេញល្បះនឹងពាក្យ រួចឱ្យសិស្សនិយាយឡើងវិញពីលំហាត់។
- ឱ្យសិស្សសាកល្បងបំពេញ និងអានល្បះដែលបំពេញហើយនោះ
- កែលម្អចំណុចខ្វះខាត
- ឱ្យសិស្សអានលំណែនាំលំហាត់រួចគ្រូសួរ៖ តើក្នុងលំហាត់នេះចង់ឱ្យប្អូនធ្វើអ្វី? (តែងល្បះតាមរូបភាព)។ តើនេះជារូបភាពអ្វី? តើពួកគេកំពុងធ្វើអ្វី? ចូរអ្នកហាត់តែងល្បះដោយមាត់ទទេរទាក់ទងនឹងរូបភាពទី១សាកមើល។ ឱ្យសិស្សដទៃជួយកែលម្អ។

គ. បែបសំណេរកថាខណ្ឌ

សកម្មភាពទី១៖ ទំនាក់ទំនងមេរៀន

- សួរសំណួរណាដែលទាក់ទងទៅនឹងប្រធានបទដែលយកមកបង្រៀន

សកម្មភាពទី២៖ ប្រមូលគំនិត

- ឱ្យសិស្សអានប្រធានបទ អានសំណួរ សង្កេតរូបភាព
- ឱ្យសិស្សផ្តល់ព័ត៌ដែលទាក់ទងនឹងប្រធានបទ តាមរយៈសំណួរ រូបភាព ...
- សរសេរចម្លើយរបស់សិស្សជាកន្សោមពាក្យលើក្តារខៀន

សកម្មភាពទី៣៖ សំណេរព្រាង

- ឱ្យសិស្សអានឡើងវិញនូវព័ត៌មាន ឬគំនិតសំខាន់ៗដែលទាក់ទងនឹងប្រធានបទ
- ដឹកនាំសិស្សលុបព័ត៌មាន ឬគំនិតដែលមិនទាក់ទងនឹងប្រធានបទ
- ឱ្យសិស្សរៀបព័ត៌មាន ឬគំនិតទាំងនោះតាមលំដាប់លំដោយ
- ឱ្យសិស្សនិយាយពង្រីកគំនិតនីមួយៗឱ្យទៅជាល្បះពេញលេញ
- សរសេរតាមការនិយាយរបស់សិស្សលើក្តារខៀន
- ដឹកនាំសិស្សភ្ជាប់ល្បះនីមួយៗឱ្យទៅជាទម្រង់កថាខណ្ឌ

សកម្មភាពទី៤៖ កែលម្អសំណេរព្រាង

- ឱ្យសិស្សពិនិត្យសំណេរព្រាងឱ្យបានត្រឹមត្រូវលើ៖
  - លំដាប់លំដោយនៃគំនិត

- ទម្រង់ល្អះ
- អក្ខរាវិរុទ្ធ

- ដើរពិនិត្យសកម្មភាពសិស្ស

សកម្មភាពទី៥៖ សរសេរសម្រេច

- ឱ្យសិស្សសរសេរឡើងវិញដោយយកចិត្តទុកដាក់តាមសំណេរព្រាង

៨. បង្រៀនសរសេរតាមអាន

ក. សរសេរតាមអានចម្លង (១ម៉ោង)

សកម្មភាពទី១៖ បង្ហាញពាក្យ

- សរសេរ ឬបិទពាក្យមួយចំនួននៅលើក្តារខៀន

សកម្មភាពទី២៖ អានពាក្យ

- អានពាក្យម្តងមួយៗឱ្យច្បាស់ៗហើយឱ្យសិស្ស ២-៣នាក់ ឡើងចង្អុលពាក្យនីមួយៗអានតាម
- ចង្អុលពាក្យទី១ និងអានម្តងទៀត
- ឱ្យសិស្សធ្វើអក្ខរាវិញ្ញាសពាក្យនោះ រួចឱ្យសិស្សសរសេរនៅលើក្តារឆ្នូនទាំងអស់គ្នា
- ត្រួតពិនិត្យនិងឱ្យសិស្សដែលសរសេរខុសកែឱ្យត្រូវឡើងវិញ
- ចង្អុលពាក្យទី២ ទី៣ ...រហូតគ្រប់ពាក្យ ហើយធ្វើតាមលំនាំពាក្យបង្រៀនទី១ដែរ

សកម្មភាពទី៣៖ សរសេរពាក្យក្នុងសៀវភៅ

- ហៅពាក្យឆ្លាស់គ្នាឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅ
- ហៅពាក្យឡើងវិញឱ្យសិស្សផ្ទៀងផ្ទាត់
- ទុកពេលឱ្យសិស្សត្រួតពិនិត្យនិងកែកំហុស
- ឱ្យសិស្សប្តូរគ្នាកែដោយផ្ទៀងជាមួយពាក្យនៅលើក្តារខៀន
- ប្រមូលសៀវភៅសិស្សកែដាក់ពិន្ទុ

ខ. សរសេរតាមអានរៀបចំ (១ម៉ោង)

សកម្មភាពទី១៖ បង្ហាញអត្ថបទ

- ចម្លង ឬបិទពាក្យ ឃ្លា ល្អះ ឬអត្ថបទដាក់លើក្តារខៀន
- អានពាក្យពិបាក ឬពាក្យគន្លឹះ រួចឱ្យសិស្សអានតាម
- អានអត្ថបទដោយយឺតៗច្បាស់ៗ រួចឱ្យសិស្ស២ ឬ៣នាក់អានឡើងវិញ

សកម្មភាពទី២៖ អានពាក្យពិបាកក្នុងអត្ថបទ

- អានពាក្យនេះម្តងមួយៗ ឱ្យច្បាស់ៗឱ្យសិស្សចង្អុលពាក្យ និងអានតាម ២-៣នាក់
- អានពាក្យទាំងនោះដោយចង្អុលផង រួចឱ្យសិស្សធ្វើអក្ខរាវិញ្ញាសនិងឱ្យសរសេរលើក្តារឆ្នូនទាំងអស់គ្នា
- ពិនិត្យនិងឱ្យសិស្សដែលសរសេរខុសកែឱ្យបានត្រូវឡើងវិញ
- បន្តទៅពាក្យទី២ ទី៣រហូតដល់ចប់ដោយធ្វើតាមលំនាំបង្រៀនដូចពាក្យទី១

សកម្មភាពទី៣៖ សរសេរអត្ថបទដាក់ក្នុងសៀវភៅ

- លាក់អត្ថបទ រួចហៅឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅមួយឃ្លាម្តងៗ រហូតដល់ចប់
- អានអត្ថបទឡើងវិញឱ្យសិស្សស្តាប់និងផ្ទៀងឡើងវិញ
- រួចទុកពេលឱ្យសិស្សពិនិត្យ និងកែកំហុសរៀងៗខ្លួន
- ឱ្យសិស្សដូរសៀវភៅគ្នាកែតាមអត្ថបទបង្ហាញនៅលើក្តារខៀន

- ប្រមូលសៀវភៅកិច្ចការសិស្សកែដាក់ពិន្ទុ

គ. សរសេរតាមអានត្រួតពិនិត្យ (១ម៉ោង)

សកម្មភាពទី១៖ អាន

- អានពាក្យ កន្សោមពាក្យ កថាខណ្ឌ ឬអត្ថបទខ្លីៗដែលតម្រូវឱ្យសិស្សសរសេរ។
- ឱ្យសិស្សទាំងអស់ស្តាប់ ដោយអានឱ្យឮនិងច្បាស់ៗ។

សកម្មភាពទី២៖ សរសេរក្នុងសៀវភៅ

- អាន (ហៅ) ពាក្យ កន្សោមពាក្យ ឬឃ្លាខ្លីៗ បីដងឱ្យសិស្សសរសេរតាម ម្តងមួយៗ រហូតដល់ចប់
- អានឱ្យសិស្ស២នាក់ថាតាមក្រោយពីគ្រូអាន សិស្សទាំងអស់សរសេរ ដោយសិស្សម្នាក់ថាមុននឹងខ្លួនសរសេរ ហើយម្នាក់ទៀតថា ពីក្រោយបន្ទាប់ពីខ្លួនសរសេរចប់
- អានឱ្យសិស្សស្តាប់ឡើងវិញដោយយឺតៗនិងច្បាស់ៗ ដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់និងកែតម្រូវពាក្យកន្សោមពាក្យ ដែលគេសរសេរលឿនឬខុស
- ទុកពេលសមល្មមឱ្យសិស្សកែនិងបំពេញបន្ថែម
- ឱ្យសិស្សដូរសៀវភៅគ្នាកែតាមអត្ថបទបង្ហាញនៅលើក្តារខៀន
- ប្រមូលសៀវភៅកិច្ចការសិស្សកែដាក់ពិន្ទុ
  - *ចំណាំ:* ចំពោះការសរសេរតាមអានត្រួតពិនិត្យ លោកគ្រូ អ្នកគ្រូអាចអនុវត្តទៅតាមលទ្ធភាពដែលអាចធ្វើបាន។

ផ្នែកទី៤
សណាកប័ត្រជំពូកនិងមេរៀន

ជំពូកទី១

សាលារៀនភូមិខ្ញុំ

រយៈពេល	26ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី១	បំណិន៖ ការប្រើបទានុក្រម
មេរៀនទី២	អំណាន៖ ចេះមកពីរៀន
មេរៀនទី៣	សំណេរ៖ សកម្មភាពនៅសាលារៀន
មេរៀនទី៤	វេយ្យាករណ៍៖ សញ្ញាខំណ្ឌ
មេរៀនទី៥	អំណាន៖ គុណគ្រូ
មេរៀនទី៦	ស្តាប់៖ រឿង អាគីមើលអក្សរ
មេរៀនទី៧	សំណេរ៖ គុណគ្រូនិងឪពុកម្តាយ
មេរៀនទី៨	អំណាន៖ រឿង សិស្សដឹងគុណ
មេរៀនទី៩	សំណេរ៖ ពិពណ៌នាពីគ្រូបង្រៀន
មេរៀនទី១០	អំណាន៖ សាលារៀនខ្ញុំ
មេរៀនទី១១	សំណេរ៖ ពណ៌នាពីសាលារៀន

មេរៀនទី១	**បំណិន៖ ការប្រើបទានុក្រម**
រយៈពេល	2ម៉
វត្ថុបំណង	ប្រើប្រាស់បទានុក្រមបានត្រឹមត្រូវ។
សម្ភារៈឧបទេស	ស.ស. ទំព័រទី2 ដល់ទំព័រទី3 រូបភាពវចនានុក្រម
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	1. បទានុក្រមគឺជាបញ្ជីពាក្យពិបាកដែលស្រង់ចេញពីសៀវភៅ ។ ពាក្យទាំងនោះត្រូវបានរៀបតាមអក្ខរក្រម ដោយមានប្រាប់ពីរបៀបអាននិងន័យរបស់ពាក្យ ។ 2. យើងប្រើបទានុក្រមនៅពេលយើងមិនយល់ពាក្យណាមួយនៅក្នុងសៀវភៅ ដើម្បីឲ្យបានយល់កាន់តែច្បាស់ ។
កំណែលំហាត់	**លំហាត់ទី1៖** ក ⇨ គឺជាពាក្យត្រូវពន្យល់ ខ ⇨ គឺជាថ្នាក់ពាក្យ គ ⇨ គឺសេចក្តីពន្យល់ពាក្យខាងដើម **លំហាត់ទី2៖**

	គជសារ ⇨ ពាក្យត្រូវពន្យល់ (គច់ -ជ: - សា) ⇨ សូរពាក្យ ន. ⇨ ថ្នាក់ពាក្យ ជំរីមាឌធំសម្បើម ⇨ នំយរបស់ពាក្យ **លំហាត់ទី3៖** (១)មិនយល់ (២)សៀវភៅ (៣)បើកមើល (៤)ក្នុងទំព័រ (៥)ពាក្យនោះ

មេរៀនទី២	**អំណាន៖ ចេះមកពីរៀន**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីសារប្រយោជន៍នៃការរៀនសូត្របានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី4 ដល់ទំព័រទី5 រូបភាពទំព័រទី4
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. កុមារទៅសាលារៀន ដើម្បីទទួលចំណេះដឹង។ 2. ការរៀនសូត្រមានប្រយោជន៍អាចជួយខ្លួនឯង គ្រួសារ និងសង្គមជាតិឱ្យបានប្តុំប្តើងរុងរឿង។ 3. ខ្ញុំអាចជួយខ្លួនខ្ញុំគ្រួសារបានដោយសារចំណេះដឹង។ 4. បើមិនខំរៀនយើងនឹងក្លាយជាមនុស្សល្ងង់ខ្លៅមិនអាចជួយខ្លួនឯងគ្រួសារ និងសង្គមជាតិបាន។
កំណែលំហាត់	**លំហាត់ទី1៖** ខ. ព្យាយាមរៀនសូត្រ។ **លំហាត់ទី2៖** គ. ជួយខ្លួនឯង គ្រួសារនិងសង្គម។

មេរៀនទី៣	**សំណេរ៖ សកម្មភាពនៅសាលារៀន**
រយៈពេល	3ម៉
វត្ថុបំណង	រៀបរាប់ពីសកម្មភាពនៅសាលារៀនបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី6 រូបភាពទំព័រទី6
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** សរសេរពាក្យក្នុងប្រអប់សៀវភៅទំព័រ6 **លំហាត់ទី2៖** រូបទី១៖ តារាទទួលសៀវភៅយ៉ាងច្រើនពីសុផល។ រូបទី២៖ សិស្សានុសិស្សទាំអស់យកចិត្តទុកដាក់រៀនសូត្រ។ រូបទី៣៖ វាសនាជម្រាបសួរលោកគ្រូ។

មេរៀនទី៤	**វេយ្យាករណ៍៖ សញ្ញាខណ្ឌ** (។)
រយៈពេល	2ម៉

វត្ថុបំណង	ប្រើប្រាស់សញ្ញាខណ្ឌបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី7
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
កំណែលំហាត់	**លំហាត់ទី1៖** ក. ថ្នាក់រៀនខ្ញុំធំទូលាយ។ ខ. ការឧស្សាហ៍ព្យាយាម គ. នៅក្នុងទីធ្លាមានដើមឈើធំៗ។ ឃ. កូនល្អត្រូវជួយធ្វើកិច្ចការផ្ទះ។ **លំហាត់ទី2៖** សាលារៀនខ្ញុំតូចតែស្អាត។ ថ្នាក់រៀនខ្ញុំនៅជិតទីចាត់ការ។ ថ្នាក់រៀននីមួយៗ មានទ្វារនិងបង្អួចធំៗ។ សាលារៀននេះមានរបងព័ទ្ធជុំវិញ។ នៅខាងមុខថ្នាក់រៀនមានសួនច្បារ។ ទីធ្លាសាលាមានដើមឈើធំៗផ្តល់ម្លប់ត្រឈឹងត្រឈៃ។

មេរៀនទី៥	**អំណាន៖ មេសូត្រ៖ គុណគ្រូ (បទកាកគតិ)**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ការគោរពគ្រូបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី8 ដល់ទំព័រទី9 រូបភាពទំព័រទី8
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
ចម្លើយនៃសំណួរ	1. គុណម៉ែឪមានទម្ងន់ដូចប្រឹថពី ។ 2. គុណនេះមានតម្លៃដូចមាស ។ 3. យើងគួរទុកគ្រូបាធ្យាយ ឬគ្រូបង្រៀនរបស់យើងដូច ម្តាយឪពុកយើង។ 4. បានជាគេទុកគ្រូដូចជាឪពុកម្តាយព្រោះលោកបានផ្តល់នូវចំណេះដឹងនិងការប្រៀនប្រដៅ ។ 5. ខ្ញុំបានធ្វើអំពើល្អដូចជាស្តាប់ការអប់រំ ខិតខំរៀនសូត្រ គោរពវិន័យ ជួយកិច្ចការមួយចំនួនធំទៀតចំពោះគ្រូរបស់ខ្ញុំ។
កំណែលំហាត់	**លំហាត់ទី1៖** ក. រី ខ. ៧ឃ្លា គ. គុណឪពុកម្តាយ ឬគ្រូ ឃ. ចំណេះដឹងដល់យើង។ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង) បើសិនជាមិនស្តាប់ដំបូន្មានរបស់គ្រូយើងនឹងក្លាយជាក្មេងប្រព្រឹត្តខុសនឹងច្បាប់សាលា។

មេរៀនទី៦	**ការស្តាប់៖ រឿង អាគីមើលអក្សរ**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីគុណវិបត្តិមិនចេះអក្សរបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី10 ដល់ទំព័រទី11 រូបភាព៖ ទំព័រទី10

ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ24
ចម្លើយនៃសំណួរ	1. មានតួអង្គ៤នាក់ 2. លោកយាយបានទទួលសំបុត្រពីអ្នករត់សំបុត្រ។ 3. សំបុត្រនោះផ្តល់ដំណឹងល្អ។ 4. គាត់ប្រាប់ដំណឹងនោះដល់កូនរបស់គាត់។ 5. អាចំរើន 6. អាគីមិនអាចអានសំបុត្រនោះបានទេព្រោះវាមិនចេះអក្សរ។ 7. ដើម្បីចេះអាននិងសរសេរគេត្រូវខិតខំរៀនសូត្រ។
កំណែលំហាត់	**លំហាត់ទី1៖** ខ. រ៉ែនតា **លំហាត់ទី2៖** ខ. ផលវិបាកនៃអ្នកមិនចេះអក្សរ

មេរៀនទី៧	**សំណេរ៖ គុណគ្រូនិងឪពុកម្តាយ**
រយៈពេល	3ម៉ោ
វត្ថុបំណង	រៀបរាប់ពីគុណគ្រូនិងឪពុកម្តាយបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី12 រូបភាពទំព័រទី12
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** (ចម្លើយជាក់ស្តែង) ក. តាំងពីព្រលឹមឪពុកខ្ញុំលីន័ង្គលដឹកគោសំដៅទៅស្រែនៅឯក្បែរភូមិ។ លុះដល់ស្រែគាត់រួតរះទឹមគោដើម្បីភ្ជួរនិងរាស់ដីរហូតដល់ថ្ងៃត្រង់ទើបសម្រាក។ ឪពុកខិតខំយ៉ាងហត់នឿយនេះក៏ដើម្បីឱ្យកូនៗបានសិក្សារៀនសូត្រដែរ។ ខ. ម្តាយខ្ញុំឈ្មោះសុភាព។ គាត់មានអាយុ45ឆ្នាំហើយ។ គាត់ជាគ្រូបង្រៀន។ រាល់ថ្ងៃគាត់តែងយកចិត្តទុកដាក់បង្រៀនសិស្ស។ មិនតែប៉ុណ្ណោះគាត់បានផ្តល់ការអប់រំដល់សិស្សគ្រប់រូបនិងកូនៗរាល់គ្នាដើម្បីក្លាយខ្លួនជាសិស្សល្អកូនល្អនិងពលរដ្ឋល្អ។ ម្តាយគឺជាអ្នកមានគុណគាត់ខិតខំធ្វើការដោយមិនគិតពីការនឿយហត់ដើម្បីឱ្យកូនៗបានសិក្សារៀនសូត្រ។ **លំហាត់ទី2៖** (១)ព្រលឹម(២)ព្រលប់(៣)មុខរបរ(៤)កាប់គាស់(៥)ព្រះអាទិត្យ(៦)ចិញ្ចឹម(៧)រៀនសូត្រ(៨)ពួកគាត់(៩)ចំណេះដឹង

មេរៀនទី៨	**អំណាន៖ រឿង សិស្សដឹងគុណ**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីសកម្មភាពនៃការដឹងគុណបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី13ដល់ទំព័រទី14 រូបភាពទំព័រ13
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. លោកមេត្តាជានាយកនៃមន្ទីរពេទ្យមួយ។

	2. លោកបានជួបនឹងអតីតគ្រូបង្រៀនរបស់លោក។ ហើយមានអារម្មណ៍រីករាយណាស់។ 3. លោកមេត្តានិងករិយាបានសួរសុខទុក្ខអ្នកគ្រូជារឿយៗព្រមទាំងជួយឧបត្ថម្ភ ចំពោះអ្នកគ្រូទៀតផង។ 4. អ្នកគ្រូសប្បាយចិត្តដោយគាត់មានសិស្សជាមនុស្សល្អ មានចិត្តសប្បុរសចេះដឹងគុណ។
កំណែលំហាត់	**លំហាត់ទី1៖** សិស្សហាត់អានពាក្យក្នុងសៀវភៅទំព័រ14 **លំហាត់ទី2៖** ក. ការសងគុណគ្រូ ខ. ជួយឧបត្ថម្ភគាំទ្រទាំងស្មារតីនិងសម្ភារៈ

មេរៀនទី៩	**សំណេរ៖ ពណ៌នាពីគ្រូបង្រៀន**
រយៈពេល	3ម៉
វត្ថុបំណង	ពណ៌នាពីគ្រូបង្រៀនបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី15 រូបភាពទំព័រ15
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** សិស្សចម្លងពាក្យតាមក្នុងប្រអប់សៀវភៅទំព័រទី១៥ **លំហាតទី2៖** (ចម្លើយជាក់ស្តែង) - លោកគ្រូខ្ញុំឈ្មោះ សុធី។ - គាត់អាយុសែសិបឆ្នាំ។ - គាត់មានរាងខ្ពស់សង្ហារ។ - ទឹកមុខគាត់ញញឹមជានិច្ច។ - គាត់ជាមនុស្សរួសរាយរាក់ទាក់ណាស់។ - សម្លៀកបំពាក់គាត់ស្អាតបាតសមរម្យ។ - យើងគោរពស្រឡាញ់លោកគ្រូណាស់។ **លំហាត់ទី3៖** ក. លោកគ្រូពន្យល់មេរៀនដល់សិស្សានុសិស្ស។ ខ. អ្នកគ្រូទទួលសិស្សដោយទឹកមុខញញឹមជានិច្ច។

មេរៀនទី១០	**អំណាន៖ សាលារៀនខ្ញុំ**
រយៈពេល	2ម៉
វត្ថុបំណង	ពណ៌នាពីសាលារៀនបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី16 ដល់ទំព័រទី17 រូបភាពទំព័រ16
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. សាលារៀននោះឈ្មោះសាលាបឋមសិក្សាស្វាយមាស។ សង់នៅលើទីវាលមួយដ៏ធំ

	ទូលាយនាកណ្តាលភូមិ។ 2. ទីធ្លាសាលារៀនមានសួនច្បារនិងដើមឈើធំៗ 3. សិស្សានុសិស្សមានអារម្មណ៍ស្រឡាញ់និងសប្បាយរីករាយចង់មករៀនរាល់ថ្ងៃ។ 4. (ចម្លើយជាក់ស្តែង)
កំណែលំហាត់	**លំហាត់ទី1៖** សិស្សអានពាក្យក្នុងប្រអប់សៀវភៅទំព័រ16 **លំហាត់ទី2៖** ក. សាលារៀនឈ្មោះ សាលាបឋមសិក្សា "ស្វាយមាស"។ គ. សាលានេះមានរបងលួសបន្លាព័ទ្ធជុំវិញ ។ ង. សិស្សស្រឡាញ់សាលារៀន "ស្វាយមាស" ព្រោះសាលានេះស្អាតគ្មានសំរាម និង ស្រស់បំព្រងជានិច្ច។ **លំហាត់ទី3៖** ក. ទូលាយ ≠ ចង្អៀត ខ. ស្អាត ≠ កខ្វក់ គ. ខ្ពស់≠ ទាប ឃ. ធំ ≠ តូច ង. ជិត ≠ ឆ្ងាយ ច. តូច ≠ ធំ ឆ. ទាប ≠ ខ្ពស់ ជ. ចង្អៀត ≠ ទូលាយ ឈ. កខ្វក់ ≠ ស្អាត ញ. ឆ្ងាយ≠ ជិត

មេរៀនទី១១	**សំណេរ៖ ពណ៌នាពីសាលារៀន**
រយៈពេល	3ម៉
វត្ថុបំណង	ពណ៌នាពីសាលារៀនបានត្រឹមត្រូវ។
សម្ភារៈឧបទេស	ស.ស. ទំព័រទី18 រូបភាពទំព័រ18
ជំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** (ចម្លើយជាក់ស្តែង) - សាលារៀនខ្ញុំឈ្មោះសាលាដើម្បីភាពញញឹមនៃកុមារ។ - សាលារៀននេះសង់អំពីឈើប្រក់ក្បឿង។ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង) (១)ភាពញញឹមនៃកុមារ(២)លើទីវាលមួយដ៏ធំទូលាយ(៣)ថ្ម(៤)ក្បឿង(៥)អគារ (៦)២០បន្ទប់(៧)ខាងមុខ(៨)បោសសម្អាត (៩)ទីនេះផ្តល់នូវចំណេះយ៉ាងច្រើនដល់ខ្ញុំ។ **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង) - សាលារៀនខ្ញុំមានខ្លោងទ្វារសម្រាប់ចេញចូលនិងមានរបងលួបន្លាព័ទ្ធជុំវិញ។ ទីចាត់ការសាលាបែមុខចំទ្វារចូល។ នៅមុខទីចាត់ការមានដងទង់ជាតិបក់រវើចៗ។ - សាលារៀនខ្ញុំមានទីធ្លាធំទូលាយនិងមានសួនច្បារដែលមានផ្កាវីកស្គុះស្គាយ។ - សាលារៀនខ្ញុំមានអគារ២ខ្នងសង់អំពីថ្មប្រក់ស័ង្កសីនៅចំកណ្តាលទីធ្លា មានដងទង់ជាតិមួយអមដោយសួនច្បារពងរង្វង់មូល។

ជំពូកទី២

សិស្សល្អ

រយៈពេល	13ម៉ោង
វត្ថុបំណង	រៀបរាប់ពីសកម្មភាពរបស់សិស្សល្អបានត្រឹមត្រូវ ។
ចំណងជើងសមត្ថភាព	
មេរៀនទី១	អំណាន៖ សិស្សឧស្សាហ៍
មេរៀនទី២	វេយ្យាករណ៍៖ នាម
មេរៀនទី៣	អំណាន៖ មេសូត្រ៖ ច្បាប់ល្បីកថ្មី
មេរៀនទី៤	សំណេរ៖ ពណ៌នាពីសិស្សល្អ
មេរៀនទី៥	ស្តាប់៖ រឿង ការវៀហារសន្ធរម៉ុក
មេរៀនទី៦	អំណាន៖ ការកម្សាន្តនៅពេលទំនេរ

មេរៀនទី១	**អំណាន៖ សិស្សឧស្សាហ៍**
រយៈពេល	2ម៉
វត្ថុបំណង	កំណត់ពីលក្ខណៈសិស្សឧស្សាហ៍បានត្រឹមត្រូវ ។
សម្ភារឧបទេស	ស.ស. ទំព័រទី20ដល់ទី21 រូបភាពទំព័រទី20
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. កែវនិងសុខាជាសិស្សឧស្សាហ៍។ 2. នៅសាលារៀនពួកគេគោរពបទបញ្ជាផ្ទៃក្នុងសាលាយកចិត្តទុកដាក់ស្តាប់គ្រូពន្យល់ស្រឡាញ់មិត្តភក្តិជួយពន្យល់មិត្តដែលរៀនខ្សោយ។ 3. នៅផ្ទះពួកគេខំធ្វើលំហាត់និងអានសៀវភៅសិក្សាផ្សេងៗនិងជួយកិច្ចការផ្ទះខ្លះ។ 4. ឪពុកម្តាយកែវនិងសុខាមានអារម្មណ៍សប្បាយចិត្តណាស់ព្រោះឃើញកូនខិតខំរៀនសូត្រហើយទទួលបានលទ្ធផលល្អជាទីគាប់ចិត្ត។ 5. ខ្ញុំគួរយកទម្លាប់ដូចសុខានិងកែវដែរ ព្រោះនាងជាកូនល្អ សិស្សល្អ និងមិត្តល្អ។
កំណែលំហាត់	**លំហាត់ទី1៖** អានពាក្យក្នុងប្រអប់សៀវភៅទំព័រ20 **លំហាត់ទី2៖** ក. ឧស្សាហ៍ ខ. ពន្យល់ គ. សប្បាយ ឃ. បទបញ្ជា **លំហាត់ទី3៖** - គោរពបទបញ្ជារបស់សាលារៀន - ចេះជួយការងារផ្ទះ - ត្រូវបានឪពុកម្តាយស្រឡាញ់

	លំហាត់ទី4៖ នេះជាសួនបន្លែសាលារៀនយើង ។ នៅក្នុងសួនបន្លែដ៏ធំនេះយើងដាំបន្លែច្រើនមុខ ដូចជា៖ ស្ពៃ ត្រកួន ផ្ទឹ ...។ បន្លែទាំងនោះដុះលូតលាស់ល្អណាស់។

មេរៀនទី២	**វេយ្យាករណ៍៖ នាម**
រយៈពេល	2ម៉
វត្ថុបំណង	ប្រើប្រាស់នាមបានត្រឹមត្រូវ ។
សម្ភារឧបទេស	ស.ស. ទំព័រទី22 ដល់ទំព័រទី23 រូបភាព៖ តុ កៅ អី ប៊ិក សៀវភៅ.....
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
កំណែលំហាត់	**លំហាត់ទី1៖** សុខា បន្ទប់គេង ផ្ទះ ផ្កា ចំណីជ្រូក សៀវភៅ ខ្មៅដៃ បន្ទាត់ ជំរលុប សម្អែត សាលារៀន។ **លំហាត់ទី2៖** ក. តុ កៅអី ខ. សិស្ស គ. កង់ ឃ. ចេក **លំហាត់ទី3៖**

ចំនួន	មនុស្ស	សត្វ	វត្ថុ	រុក្ខជាតិ
១	សិស្ស	ឆ្កែ	តុ	ស្វាយ
២	កសិករ	ឆ្មា	កៅអី	ដូង
៣	គ្រូពេទ្យ	កណ្តុរ	កង់	ចេក
៤	កម្មករ	មាន់	សៀវភៅ	ខ្នុរ
៥	គ្រូបង្រៀន	ត្រី	បន្ទាត់	ស្ពៃ

មេរៀនទី៣	**អំណាន៖ មេសូត្រ៖ ច្បាប់ល្បីកថ្មី (បទកាកគតិ)**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីឥរិយាបថល្អចំពោះចាស់ទុំបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី24 ដល់ទំព័រទី25 រូបភាពទំព័រទី24
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. ពាក្យចាស់ទុំនានឱ្យរាប់អានមនុស្សសុចរិតត្រឹមត្រូវជាមិត្ត។ 2. យើងត្រូវស្តាប់បង្គាប់ ឆ្លើយបាទ ឬចាសប្រើពាក្យសម្តីទន់ភ្លន់ចំពោះឪពុកម្តាយ។ 3. បានជាយើងត្រូវប្រកាន់ឫកពាទន់ភ្លន់ដើម្បីបង្ហាញពីការគោរព។ 4. ខ្ញុំមិនចូលចិត្តមនុស្សកោងកាចទេ ព្រោះគេអាចធ្វើឱ្យគ្រោះថ្នាក់បាន។
កំណែលំហាត់	**លំហាត់ទី1៖** ក. ចាស់ ចួន ណាស់ ខ. ល្អ ចួន ក្រ គ. ផ្លូវ ចួន ឱ ស្លូវ **លំហាត់ទី2៖** ក. គ. ឃ **លំហាត់ទី3៖**(១)ខ្នាត (២)សម្អាត(៣)អនាម័យ (៤)ចង្រៃ (៥)ឆ្លងបាន

មេរៀនទី៤	**សំណេរ៖ ពណ៌នាពីសិស្សល្អ**
រយៈពេល	3ម៉
វត្ថុបំណង	រៀបរាប់ពីសិស្សល្អបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី26 រូបភាពទំព័រ 26
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** ក. នីតាជាសិស្សព្យាយាមរៀនសូត្រ។ ខ. ទិទូគោរពវិន័យសាលាជានិច្ច។ គ. ពេលទំនេរសុផលតែងតែធ្វើលំហាត់។ **លំហាត់ទី2៖** (១)អាក់ខាន(២)ពន្យល់ (៣)ពិន្ទុ(៤)មិត្តភក្តិ(៥)សរសើរ **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង) - ពេលចេញលេងសុខានិងតារាអានការសែត។ - សុភ័ក្រនិងសុផលកំពុងអានសៀវភៅរឿង។

មេរៀនទី៥	**ការស្តាប់៖ រឿង ការីរ៉ោហាសន្ធរម៉ុក**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីភាពប៉ិនប្រសប់(លក្ខណៈពិសេស)របស់ការីរ៉ោហាសន្ធម៉ុខបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី27 ដល់ទំព័រទី28 រូបភាពទំព័រ27
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ24
ចម្លើយនៃសំណួរ	1. កុមារម៉ុកមានរូបសម្បត្តិអាក្រក់។ 2. ពេលអាយុ១១ឆ្នាំកុមារម៉ុករស់នៅជាមួយព្រះចៅអធិការវត្តនៅស្រុកឧត្តុង្គ។ 3. ម៉ុកពូកែខាងនិយាយពាក្យចួនភ្លាមៗ។ 4. ក្រោយពីចាកសិក្ខាបទ ព្រះគ្រូយកម៉ុកទៅថ្វាយហ្លួង សម្តេចព្រះនរោត្តម។ 5. ម៉ុកបានទទួលឋានៈជាចាងហ្វាងកឹងអាល័ក្សនិងឧកញ៉ាសន្ធរ៉ោហាម៉ុក។ 6. គាត់ទទួលមរណៈភាពនៅឆ្នាំ1908។
កំណែលំហាត់	**លំហាត់ទី1៖** ខ. ពូកែនិយាយពាក្យជួនភ្លាមៗ **លំហាត់ទី2៖** គ. ដោយសារម៉ុកមានរូបសម្បត្តិអាក្រក់និងមានដៃទាំងពីរក្រែងង

មេរៀនទី៦	**អំណាន៖ ការកម្សាន្តនៅពេលទំនេរ**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីសកម្មភាពនៃការកម្សាន្តនៅពេលទំនេរបានត្រឹមត្រូវ ។
សម្ភារឧបទេស	ស.ស. ទំព័រទី29 ដល់ទំព័រទី30 រូបភាពទំព័រ29

ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. ការកម្សាន្តរបស់មនុស្សម្នាក់ៗមិនដូចគ្នាទេ ព្រោះមនុស្សម្នាក់ៗមានលទ្ធភាព និងចំណង់ចំណូលចិត្តខុសៗគ្នា។ 2. ការកម្សាន្តមានសារប្រយោជន៍ផ្តល់ភាពសប្បាយរីករាយធ្វើឱ្យមានសុខភាពល្អ និងកាត់បន្ថយការនឿយហត់។ 3. អ្នកចូលចិត្តការកម្សាន្តតាមឆ្នេរសមុទ្រ ព្រោះការកម្សាន្តនេះធ្វើឱ្យខ្ញុំទទួលបានខ្យល់អាកាសល្អបរិសុទ្ធ។
កំណែលំហាត់	**លំហាត់ទី1៖** ខ. ការកម្សាន្តនៅពេលទំនេរ **លំហាត់ទី2៖** ក ខ ឃ ច ជ

ជំពូកទី៣

ការកម្សាន្តរបស់យើង

រយៈពេល	16ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី១	អំណាន៖ ទិដ្ឋភាពថ្ងៃរៀបអស្តង្គតនៅប្រាសាទអង្គរវត្ត
មេរៀនទី២	សំណេរ៖ ពណ៌នាពីទិដ្ឋភាពរមណីយដ្ឋាន
មេរៀនទី៣	ស្តាប់៖ រឿង ណាស៊ីកុមារផ្ចាត់គ្រាប់ក្រួស
មេរៀនទី៤	និយាយ៖ ការរៀបរាប់ពីការកម្សាន្តដែលខ្លួនចូលចិត្ត
មេរៀនទី៥	វេយ្យាករណ៍៖ គុណនាម
មេរៀនទី៦	អំណាន៖ ត្រូវចេះជ្រើសរើសការកម្សាន្ត
មេរៀនទី៧	សំណេរ៖ រៀបរាប់ពីការកម្សាន្តមានសុវត្ថិភាព

មេរៀនទី១	**អំណាន៖ ទិដ្ឋភាពថ្ងៃរៀបអស្តង្គតនៅប្រាសាទអង្គរវត្ត**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីទិដ្ឋភាពថ្ងៃរៀបអស្តង្គតនៅប្រាសាទអង្គរវត្តបានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស. ទំព័រទី32ដល់ទំព័រទី33 រូបភាព៖ ទំព័រទី 32
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. ប្រាសាទអង្គរស្ថិតនៅខេត្តសៀមរាប។ 2. ទេសចរគួរចាំមើលប្រាសាទអង្គរវត្តប្រែពណ៌មាសនៅពេលថ្ងៃរៀបលិច។ 3. ទេសចរមានអារម្មណ៍រីករាយនិងជក់ចិត្តជិតអារម្មណ៍នូវទិដ្ឋភាពថ្ងៃរៀបអស្តង្គតនៅប្រាសាទអង្គរវត្ត។ 4. ខ្ញុំមានអារម្មណ៍ស្ងប់ស្ងៀងក្បាច់ប្រាសាទអង្គរវត្ត។
កំណែលំហាត់	**លំហាត់ទី1៖** សិស្សបើកសៀវភៅទំព័រ33អានពាក្យក្នុងប្រអប់ **លំហាត់ទី2៖** ក. អស្ចារ្យ (គុ) ដែលគួរស្ញើចក្រៃពេក។ ខ. ទិដ្ឋភាព (ន) ភាពនៃអ្វីៗដែលគេបានឃើញបានជួបប្រទះមកហើយ។ គ. ទេសចរ (ន) អ្នកធ្វើដំណើរលំហែកម្សាន្ត។ ឃ. ពសុធា (ន) ផែនដី ពិភពលោក។ **លំហាត់ទី3៖** ក. ព្រះអាទិត្យ ខ. ថ្ងៃលិច

	លំហាត់ទី4៖ ក. តួប្រាសាទទទួលពន្លឺពណ៌មាសនៅពេលថ្ងៃរៀបលិច ខ. ទិដ្ឋភាពថ្ងៃរៀបលិចនៅប្រាសាទអង្គរវត្ត

មេរៀនទី២	**សំណេរ៖ ពណ៌នាពីទិដ្ឋភាពរមណីយដ្ឋាន**
រយៈពេល	3ម៉ោ
វត្ថុបំណង	ពណ៌នាពីទិដ្ឋភាពរមណីយដ្ឋានណាមួយបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី34
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** ក. គិរីរម្យ ជ្រោះប៊ូស្រា ខ. ប្រាសាទអង្គរវត្ត គ. ល្អរិចិត្រ ឃ. សុខភាព ង. គង់វង្ស **លំហាត់ទី2៖** (១)ទឹកធ្លាក់ (២)ប្រាំពីរម៉ែត្រ (៣)អ្នកទេសចរ (៤)អន្តរជាតិ (៥)ទស្សនា

មេរៀនទី៣	**ការស្តាប់៖ រឿង ណាស៊ីកុមារផ្ចាត់គ្រាប់ក្រួស**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីទេពកោសល្យរបស់កុមារណាស៊ីបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី35ដល់ទី36 រូបភាពទំព័រទី35
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ24
ចម្លើយនៃសំណួរ	1. ណាស៊ីមានរាងកាយ ពិការស្ងិតជើងទាំងសងខាង។ 2. ណាស៊ីចូលចិត្តផ្ចាត់គ្រាប់ក្រួសទៅរកទិសដៅមួយជាច្រើនដងក្នុងមួយថ្ងៃ។ 3. បានជាកុមារជាច្រើនចូលចិត្តណាស៊ី ព្រោះវាផ្ចាត់គ្រាប់ក្រួសមិនដែលខុសទិសដៅ។ 4. ណាស៊ីបានជួបស្តេចនៅថ្ងៃមួយពេលដែលកំពុងលេង។ 5. បានជាស្តេចនាំណាស៊ីទៅវាំង ព្រោះស្តេចកោតសរសើរស្នាដៃដ៏ចម្លែកនេះ។ 6. ពេលនៅក្នុងវាំងស្តេចបានឱ្យណាស៊ីផ្ចាត់ដុំដីចូលក្នុងមាត់ទីប្រឹក្សាដែលនិយាយច្រើន។
កំណែលំហាត់	**លំហាត់ទី1៖** ខ. ក្របី ដំរី ចៀម **លំហាត់ទី2** ខ. បំណិនរបស់ណាស៊ីក្នុងការផ្ចាត់គ្រាប់ក្រួសទៅរកទិសដៅមួយ។ **លំហាត់ទី3៖** ក. ការឧស្សាហ៍ព្យាយាមនឹងទទួលបានអនាគតល្អ។

មេរៀនទី៤	**ការនិយាយ៖ ការរៀបរាប់ពីការកម្សាន្តដែលខ្លួនចូលចិត្ត**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីការកម្សាន្តដែលខ្លួនចូលចិត្តបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី37 ដល់ទី38 រូបភាពទំព័រទី37

ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ25
ចម្លើយនៃសំណួរ	1. នារីចូលចិត្តលោតអន្ទាក់ ព្រោះល្បែងនេះធ្វើឱ្យសប្បាយផងនិងមានសុខភាពល្អផង។ 2. ស្រគំចូលចិត្តលេងដណ្តើមបាល់ជាមួយមិត្តភក្តិ ព្រោះវាជាការហាត់ប្រាណដែរហើយនាំឱ្យយើងរហ័សរហួននិងមានសុខភាពល្អ។ 3. ចិន្តាចូលចិត្តអានសៀវភៅ កាសែត ទស្សនាវដ្តី ព្រោះការអានច្រើននាំឱ្យចេះដឹងច្រើន។ 4. ដីវ៉ាចូលចិត្តលេងរែក ព្រោះល្បែងនេះទម្លាប់ឱ្យយើងប្រើប្រាជ្ញានិងចម្រើនភាពវាងវៃ។ 5. (ចម្លើយជាក់ស្តែង)
កំណែលំហាត់	**លំហាត់ទី1៖** ខ. ល្បែងកម្សាន្តនិងផលប្រយោជន៍ ដែលកុមារម្នាក់ៗចូលចិត្ត។ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង)

មេរៀនទី៥	**វេយ្យាករណ៍៖ គុណនាម**
រយៈពេល	2ម៉
វត្ថុបំណង	ប្រើប្រាស់គុណនាមបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី39 ដល់ទំព័រទី40
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
កំណែលំហាត់	**លំហាត់ទី1៖** ក. វែង ខ្លី ខ. តូច ធំ គ. ខ្ពស់ ទាប ឃ. ជាត់ ស្គម **លំហាត់ទី2៖** ល្អ ស្តើង ខ្ពស់ រហ័សរហួន ឧស្សាហ៍ **លំហាត់ទី3៖** ក. ស្ងាត់ល្អ ស្រស់ត្រកាល ខ. ត្រជាក់ គ. ពីរោះ **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) សុខាមានមាឌតូច។ នៅខាងក្រោយផ្ទះខ្ញុំមានដើមឈើមួយដើមយ៉ាងខ្ពស់។ ចិត្រាចូលចិត្តស្លៀកសំពត់ខ្លី។ ក្រដាសសៀវភៅនេះស្តើង។ សុផលមានចិញ្ចើមក្រាស់។

មេរៀនទី៦	**អំណាន៖ ត្រូវចេះជ្រើសរើសការកម្សាន្ត**
រយៈពេល	2ម៉
វត្ថុបំណង	ជ្រើសរើសការកម្សាន្តបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី41ដល់ទំព័រទី42 រូបភាពទំព័រទី41
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. ការកម្សាន្តដែលមានប្រយោជន៍មាន លេងមឹក ជិះទោងលេងត្រែ៖ ទាត់សី លេងបិទពួន អាន សរសេរ គូររូប ដេរប៉ាក់ បត់ក្រដាស។

	2. ការកម្សាន្តដែលបង្កឱ្យមានគ្រោះថ្នាក់មាន លេងទឹក លេងភ្លើង ឡើងដើមឈើ លេងគ្រឿងផ្ទុះ លេងបាញ់ចម្ការមកៅស៊ូ លេងគប់គ្នា លេងគប់វង់លើថ្នល់ឬប្រឡែងគ្នាតាមចិញ្ចើមផ្លូវជាដើម។ 3. យើងគួរជ្រើសរើសការកម្សាន្តដែលមានប្រយោជន៍ពុំមានគ្រោះថ្នាក់ដល់ខ្លួននិងអ្នកដទៃ។
កំណែលំហាត់	**លំហាត់ទី1៖** សិស្សអានពាក្យក្នុងប្រអប់សៀវភៅទំព័រ42 **លំហាត់ទី2៖** ក. ការយល់ដាក់ច្បាស់។ ខ. សប្បាយរីករាយនិងបង្កើនប្រាជ្ញា

មេរៀនទី៧	**សំណេរ៖ រៀបរាប់ពីការកម្សាន្តមានសុវត្ថិភាព**
រយៈពេល	3ម៉
វត្ថុបំណង	រៀបរាប់ពីការកម្សាន្តដែលមានសុវត្ថិភាពបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី43 ដល់ទី44 រូបភាពទំព័រទី43 – 44
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** ក. នារីពូកែលេងត្រែ។ ខ. ទេសចរបរទេសទស្សនាប្រាសាទអង្គរវត្ត។ គ. ខ្ញុំចូលចិត្តការប្រគំតន្ត្រី។ ឃ. សែមចូលចិត្តអានសៀវភៅរឿងព្រេង។ **លំហាត់ទី2៖** (១)រីករាយ (២)លោតអន្ទាក់ (៣)ទាញព្រ័ត្រ (៤)រឹងមាំ (៥)គ្រោះថ្នាក់ (៦)សុវត្ថិភាព **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង) ក. ចិន្តានិងសុខាកំពុងលេងបាយខុំ។ ខ. ចាន់និងតារាលេងទាត់សីនៅទីធ្លាសាលា។ គ. កុមារីពីរនាក់កំពុងលេងលោតមឹក។

ជំពូកទី៤

កន្លែងកម្សាន្តនៅភូមិខ្ញុំ

រយៈពេល	26ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី១	អំណាន៖ មេសូត្រ៖ បាវាយណ៍ទឹកថ្លា
មេរៀនទី២	សំណេរ៖ ពណ៌នាពីតំបន់ទេសចរណ៍នៅខេត្តសៀមរាប
មេរៀនទី៣	និយាយ៖ ការផ្តល់ការណែនាំឱ្យស្គាល់ទីកន្លែង
មេរៀនទី៤	វេយ្យាករណ៍៖ កិរិយា
មេរៀនទី៥	អំណាន៖ ប្រាសាទអង្គរវត្ត
មេរៀនទី៦	សំណេរ៖ ពណ៌នាពីទិដ្ឋភាពភ្នំបាក់ខែង
មេរៀនទី៧	ស្តាប់៖ ទេសភាពជើងភ្នំ
មេរៀនទី៨	អំណាន៖ ផ្លូវទៅកាន់អង្គរ
មេរៀនទី៩	សំណេរ៖ ពណ៌នាពីទិដ្ឋភាពផ្លូវទៅកាន់អង្គរ
មេរៀនទី១០	អំណាន៖ រឿង ពូរស់ទៅលេងសៀមរាប
មេរៀនទី១១	សំណេរ៖ ពណ៌នាពីពីទិដ្ឋភាពប្រាសាទព្រះវិហារ

មេរៀនទី១	**អំណាន៖ មេសូត្រ៖ បាវាយណ៍ទឹកថ្លា (បទពាក្យប្រាំពីរ)**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីទិដ្ឋភាពបាវាយណ៍ទឹកថ្លាបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី46ដល់ទំព័រទី47 រូបភាព៖ បាវាយណ៍ទឹកថ្លា
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
ចម្លើយនៃសំណួរ	1. បាវាយណ៍ជាបឹងមួយយ៉ាងល្អឯក។ 2. បាវាយណ៍មានប្រយោជន៍ សម្រាប់ងូត ប្រើប្រាស់និងស្រោចស្រពដំណាំ។ 3. យើងត្រូវថែរក្សាដើម្បីឱ្យបាវាយណ៍នៅគង់វង្ស។
កំណែលំហាត់	**លំហាត់ទី1៖** ក. ដី ចួន សិរី ខ. មេត្រី ចួន ដី គ. ខ្មែរ ចួន ខែ ថៃ **លំហាត់ទី2៖** ក. ការងូតទឹកលេងសប្បាយ ខ. សម្រស់បឹងដ៏ល្អឯក គ. ទេសភាពនិងផលប្រយោជន៍នៃបាវាយណ៍ទឹកថ្លា

មេរៀនទី២	**សំណេរ៖ ពណ៌នាពីតំបន់ទេសចរណ៍នៅខេត្តសៀមរាប**
រយៈពេល	3ម៉ោ
វត្ថុបំណង	ពណ៌នាពីតំបន់ទេសចរណ៍ណាមួយនៅខេត្តសៀមរាបបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី48 រូបភាព៖ ប្រាសាទអង្គរវត្ត
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** ក. ប្រាសាទបន្ទាយស្រីមានក្បាច់ចម្លាក់ល្អអស្ចារ្យ។ ខ. ថ្ងៃអាទិត្យខ្ញុំទៅលេងបារាយណ៍ទឹកថ្លា។ គ. ភ្នំគូលែនស្ថិតនៅក្នុងខេត្តសៀមរាប។ ឃ. ប្រាសាទទាំងអស់សុទ្ធតែធ្វើអំពីថ្ម។ **លំហាត់ទី2៖** (១)ទស្សនា (២)កសាង (៣)សូរ្យវរ្ម័នទី២ (៤)កំពែង(៥)កស្តុតាង

មេរៀនទី៣	**ការនិយាយ៖ ការផ្តល់ការណែនាំឱ្យស្គាល់ទីកន្លែង**
រយៈពេល	2ម៉ោ
វត្ថុបំណង	ណែនាំនរណាម្នាក់ឱ្យស្គាល់ទីកន្លែងមួយបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទ49 ដល់ទំព័រទី50 រូបភាពទំព័រទី49
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ25
ចម្លើយនៃសំណួរ	1. ទេសចរសួរក្មេងប្រុសពីរទីកន្លែងរមណីយដ្ឋានក្បាលឆាយ។ 2. អ្នកទេសចរទទួលបានព័ត៌មាន ទីតាំងប្លង់និងចម្ងាយផ្លូវ។
កំណែលំហាត់	**លំហាត់ទី1៖** (ចម្លើយជាក់ស្តែង) **លំហាត់ទី2៖** អំប្រុស : ក្មួយប្រុស! តើមន្ទីរពេទ្យកុមារជាតិស្ថិតនៅឯណា? តើក្មួយអាចប្រាប់អំបានឬទេ? ក្មេងប្រុស: បាទបាន! មន្ទីរពេទ្យកុមារជាតិស្ថិតនៅចម្ងាយប្រហែល200ម៉ែត្រពីស្តុបអំបាសាំរ។ អំប្រុស : ដើម្បីទៅដល់ទីនោះតើខ្ញុំត្រូវធ្វើដំណើរតាមផ្លូវណា? បើយើងចេញដំណើរពីស្ថានីយរថភ្លើងតាមមហាវិថីសហព័ន្ធរុស្សីទៅទិសខាងលិចបានចម្ងាយប្រហែលជាង៧០០ម៉ែត្រយើងនឹងឃើញទីស្តីការគណៈរដ្ឋមន្ត្រីនៅខាងត្បូងផ្លូវលុះបន្តដំណើរបានប្រហែល៦០០ម៉ែត្រទៀតដល់ស្តុបអំបាសាំរយើងត្រូវធ្វើដំណើរទៅមុខត្រង់ប្រហែល២០០ម៉ែត្រទៀតនឹងឃើញមន្ទីរពេទ្យកុមារជាតិនៅខាងឆ្វេងដៃ។ សូមអំមើលប្លង់នេះ។ (សៀវភៅសិស្សទំព័រទី50) **លំហាត់ទី៣៖** (ចម្លើយជាក់ស្តែង)

មេរៀនទី៤	**វេយ្យាករណ៍៖ កិរិយា**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រើប្រាស់កិរិយាបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី51 ដល់ទំព័រទី52
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
កំណែលំហាត់	**លំហាត់ទី1៖** ទស្សនា លោត ទាត់ អាន សរសេរ **លំហាត់ទី2៖** ក. ជិះ ខ. ស៊ី គ. ធ្វើ កត់ ឃ. ទិញ ស្លូច **លំហាត់ទី3៖** រៀន អាន ជួយ មើល បោស រែក ពុះ ដាំ **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) ម៉ារីទៅផ្សារទិញម្ហូប។ ជីតាជាណាចូលចិត្តហូបបាយជាមួយស្វាយទុំ។ ចាន់ណាដាំបាយខ្លោច។ តារាកំពុងជួសជុលម៉ូតូ។ ពូសាន់នេសាទត្រីក្នុងបឹងទន្លេសាប។

មេរៀនទី៥	**អំណាន៖ ប្រាសាទអង្គរវត្ត**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីក្បាច់ចម្លាក់ប្រាសាទអង្គរវត្តបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី53ដល់ទំព័រទី54 រូបភាពប្រាសាទអង្គរវត្ត
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. ខេត្តសៀមរាបជាតំបន់ទេសចរណ៍។ 2. ចម្លាក់នៅលើប្រាសាទអង្គរវត្តមានលក្ខណៈរស់រវើក។ 3. ចម្លាក់ទាំងនោះមាននៅពាសពេញលើផ្នាំងថ្ម ចាប់ពីបង្កាន់ដៃស្ពាន ខឿនប្រាសាទ ខ្លោងទ្វារ បង្អួច សសរ ជញ្ជាំង ពិតានរហូតដល់កំពូល។ 4. អ្នកទេសចរមានអារម្មណ៍កោតស្ងប់ស្ងែងពេលបានទស្សនាប្រាសាទអង្គរវត្ត។ 5. ដើម្បីថែរក្សាប្រាសាទឱ្យនៅគង់វង្ស យើងមិនត្រូវប៉ះពាល់រូបចម្លាក់នៅលើជញ្ជាំងប្រាសាទ។
កំណែលំហាត់	**លំហាត់ទី1៖** ក. ចម្លាក់ ខ. បង្កាន់ដៃ គ. បង្ហាញ **លំហាត់ទី2៖** ក. ពិតាន (ន) របាំងក្រោមដំបូល។ ខ. ខឿន (ន) ថ្នាក់ ជាន់រងគេហដ្ឋាន ឬដីដែលលើកហើយមានឈើច្រុះ ឬរៀបឥដ្ឋ ថ្មបាំងពីខាងជុំវិញ ដើម្បីកុំឱ្យទឹកលិច។ គ. បុព្វបុរស (ន) មនុស្សជំនាន់ដើម។ ឃ. គង់វង្ស (គុ) គង់ពូជពង្សនៅមិនសូន្យ។

	លំហាត់ទី3៖ គ. ថ្វីដៃដ៏អស្ចារ្យរបស់បុព្វបុរសយើងនៅប្រាសាទអង្គរវត្ត។ **លំហាត់ទី4៖** ក. បុរាណ ≠ សម័យ ខ. គង់វង្ស ≠ បាត់បង់ **លំហាត់ទី5៖** នាម៖ ប្រាសាទ ថ្ម បុព្វបុរស ទេសចរ ធុងសំរាម ព្រះអាទិត្យ ពន្លឺ គុណនាម៖ ស្រទន់ កិរិយា៖ កសាង ដាក់ ចោល

មេរៀនទី៦	**សំណេរ៖ ពណ៌នាពីទិដ្ឋភាពភ្នំបាខែង**
រយៈពេល	3ម៉ោ
វត្ថុបំណង	ពណ៌នាពីទិដ្ឋភាពភ្នំបាខែងបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី55 រូភាពភាពភ្នំបាខែង
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** ក. ជា ខ. មើល គ. ឃើញ ឃ. ចូលចិត្ត ង. សម្លឹង **លំហាត់ទី2៖** (១)បាខែង (២)ស្ថិតនៅ (៣)ប្រាសាទ (៤)ថ្ងៃលិច (៥)ដើមឈើ (៦)ខ្ពស់ (៧)ព្រះអាទិត្យ

មេរៀនទី៧	**ការស្តាប់៖ ទេសភាពជើងភ្នំ**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីទេសភាពជើងភ្នំបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី56 រូបភាពទេសភាព
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ24
ចម្លើយនៃសំណួរ	1. កំណាព្យនេះលំនាំបទពាក្យប្រាំពីរ។ 2. នៅជើងភ្នំមានសត្វយំ ក្លិនផ្កា ទឹកហូរ។ 3. ព្រោះសម្រស់ធម្មជាតិនៅទីនោះដក់ជាប់ចិត្ត។
កំណែលំហាត់	**លំហាត់ទី1៖** ក. ភ្នំ ចួន យំ ខ. រមនា ចួន គន្ធា គ. មិនណាយ ចួន ស្រាយ ទៀត ចួន ឃ្លាត **លំហាត់ទី2៖** ខ. ទេសភាពជើងភ្នំ

មេរៀនទី៨	**អំណាន៖ ផ្លូវទៅកាន់អង្គរ**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីទិដ្ឋភាពតាមផ្លូវទៅអង្គរបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី57 ដល់ទំព័រទី58 រូបភាពទេសភាពផ្លូវទៅកាន់អង្គរ

ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. វៃកណ្តឹងយំនៅតាមដងផ្លូវទៅអង្គរនៅពេលរសៀល។ 2. សព្ទតូរ្យតន្ត្រីចម្លែកក្នុងអត្ថបទនេះជាសំឡេងវៃកណ្តឹង។ 3. នៅខែចេត្រនិងខែពិសាខអ្នកធ្វើដំណើរធុំក្លិនផ្កាំដួលនៅតាមដងផ្លូវទៅអង្គរ។ 4. ក្លិនផ្កាំដួលធ្វើឱ្យអ្នកដំណើរមានអារម្មណ៍អណ្តែតអណ្តូង។ 5. អ្នកនិពន្ធប្រដូចសំឡេងវៃនិងក្លិនដួលទៅនឹងទិព្វឱសថ។
កំណែលំហាត់	**លំហាត់ទី1៖** ក. ទិដ្ឋភាពតាមផ្លូវទៅអង្គរ ខ. អាប់ឱន **លំហាត់ទី2៖** នាម: ព្រះសុរិយា ធម្មជាតិ វៃកណ្តឹង ស្រឡៅ ឈើទាល តូរ្យតន្ត្រី គុណនាម: ខ្ពស់ ចម្លែក ប្លុំប្លើន ក្រអូប អណ្តែតអណ្តូង កិរិយាស័ព្ទ: ដុតចំហុយ យំ ទម្លាក់ នឹក បញ្ចេញ

មេរៀនទី៩	**សំណេរ៖ ពណ៌នាពីទិដ្ឋភាពផ្លូវទៅកាន់អង្គរ**
រយៈពេល	3ម៉ោ
វត្ថុបំណង	ពណ៌នាពីទិដ្ឋភាពផ្លូវទៅកាន់អង្គរបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី59
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** សិស្សបើកសៀវភៅទំព័រ59 អានពាក្យក្នុងប្រអប់ **លំហាត់ទី2៖** ក. ទិដ្ឋភាព ខ. ធ្វើដំណើរ គ. អណ្តែតអណ្តូង **លំហាត់ទី3៖** 4. ក 2. ខ 1. គ 3. ឃ 5. ង

មេរៀនទី១០	**អំណាន៖ រឿង ពូរស់ទៅលេងសៀមរាប**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីការធ្វើដំណើរទៅលេងសៀមរាបរបស់គ្រួសារ ពូរស់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី60 ដល់ទំព័រទី61 រូបភាពជិះឡានក្រុង
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. ពូរស់ទៅលេងនៅឯខេត្តសៀមរាប។ 2. គាត់ភ្លេចថង់ដាក់ចំណីអាហារ។ 3. ពូរស់រកស្នោងឃើញដោយសារកូនស្រីយកសំបុត្រឡានមកមើលរួចដើររកឡាននោះឃើញ។
កំណែលំហាត់	**លំហាត់ទី1៖** ធ្នើរ(ន) ថ្នាក់ខ្ពស់សម្រាប់បន្ទើរវត្តផ្សេងៗ។ ស្មុគ(ន) ហឹប ឬប្រអប់ក្បាញដោយបន្ទោះស្លឹកត្នោត ឬស្លឹកទ្រាំងជាដើម។

	លំហាត់ទី2៖ ក. ពូរស់និងកូនស្រីទៅលេងខេត្តសៀមរាប។ ខ. ប្រាសាទនានា

មេរៀនទី១១	**សំណេរ៖ ពណ៌នាពីពីទិដ្ឋភាពប្រាសាទព្រះវិហារ**
រយៈពេល	3ម៉
វត្ថុបំណង	ពណ៌នាពីទិដ្ឋភាពប្រាសាទព្រះវិហារបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី62 រូបភាពប្រាសាទព្រះវិហារ
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** សិស្សអានពាក្យក្នុងប្រអប់សៀវភៅទំព័រ62 **លំហាត់ទី2៖** ក. ប្រាសាទព្រះវិហារមានក្បាច់ចម្លាក់ល្អអស្ចារ្យ។ ខ. ប្រាសាទព្រះវិហារស្ថិតនៅក្នុងខេត្តព្រះវិហារ។ គ. ទេសចរបរទេសចូលចិត្តទៅកម្សាន្តនៅទីនោះ។ **លំហាត់ទី3៖** ក. ចម្លាក់ ជញ្ជាំង ខ. កូនខ្មែរ សម្បត្តិ គ. ដូនតា **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) ប្រាសាទព្រះវិហារស្ថិតក្នុងខេត្តព្រះវិហារ។ នៅលើជញ្ជាំងប្រាសាទមានចម្លាក់ល្អអស្ចារ្យ។ ភ្ញៀវទេសចរចូលចិត្តទៅកម្សាន្តនៅប្រាសាទព្រះវិហារ។

ជំពូកទី៥

គ្រួសារខ្ញុំ

រយៈពេល	9ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី១	ការស្តាប់៖ ការផ្សព្វផ្សាយការប្រមូលកុមារចូលរៀន
មេរៀនទី២	អំណាន៖ រឿង បងប្អូនគំរូពីរនាក់
មេរៀនទី៣	សំណេរ៖ រៀបរាប់ពីសកម្មភាពកូនល្អ
មេរៀនទី៤	អំណាន៖ មេសូត្រ៖ បណ្តាំបិតា

មេរៀនទី១	**ការស្តាប់៖ ការផ្សព្វផ្សាយប្រមូលកុមារចូលរៀន**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ការផ្សព្វផ្សាយការប្រមូលកុមារចូលរៀនបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី64
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ24
ចម្លើយនៃសំណួរ	1. គេផ្សព្វផ្សាយព័ត៌មាននៅសាលាបឋមសិក្សាភូមិយើង។ 2. គេផ្សព្វផ្សាយព័ត៌មាននេះ ដើម្បីឱ្យឪពុកម្តាយ ឬអាណាព្យាបាលកុមារទាំងអស់នាំកូនចៅដែលមានអាយុគ្រប់6ឆ្នាំទៅចុះឈ្មោះចូលរៀន។
កំណែលំហាត់	**លំហាត់ទី1៖** ក. ការប្រមូលកុមារចូលរៀន **លំហាត់ទី2៖** ខ. មុនពេលបវេសនកាល **លំហាត់ទី៣៖** ខ. ពុំមានបង់ប្រាក់

មេរៀនទី២	**អំណាន៖ រឿង បងប្អូនគំរូពីរនាក់**
រយៈពេល	2ម៉ោង
វត្ថុបំណង	រៀបរាប់ពីសកម្មភាពរបស់បងប្អូនគំរូពីរនាក់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី65ដល់ទំព័រទី66 រូបភាពទំព័រ65
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. បងមានប្រពន្ធ។ ប្អូននៅលីវ។ 2. ប្អូនបានជញ្ជូនកណ្តាប់ពីពំនូករបស់ខ្លួនទៅដាក់អោយបង។ ព្រោះប្អូនគិតថាខ្លួនគ្មានប្រពន្ធ។ 3. បងបានជញ្ជូនកណ្តាប់ពីពំនូករបស់ខ្លួនទៅដាក់ឱ្យប្អូន។ ព្រោះបងគិតថាខ្លួនមាន

	ប្រពន្ធកូនជួយរកស៊ី។ 4. បងប្អូនទាំងពីរជាមនុស្សល្អចេះស្រឡាញ់គ្នា និងគិតដល់គ្នា។
កំណែលំហាត់	**លំហាត់ទី1៖** សិស្សអានពាក្យក្នុងប្រអប់សៀវភៅទំព័រ66 **លំហាត់ទី2៖** គ. បងប្អូនប្រុសពីរនាក់មានចិត្តដូចគ្នា។ **លំហាត់ទី3៖** នាម៖ ស្រូវ ប្អូន គុណនាម៖ ទុំ កិរិយា៖ ច្រូត ចែក ស៊ី រស់ ជួយ **លំហាត់ទី4៖** ក. លីវ ⇨ ទំនេរ(គ្មានប្តី/ប្រពន្ធ) ខ. ប្រពន្ធ ⇨ ភរិយា គ. គំនរ ⇨ ពំនូក **លំហាត់ទី5៖** ក. សប្បាយ ⇨ ទុក្ខព្រួយ ខ. មុខ ⇨ ក្រោយ គ. ទំនេរ ⇨ រវល់

មេរៀនទី៣	**សំណេរ៖ រៀបរាប់ពីសកម្មភាពកូនល្អ**
រយៈពេល	3ម៉
វត្ថុបំណង	រៀបរាប់ពីសកម្មភាពកូនល្អបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី67
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** ក. ពាល់ឆ្នាំម្តាយខ្ញុំតែងធ្វើបុណ្យនៅផ្ទះ។ ខ. ពាល់ល្ងាចខ្ញុំតែងគក់ច្របាច់ឱ្យយាយទួត។ គ. កូនទាំងអស់ត្រូវស្តាប់ដំបូន្មានឪពុកម្តាយ។ **លំហាត់ទី2៖**(១)អាហារ (២)សាលារៀន (៣)ដំបូន្មាន (៤)ចំណី (៥)កូនល្អ **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង) សុខាស្រឡាញ់និងមើលថែប្អូន។ យើងជាកូនខ្មែរត្រូវមានចរិតថ្លៃថ្នូរ។ សុកីជាសិស្សឧស្សាហ៍។ ថ្ងៃអាទិត្យសូណានាំបងប្អូនទៅផ្សារទំនើប។ ឪពុកម្តាយសុខាជាអ្នកចម្ការ។

មេរៀនទី៤	**អំណាន៖ មេសូត្រ៖ បណ្តាំបិតា (បទកាកគតិ)**
រយៈពេល	2ម៉

វត្ថុបំណង	រៀបរាប់ពីបណ្តាំបិតាចំពោះកូនចៅបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី68ដល់ទំព័រទី69 រូបភាពទំព័រ68
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ23
ចម្លើយនៃសំណួរ	1. បិតាផ្តាំកូនថា រៀនឱនរៀនអត់ រៀនគិតក្នុងក្រៅ រៀនឱនលំទោន កុំឱ្យហ្មងសៅដល់ខ្លួនកូនពៅ កេរ្តិ៍ដល់ឪពុក។ 2. ប្រសិនបើកូនប្រព្រឹត្តខុសឆ្គងគេដៀលឪពុកម្តាយ។
កំណែលំហាត់	**លំហាត់ទី1៖**ខ. ប្រកាន់ឥរិយាបថល្អគ្រប់ពេល **លំហាត់ទី2៖** ក. បិតា ចួន បា រក្សា ខ. កំសត់ ចួន អត់ គ. ឪពុក ចួន ទុក

ជំពូកទី៦

ការរស់នៅរបស់អ្នកភូមិខ្ញុំ

រយៈពេល	15ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី១	អំណាន៖ ទីធ្លាចិញ្ចឹមសត្វ
មេរៀនទី២	និយាយ៖ ការរៀបរាប់អំពីមុខរបរអ្នកភូមិ
មេរៀនទី៣	ស្តាប់៖ ព័ត៌មានអំពីខ្យល់ព្យុះ
មេរៀនទី៤	វេយ្យាករណ៍៖ សញ្ញាសួរ (?)
មេរៀនទី៥	អំណាន៖ មេសូត្រ៖ មុខរបរអ្នកភូមិ
មេរៀនទី៦	អំណាន៖ រឿង ការងារជាកំណប់ទ្រព្យ
មេរៀនទី៧	សំណេរ៖ រៀបរាប់ពីមុខរបរអ្នកចិញ្ចឹមសត្វ

មេរៀនទី១	**អំណាន៖ ទីធ្លាចិញ្ចឹមសត្វ**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីសកម្មភាពចិញ្ចឹមសត្វក្នុងទីធ្លាបានត្រឹមត្រូវ។
សម្ភារៈឧបទេស	ស.ស. ទំព័រទី71ដល់ទំព័រទី72 រូបភាពទំព័រ71
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. អ្នកភូមិក្នុងអត្ថបទនេះប្រកបរបរធ្វើស្រែចម្ការ ដាំដំណាំ និងចិញ្ចឹមសត្វ។ 2. សត្វជ្រូក មាន់ ទាក្ងាន...។ 3. ដេញហួរនិងស្រែកបង្កើលមនុស្សចម្លែកដែលចូលក្នុងធ្លាសត្វធ្វើឱ្យអ្នកនោះភ័យខ្លាច។
កំណែលំហាត់	**លំហាត់ទី1៖** ក. បន្ទុក ខ. ប្រសាសន៍ គ. រណ្តៅ ឃ. បង្កើល។ **លំហាត់ទី2៖** ខ. 2កថាខណ្ឌ **លំហាត់ទី3៖** 1= ខ 2= ឃ 3= ក 4= គ 5= ង **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង)

ល.រ	សមាជិកគ្រួសារ	ការកិច្ច
1	ឪពុក	មានការកិច្ចរកស៊ីចិញ្ចឹមគ្រួសារ។
2	ម្តាយ	មានការកិច្ចមើលថែទាំកូននិងផ្ទះសំបែង។
3	ខ្ញុំ	មានការកិច្ចជួយបោសសម្អាតផ្ទះ។
4	បងស្រីខ្ញុំ	មានការកិច្ចជួយចម្អិនម្ហូបអាហារ។
5	ប្អូនស្រីខ្ញុំ	មានការកិច្ចឱ្យចំណីសត្វ។

មេរៀនទី២	**ការនិយាយ៖ ការរៀបរាប់អំពីមុខរបរអ្នកភូមិ**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីមុខរបរអ្នកភូមិបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី73ដល់ទំព័រទី74 រូបភាពទំព័រ73 -74
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ25
ចម្លើយនៃសំណួរ	1. សុខានិងវីរៈនិយាយគ្នាពីរឿងមុខរបរអ្នកភូមិ។ 2. សុខារស់នៅជនបទ។ វីរៈរស់នៅទីក្រុង។ 3. អ្នកជនបទគេប្រកបរបរធ្វើស្រែចម្ការ ត្បាញកន្ទេល ត្បាញក្រមា រកត្រីចិញ្ចឹមសត្វ និងធ្វើស្ករត្នោត។ 4. អ្នកទីក្រុងគេប្រកបរបរធ្វើសិប្បកម្ម លក់ដូរ ជួសជុលរថយន្ត ធ្វើសំណង់អ៊ុតសក់ កាត់សក់ បើកបរ និងធ្វើរាជការ។
កំណែលំហាត់	**លំហាត់ទី1៖** ក. ពូសំជាកសិករ។ ខ. ឪពុក ម្តាយខ្ញុំជាអ្នកលក់ដូរនៅឯផ្សារ។ គ. បងប្រុសខ្ញុំជាជាងសំណង់។ ឃ. បងស្រីខ្ញុំជាអ្នកគ្រូពេទ្យ។ **លំហាត់ទី2៖** ក. ខ្ញុំរស់នៅឯជនបទ។ ខ. អ្នកភូមិខ្ញុំប្រកបរបរធ្វើស្រែចម្ការ និងនេសាទត្រី។ គ. មុខរបរបន្ទាប់បន្សំរបស់អ្នកភូមិមានចិញ្ចឹមសត្វ និងបោចវល្លិ។ ឃ. ផលិតផលដែលគាត់ផលិតបានគាត់យកទៅលក់នៅឯផ្សារ។ ង. គ្រួសារនីមួយមានជីវភាពធូរធារ។

មេរៀនទី៣	**ការស្តាប់៖ ព័ត៌មានអំពីខ្យល់ព្យុះ**
រយៈពេល	2ម៉ោ
វត្ថុបំណង	ផ្សព្វផ្សាយព័ត៌មានអំពីខ្យល់ព្យុះបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី75 រូបភាពទំព័រ75
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ24
ចម្លើយនៃសំណួរ	1. ព័ត៌មានចេញពីការផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ទើបចាត់ទុកថាជាព័ត៌មានច្បាស់លាស់។ 2. ខ្យល់បក់ចេញពីប្រទេសចិនហើយឆ្លងកាត់ប្រទេសវៀតណាមនិងកម្ពុជា។ 3. ព្យុះនេះបានបង្កភាពមហន្តរាយដល់ខេត្តខេត្តកោះកុង ក្រុងព្រះសីហនុ...។ 4. រាជរដ្ឋាភិបាលអំពាវនាវដល់ប្រជាជនដែលរស់នៅតាមតំបន់មួយចំនួនខាងលើ

	ឱ្យប្រុងប្រយ័ត្ននិងហាមប្រជាជនចេញនេសាទក្នុងសមុទ្រធ្វើដំណើរតាមផ្លូវទឹកនិងផ្លូវអាកាសដើម្បីចៀសវាងគ្រោះថ្នាក់។ 5. ខ្ញុំចូលចិត្តស្តាប់ព័ត៌មាន ព្រោះវាធ្វើឱ្យយើងដឹងពីដំណឹងផ្សេងៗដែលបានកើតឡើងទាំងក្នុងប្រទេសនិងក្រៅប្រទេស។
កំណែលំហាត់	**លំហាត់ទី1៖** ក. ព្រឹកស្អែកនឹងមានខ្យល់ព្យុះធំមួយ **លំហាត់ទី2៖** គ. ត្រូវផ្សព្វផ្សាយបន្ត

មេរៀនទី៤	**វេយ្យាករណ៍៖ សញ្ញាសួរ (?)**
រយៈពេល	2ម៉
វត្ថុបំណង	ប្រើប្រាស់សញ្ញា(?)បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី76ដល់ទំព័រទី77
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ21
កំណែលំហាត់	**លំហាត់ទី1៖** ខ. ដាក់ខាងក្រោយល្បះសំណួរ **លំហាត់ទី2៖** ខ. តើឯងក្រោកពីដំណេកនៅម៉ោងប៉ុន្មាន? ឃ. តើឯងរៀននៅថ្នាក់ណា? **លំហាត់ទី3៖** ក ⇨ តើឯងចង់មានមុខរបរអ្វីនៅពេលអនាគត? ខ ⇨ តើឪពុកម្តាយឯងមានមុខរបរអ្វី? គ ⇨ តើសព្វថ្ងៃឯងស្នាក់នៅឯណា? ឃ ⇨ តើឯងមានបងប្អូនប៉ុន្មាននាក់? ង ⇨ តើជីតាឯងមានអាយុប៉ុន្មានឆ្នាំ? **លំហាត់ទី4៖** ក. តើកង្កែបនិងសត្វគីរស់នៅឯណា? ខ. តើកុមារានិងកុមារីកំពុងនិយាយគ្នាពីអ្វី? **លំហាត់ទី5៖** (ចម្លើយជាក់ស្តែង) តើឪពុកម្តាយឯងប្រកបមុខរបរអ្វី? តើឯងរៀននៅថ្នាក់ទីប៉ុន្មាន? តើឯងមានអាយុប៉ុន្មានឆ្នាំ? តើឯងរស់នៅឯណា?

មេរៀនទី៥	**អំណាន៖ មេសូត្រ៖ មុខរបរអ្នកភូមិ (បទកាកគតិ)**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីមុខរបរអ្នកភូមិបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី78ដល់ទំព័រទី79 រូបភាពទំព័រ78 ប័ណ្ណលំហាត់3(ទំព័រ79)

ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ23
ចម្លើយនៃសំណួរ	1. ក្រៅពីធ្វើស្រែចម្ការប្រជាជនត្បាញហូល ផាមួង ឡើងត្នោត ចិញ្ចឹមសត្វ នេសាទ ត្បាញកន្ទេល និងលក់ដូរ។ 2. បានជាប្រជាជនមានជីវភាពល្អប្រសើរ ព្រោះប្រជាជនខិតខំប្រកបមុខរបរច្រើនមុខ ដោយមិនទំនេរដៃ។ 3. ប្រជាជនភូមិខ្ញុំប្រកបរបរមិនដូចគ្នាទេ ព្រោះគេប្រកបរបរទៅតាមចំណង់ចំណូលចិត្ត។
កំណែលំហាត់	**លំហាត់ទី1៖** ក. ចិញ្ចឹម ខ. កន្ទេល គ. កម្រៃ ឃ. ចម្ការ **លំហាត់ទី2៖** ក. ចម្ការ ចួន ផ្កា ថ្លា (វគ្គទី1) ខ. ទា ចួន គ្នា(វគ្គទី2) គ. ប្រសើរ ចួន ដំណើរ (វគ្គទី3) ឃ. ថ្នៃ ចួន ដៃ កម្រៃ កម្រៃ ចួន ដៃ(ចួនឆ្លងវគ្គ) **លំហាត់ទី3៖** ខ. ប្រជាជនម្នាក់ៗខិតខំធ្វើការងាររច្រើនមុខ ដើម្បីជីវភាពធូរធារ។ **លំហាត់ទី4៖** សំណាញ់ មង អួន អង្រុត ឈ្នាង

មេរៀនទី៦	**អំណាន៖ រឿង ការងារជាកំណប់ទ្រព្យ**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីប្រយោជន៍ការងារបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី80ដល់ទំព័រទី81 រូបភាពទំព័រ80 បញ្ណាលំហាត់ទំព័រ81
ដំណើរការបង្រៀន	មើលលំនាំបង្រៀបទំព័រ22
ចម្លើយនៃសំណួរ	1. គ្រួសារក្នុងអត្ថបទមានសមាជិក3នាក់។ 2. កូនទាំងពីរមានគំនិតចង់ក្លាយជាអ្នកមាន។ 3. គ្រួសារនេះមានជីវភាពធូរធារដោយសារកូនទាំងពីរជាមនុស្សឧស្សាហ៍ខិតខំប្រកបរបរបន្ថែមទៀត។ 4. ខ្ញុំត្រូវខិតខំបង្កើតមុខរបរបន្ថែមទៀត។
កំណែលំហាត់	**លំហាត់ទី1៖** ក. សន្សំ ខ. មនុស្ស **លំហាត់ទី2៖** ក. ឧស្សាហ៍ (ន) ការខំប្រឹងមិនខ្ជិល សង្វាត សេចក្តីខ្មីឃ្មាត។ ខ. ទំនេរ (គុ. ឬ កិ. វិ.) ឥតមានរវល់, ឥតមានជំពាក់ដោយហេតុអ្វីនីមួយ។ គ. ឈ្មួញ (ន) អ្នកដែលធ្វើជំនួញ, អ្នកជួញ។ ឃ. កំណប់ (ន) របស់ដែលកប់ទុក : កំណប់ប្រាក់, កំណប់មាស។ **លំហាត់ទី3៖** គ. ការខំប្រកបរបរចិញ្ចឹមជីវិតនាំឱ្យគ្រួសារមានជីវភាពធូរធារ។

មេរៀនទី៧	**សំណេរ៖ រៀបរាប់ពីមុខរបរអ្នកចិញ្ចឹមសត្វ**
រយៈពេល	3ម៉
វត្ថុបំណង	រៀបរាប់ពីមុខរបរអ្នកចិញ្ចឹមសត្វ(គោ ជ្រូក មាន់ ទា ក្រួច)បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី82 រូបភាពទំព័រ82 ប័ណ្ណលំហាត់
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** សិស្សចម្លងពាក្យនិងកន្សោមពាក្យពីសៀវភៅសិស្សទំព័រ៨៣ ដាក់ក្នុងសៀវភៅ។ **លំហាត់ទី2៖** (១)ចិញ្ចឹម (២)ទ្រុង (៣)កន្ទក់ (៤)សាច់ (៥)ចំណី **លំហាត់ទី3៖** ក. ក្នុងភូមិរបស់ខ្ញុំមានអ្នកចិញ្ចឹមសត្វ។ គាត់ឈ្មោះមីងសាន។ គាត់ចិញ្ចឹមគោ ជ្រូក មាន់ ទា។ ខ. សត្វទាំងនេះស៊ី គោស៊ីស្មៅ មាន់និងទាស៊ីពោត ឬស្រូវ ជ្រូកស៊ីកន្ទក់ ដើមចេក និងបន្លែផ្សេងៗ។ គ. គាត់ថែរក្សាវាដូចជាឱ្យចំណីវាគ្រប់គ្រាន់ ធ្វើទ្រុងឱ្យត្រូវពន្លឺថ្ងៃនឹងលាងសម្អាតជាប្រចាំ...។ ឃ. វាផ្តល់ប្រយោជន៍ឱ្យយើងដូចជា គោជួយសម្រាលការងារ ឯមាន់ ទាជ្រូកផ្តល់ជាសាច់សម្រាប់បរិភោគនិងសម្រាប់លក់។ ង. គ្រួសារគាត់មានជីវភាពរស់នៅយ៉ាងធូរធារ។

ជំពូកទី៧

ភូមិខ្ញុំនៅរដូវប្រាំងនិងរដូវវស្សា

រយៈពេល	14ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី១	អំណាន៖ ការងារអ្នកភូមិខ្ញុំ
មេរៀនទី២	សំណេរ៖ រៀបរាប់ពីព្រឹត្តិការណ៍ដែលធ្លាប់ជួបប្រទះ
មេរៀនទី៣	ស្តាប់៖ រឿង កំណប់ឪពុក
មេរៀនទី៤	វេយ្យាករណ៍៖ សញ្ញា[អ] ឬសញ្ញាធ្មេញកណ្តុរ [◌]
មេរៀនទី៥	អំណាន៖ មេសូត្រ៖ ត្រូវឧស្សាហ៍ដាំដំណាំ
មេរៀនទី៦	សំណេរ៖ រៀបរាប់ពីសកម្មភាពថែទាំដំណាំ

មេរៀនទី១	**អំណាន៖ ការងារអ្នកភូមិខ្ញុំ**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីការងារអ្នកភូមិបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី84ដល់ទំព័រទី85 រូបភាពទំព័រ84 ប័ណ្ណលំហាត់.....
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. នៅរដូវប្រាំងអ្នកភូមិធ្វើស្រែប្រាំង អ្នកខ្លះចេញទៅរកផ្តៅ ឫស្សីយកមកធ្វើល្អី កញ្ច្រែង ចង្អេរ និងគ្រឿងសង្ហារឹម អ្នកខ្លះទៀតដេរស្លឹក ក្រងស្បូវ ត្បាញកន្ទេល ក្រមាស្បៃ។ 2. ដំណាំសំខាន់ជាងគេគឺស្រូវ។ 3. ក្រៅពីដាំដំណាំនិងធ្វើស្រែអ្នកភូមិធ្វើល្អី កញ្ច្រែង ចង្អេរ និងគ្រឿងសង្ហារឹមអ្នកខ្លះទៀតដេរស្លឹកក្រងស្បូវ ត្បាញកន្ទេល ក្រមាស្បៃ។ 4. បានជាអ្នកភូមិមានជីវភាពធូរធារព្រោះគេមានការងារធ្វើពេញមួយឆ្នាំ។
កំណែលំហាត់	**លំហាត់ទី1៖** ក. ឫស្សី ខ. កញ្ច្រែង គ. សង្ហារឹម ឃ. ចង្អេរ ង. សណ្តែក **លំហាត់ទី2៖** ក. នោស់ (ន) ប្រដាប់មានមេ ដង ធ្មេញ, សម្រាប់ប្រើការរាស់។ ខ. នង្គ័ល (ន) ប្រដាប់សម្រាប់ភ្ជួរដី។ គ. កញ្ច្រែង (ន) ប្រដាប់ប្រើត្បាញនឹងបន្ទោះដូចល្អី, កញ្ជើ (ត្បាញរង្វើលៗ) **លំហាត់ទី3៖** គ. តុ ទូ កៅអី គ្រែ **លំហាត់ទី4៖** ខ. ខិតខំធ្វើការងារ ដើម្បីឱ្យជីវភាពធូរធារ **លំហាត់ទី5៖** ធ្វើស្រែប្រាំងរក ផ្តៅ វល្លិ ឫស្សីយកមកធ្វើល្អី កញ្ច្រែង ចង្អេរ និង

	គ្រឿងសង្ហារិម អ្នកខ្លះទៀតដេរស្លឹក ក្រងស្បូវ ត្បាញកន្ទេល ក្រមា ស្បៃ។

មេរៀនទី២	**សំណេរ៖ រៀបរាប់ពីព្រឹត្តិការណ៍ដែលធ្លាប់ជួបប្រទះ**
រយៈពេល	3ម៉ោ
វត្ថុបំណង	រៀបរាប់ពីព្រឹត្តិការណ៍អ្វីមួយដែលអ្នកធ្លាប់ជួបប្រទះបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រ86
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
ចម្លើយនៃសំណួរ	
កំណែលំហាត់	**លំហាត់ទី1៖** សិស្សសរសេរពាក្យក្នុងប្រអប់សៀវភៅទំព័រ87 **លំហាត់ទី2៖** ក. ដេរវែស្បា ខ. ទឹកឡើងស្រឹតៗ គ. ហូរចូល ឃ. គ្រោះទឹកជំនន់ ទីទួល ង. កង្វះស្បៀងអាហារ **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង) ក. ខ្ញុំធ្លាប់ជួបនឹងព្រឹត្តិការណ៍ខ្យល់ព្យុះ។ នៅស្រុកល្វាឯម។ ខ. មុនពេលកើតហេតុមេឃខ្មៅងងឹត ផ្គាំងពពកខ្មៅធំៗ ភ្លៀងធ្លាក់តិចៗ។ គ. មនុស្សម្នានាំគ្នារួតរះម្ដីម្នារត់ទៅរកទីជម្រក អ្នកខ្លះរត់ទៅដឹកសត្វពាហនៈទៅរកទីជម្រក ខ្លះជញ្ជូនរបស់របរចូលផ្ទះ ខ្លះទៀតប្រមូលកូនចៅចូលផ្ទះ ឯខ្លះទៀតបិទទ្វារបង្អួចផ្ទះរៀងៗខ្លួន។ ឃ. បន្ទាប់ពីមានហេតុការណ៍នោះកើតឡើងដំណាំ ផ្ទះសំបែងទ្រព្យសម្បត្តិសាធារណៈមួយចំនួនដូចជា ស្ពាន សាលារៀន ត្រូវបានខូចខាតមនុស្ស និងសត្វមួយចំនួនត្រូវរងរបួស ប្រជាជនខ្លះគ្មានទីជម្រក។

មេរៀនទី៣	**ការស្តាប់៖ រឿង កំណប់ឪពុក**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីសារប្រយោជន៍នៃតម្លៃការងារបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី87ដល់ទំព័រទី88 រូបភាពទំព័រ88 ប័ណ្ណលំហាត់.....
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ24
ចម្លើយនៃសំណួរ	1. រឿងនេះមានតួអង្គ4នាក់។ 2. ពួកគេគិតនាំគ្នាធ្វើស្រែ។ 3. ពួកគេមានអារម្មណ៍សប្បាយរីករាយណាស់ពេលលក់ផលដំណាំបានច្រើន។ 4. ពួកគេរកកំណប់ក្នុងដីមិនឃើញទេ។

កំណែលំហាត់	**លំហាត់ទី1៖** ក. ពឹងផ្អែកលើកម្លាំងនិងទ្រព្យសម្បត្តិឪពុក ខ. ឱ្យកូនអត់ធ្មត់ទម្លាប់ខ្លួនក្នុងការងារលំបាក គ. ការងារជាកំណប់ទ្រព្យ។ **លំហាត់ទី2៖** សិស្សសម្តែងរឿងនៅតាមតួអង្គកសិករ

មេរៀនទី៤	**វេយ្យាករណ៍៖ សញ្ញា[អ] ឬសញ្ញាធ្មេញកណ្តុរ [◌ំ]**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រើប្រាស់សញ្ញា[អ] ឬសញ្ញាធ្មេញកណ្តុរ [◌ំ]បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី89ដល់ទំព័រទី90
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
កំណែលំហាត់	**លំហាត់ទី1៖** ម៉ន ចាប៊ី ប៉ា ម៉ូតូ ម៉ាក់ ម៉ាំ ប៉ាក់ យ៉ាង **លំហាត់ទី2៖** ង ញ រ វ យ ប **លំហាត់ទី3៖** ពាក្យពន: **លំហាត់ទី4៖**(ចម្លើយជាក់ស្តែង) ចំប៊ី ប៉ែងប៉ោះ ស៊ីញ៉ែ ម៉ាំល្អុង ង៉ក់ង

មេរៀនទី៥	**អំណាន៖ មេសូត្រ៖ ត្រូវឧស្សាហ៍ដាំដំណាំ (បទព្រហ្មគីតិ)**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីសកម្មភាពឧស្សាហ៍ក្នុងការដាំដំណាំបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី91ដល់ទំព័រទី92 រូបភាពទំព័រ91 ប័ណ្ណលំហាត់92
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
ចម្លើយនៃសំណួរ	1. គេដាំដំណាំស្លឹកគ្រៃ ខ្ញី ត្រប់ ត្រាវ ត្រសក់ ។ 2. ដាំដោយមើម ស្លឹកគ្រៃ ត្រាវ ខ្ញីដាំដោយគ្រាប់មានត្រប់ ត្រសក់។ 3. ដំណាំត្រូវការមើលថែទាំដូចជា បោចស្មៅ ស្រោចទឹក ដាក់ជី...ដើម្បីលូតលាស់ល្អ។ 4. នៅរដូវប្រាំងគេត្រូវដងទឹកស្រោចដំណាំ។ 5. មេសូត្រនេះលំនាំបទព្រហ្មគីតិ។
កំណែលំហាត់	**លំហាត់ទី1៖** ក. កម្លាំង ខ. បន្លែ **លំហាត់ទី2៖** ក. ងងុស (កិ.វិ) និយាយដោយទទូច។ ខ. ស្រោចស្រព (កិ) ចាក់វត្ថុរាវមានទឹកជាដើម បង្ហៀរលើ។ **លំហាត់ទី3៖** ក. 4វគ្គ ខ. ឧស្សាហ៍ គ. ផង ឃ. ការថែដំណាំ

មេរៀនទី៦	**សំណេរ៖ រៀបរាប់ពីសកម្មភាពថែទាំដំណាំ**
រយៈពេល	3ម៉ោ
វត្ថុបំណង	រៀបរាប់ពីសកម្មភាពថែទាំដំណាំបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី93 រូបភាពទំព័រ93
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** សិស្សសរសេរពាក្យក្នុងប្រអប់សៀវភៅទំព័រ93 **លំហាត់ទី2៖** ក៖ នៅជុំវិញផ្ទះយើងត្រូវដាំបន្លែនិងដំណាំហូបផ្លែ។ ខ៖ ដំណាំលូតលាស់ល្អយើងត្រូវស្រោចទឹករាល់ថ្ងៃ។ **លំហាត់ទី3៖** ក. សុខានិងបងស្រីតែងជួយគ្នាថែដំណាំនៅខាងក្រោយផ្ទះ។ ខ. ដំណាំទាំងនេះលូតលាស់ និងផ្តល់ផលបានល្អដោយសារការខិតខំថែទាំរបស់សំនិងជីតាវា។ គ. ឪពុកខ្ញុំកំពុងតែបាញ់ថ្នាំសម្លាប់សត្វល្អិតនៅឯចម្ការខាងក្រោយផ្ទះ។ **លំហាត់ទី4៖** ក. នៅជុំវិញផ្ទះរបស់ខ្ញុំមានដាំផ្ទឹ ស្ពៃ ល្ពុង ត្រប់ ម្ទេស...។ ខ. ដំណាំទាំងនោះដុះលូតលាស់ល្អដោយសារខ្ញុំជ្រួយដី ដាក់ជី ស្រោចទឹក ។ គ. ខ្ញុំថែដំណាំទាំងនោះដោយស្រោចទឹក និងដកស្មៅ...។ ឃ. ត្រូវចាប់សត្វល្អិតកុំឱ្យវាស៊ីស្លឹករុក្ខជាតិ ឬបាញ់ថ្នាំសម្លាប់សត្វល្អិត។ ង. ដំណាំទាំងនោះផ្តល់ប្រយោជន៍ដូចជាយកទៅស្លនិងលក់។

ជំពូកទី៨

ពិធីបុណ្យផ្សេងៗនៅភូមិខ្ញុំ

រយៈពេល	11ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី១	អំណាន៖ បុណ្យផ្កានៅភូមិខ្ញុំ
មេរៀនទី២	និយាយ៖ ការបង្ហាញព័ត៌មានតាមគម្រោងគំនិត
មេរៀនទី៣	វេយ្យាករណ៍៖ សញ្ញា [អ៊] ឬសញ្ញាសក់ « ◌ៈ »
មេរៀនទី៤	អំណាន៖ បុណ្យចូលឆ្នាំខ្មែរ
មេរៀនទី៥	សំណេរ៖ រៀបរាប់ពីពិធីបុណ្យ

មេរៀនទី១	**អំណាន៖ បុណ្យផ្កានៅភូមិខ្ញុំ**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីពិធីបុណ្យផ្កាបានត្រឹមត្រូវ។
សម្ភារៈឧបទេស	ស.ស. ទំព័រទី95ដល់ទំព័រទី96 រូបភាពទំព័រ95 ប័ណ្ណលំហាត់
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. ប្រជាជនប្រារព្ធពិធីបុណ្យផ្កាដើម្បីប្រមូលបច្ច័យយកទៅជួសជុលដំបូលអគារសិក្សាមួយខ្នង។ 2. នៅពេលរសៀលមានភ្ញៀវស្រីប្រុសមកចូលបុណ្យជាបន្តបន្ទាប់ហើយលោកអាចារ្យបានឱ្យពរជ័យដល់អ្នកដែលមានសទ្ធាជ្រះថ្លា និងនិមន្តព្រះសង្ឃសូត្រមន្តនិងសម្តែងធម្មទេសនា។ ពេល យប់មានសម្តែងយីកេ។ 3. ប្រជាជនមានទឹកចិត្តរីករាយចំពោះពិធីបុណ្យនេះ ពីព្រោះគេបានធ្វើបុណ្យរួមគ្នា។
កំណែលំហាត់	**លំហាត់ទី1៖** ក. ប្រារព្ធ ខ. បច្ច័យ គ. ព្រះសង្ឃ ឃ. សូត្រមន្ត ង. និមន្ត **លំហាត់ទី2៖** ក. បច្ច័យ (ន) ហេតុជាទីអាស្រ័យតគ្នា ទំនង លំអាន ហេតុដែលនាំឱ្យផលប្រព្រឹត្តទៅ។ ខ. កុះករ (គុ) ច្រើន, បរិបូណ៌, សម្បូណ៌, ដេរដាស។ គ. ប្រារព្ធ (កិ) តាំងផ្តើម, ផ្តួចផ្តើម, ផ្តងជាមុន។ **លំហាត់ទី3៖**

ឈ្មោះបុណ្យ	បុណ្យផ្កាសាមគ្គី
ថ្ងៃ ខែ ឆ្នាំបុណ្យ	15 មករា 2012
ទីកន្លែងបុណ្យ	ក្នុងភូមិ

អ្នកធ្វើបុណ្យ	ប្រជាជន
គោលបំណងបុណ្យ	ប្រមូលបច្ច័យយកទៅជួសជុលដំបូលអគារសិក្សាមួយខ្នង។

មេរៀនទី២	**ការនិយាយ៖ ការបង្ហាញព័ត៌មានតាមគម្រោងគំនិត**
រយៈពេល	2ម៉ោ
វត្ថុបំណង	បង្ហាញព័ត៌មានតាមគម្រោងគំនិតបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី97ដល់ទំព័រទី98
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ25
ចម្លើយនៃសំណួរ	1. គេបង្ហាញព័ត៌មានពីពិធីបុណ្យផ្កា។ 2. គម្រោងគំនិតនោះគេសរសេរ - ថ្ងៃ ខែឆ្នាំធ្វើ - ឈ្មោះបុណ្យ - ទីកន្លែងធ្វើបុណ្យ - អ្នកធ្វើបុណ្យ - គោលបំណងបុណ្យ។ 3. ពេលចាប់ផ្តើមបង្ហាញព័ត៌មានគេប្រើពាក្យគួរសមដូចជា ជម្រាបសួរ និងសួស្តី
កំណែលំហាត់	**លំហាត់ទី1៖** ធ្វើគម្រោងគំនិត - ថ្ងៃ ខែ ឆ្នាំធ្វើបុណ្យ: ល្ងាចថ្ងៃសៅរ៍ និងព្រឹកថ្ងៃអាទិត្យទី10 ខែវិច្ឆិកា ឆ្នាំ2012 - ឈ្មោះបុណ្យ: បុណ្យកឋិន - ទីកន្លែងធ្វើបុណ្យ: នៅវត្តស្ទឹងមានជ័យ - អ្នកធ្វើបុណ្យ: ពុទ្ធបរិស័ទចំណុះជើងវត្តស្ទឹងមានជ័យ - គោលបំណងបុណ្យ: ប្រគេនត្រៃចីវរចំពោះព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់រយៈកាល៣ខែ។ **លំហាត់ទី2៖** ការបង្ហាញព័ត៌មាន ការបង្ហាញព័ត៌មានដោយសិស្សម្នាក់: ជម្រាបសួរអ្នកគ្រូ! សួស្តីមិត្តទាំងអស់គ្នា! ថ្ងៃនេះខ្ញុំសូមជម្រាបព័ត៌មានមួយ។ នៅថ្ងៃសៅរ៍ ទី9 ខែវិច្ឆិកា ឆ្នាំ២០១២ ខាងមុខគ្រួសារខ្ញុំនឹងទៅចូលរួមពិធីបុណ្យកឋិនមួយដែលអ្នកភូមិរៀបចំឡើងនៅឯវត្តស្ទឹងមានជ័យ។ គេធ្វើបុណ្យនេះ ដើម្បីប្រគេនត្រៃចីវរចំពោះព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់រយៈកាល ៣ ខែ។ ពិធីបុណ្យនេះចាប់ផ្តើមពីល្ងាចថ្ងៃសៅរ៍ ទី9 ខែវិច្ឆិកា បង្ហើយនៅព្រឹកថ្ងៃអាទិត្យ ទី១០ ខែវិច្ឆិកា ។ ខ្ញុំតំណាងឱ្យពុទ្ធបរិស័ទចំណុះជើងវត្តស្ទឹងមានជ័យទាំងអស់សូមថ្លែងអំណរគុណចំពោះការចូលរួមរបស់ភ្ញៀវកិត្តិយសទាំងអស់។

មេរៀនទី៣	**វេយ្យាករណ៍៖ សញ្ញា [អ៊] ឬសញ្ញាសក់ « ◌៊ »**
រយៈពេល	2ម៉ោ

វត្ថុបំណង	ប្រើប្រាស់ សញ្ញា **[អ៊]** ឬសញ្ញាសក់ « ◌ ៉ »បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី99
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
កំណែលំហាត់	**លំហាត់ទី1៖** ក.ប ឃ. ស ច. ហ ឆ. អ **លំហាត់ទី2៖** ស៊ី ហ៊ាន សាប៊ូ តៅហ៊ូ កៅស៊ូ ប៊ីចេង អ៊ូអរ ទ្រអ៊ូ សុាំ ស៊ើប តស៊ូ **លំហាត់ទី3៖** ប៊ិក តស៊ូ ហ៊ឹង រអ៊ូ

មេរៀនទី៤	**អំណាន៖ បុណ្យចូលឆ្នាំខ្មែរ**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីពិធីបុណ្យចូលឆ្នាំខ្មែរបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី100ដល់ទំព័រទី101 រូបភាពទំព័រ100 ប័ណ្ណលំហាត់
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. ថ្ងៃទី13 ឬថ្ងៃទី14 ខែមេសា រៀងរាល់ឆ្នាំ។ 2. គេរៀបចំផ្កាភ្ញី នំចំណី ផ្លែឈើ និងភេសជ្ជៈផ្សេងៗដើម្បីទទួលទេវតា។ 3. ល្បែងប្រជាប្រិយដែលគេលេងនៅពេលចូលឆ្នាំមាន ចោលឈូង បោះអង្គញ់ ទាញព្រ័ត្រ និងវាំកម្សាន្ត។ 4. ប្រជាជនមានអារម្មណ៍សប្បាយរីករាយក្រៃលែង។
កំណែលំហាត់	**លំហាត់ទី1៖** ក. ចង្ហាន់ ខ. ទាញព្រ័ត្រ **លំហាត់ទី2៖** ក. ភេសជ្ជៈ (ន) គ្រឿងផឹក ក្រៅពីសុរា។ ខ. សន្តាន (ន) វង្ស ពង្ស ពូជ ពូជពង្ស តំណវង្ស។ គ. ឧទ្ទិស (កិ) សំដៅទៅរក សំដៅចំពោះ ឆ្ពោះទៅ តម្រង់ទៅរក បម្រុងត្រង់ បម្រុងចំពោះ ធ្វើបម្រុង ឬដើម្បី ឧទ្ទិសចំពោះសង្ឃ។ **លំហាត់ទី3៖** ក. បុណ្យចូលឆ្នាំខ្មែរ

មេរៀនទី៥	**សំណេរ៖ រៀបរាប់ពីពិធីបុណ្យ**
រយៈពេល	3ម៉
វត្ថុបំណង	រៀបរាប់ពីពិធីបុណ្យអ្វីមួយបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី102 រូបភាពទំព័រ102
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** សិស្សសរសេរពាក្យក្នុងប្រអប់សៀវភៅទំព័រ102 **លំហាត់ទី2៖** (១)បុណ្យចូលឆ្នាំ(២)ទទួលទេវតា(៣)ត្រៃចីវរ(៤)បុណ្យភ្ជុំបិណ្ឌ (៥)បញ្ជូនកុសល

លំហាត់ទី3៖

ក. ខ្ញុំធ្លាប់បានចូលរួមពិធីបុណ្យបច្ច័យបួន។

ខ. គ្រួសាររបស់ខ្ញុំជាអ្នកផ្តើមបុណ្យ។ ធ្វើនៅផ្ទះរបស់ខ្ញុំ។ ធ្វើនៅមុនពេលបុណ្យចូលឆ្នាំ។

គ. គេធ្វើបុណ្យនេះដើម្បីបញ្ជូនកុសលដល់អ្នកដែលបានចែកឋានទៅនិងដើម្បីចម្រើនព្រះជន្មដល់ឪពុកម្តាយដែលមានវ័យចាស់ជរា។

ឃ. អារម្មណ៍សប្បាយរីករាយពេលបានឃើញពិធីបុណ្យនេះ។

លំហាត់ទី4៖

- បុណ្យកឋិនទាន
- ពេលវេលាចាប់ពីថ្ងៃទី១រោចខែអស្សុជ ដល់ថ្ងៃទី១៥កើតខែកត្តិក
- ទីកន្លែង វត្តនិងផ្ទះ
- សម្ភារៈបុណ្យ ត្រែ ទូ ត្រែ ចីវរ បាត្រ ឈើត្រាច់ គ្រឿងរណ្តាប់សូត្រមន្ត ក្លស់ ផ្លិត សម្ភារៈ ប្រើប្រាស់មួយចំនួនទៀត។

ជំពូកទី៩

ដំណាំនៅភូមិខ្ញុំ

រយៈពេល	7ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី១	ស្តាប់៖ រឿង ផ្លែឈើចម្លែក
មេរៀនទី២	អំណាន៖ មេសូត្រ៖ បន្លែនិងផ្លែឈើយើង
មេរៀនទី៣	សំណេរ៖ រៀបរាប់ពីការដាំដំណាំ

មេរៀនទី១	**ការស្តាប់៖ រឿង ផ្លែឈើចម្លែក**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីសារប្រយោជន៍នៃផ្លែឈើចម្លែកបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី104 ដល់ទំព័រទី105 រូបភាពទំព័រ104 ប័ណ្ណលំហាត់.....
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ24
ចម្លើយនៃសំណួរ	1. ភារីទៅបមកពីមើលការតាំងពិព័រណ៌។ 2. ភារីចាប់អារម្មណ៍លើដើមចេកស្រុកដែលមានផ្លែ100ស្និត។ 3. ឪពុកភារីនិយាយប្រាប់ភារីអំពីផ្លែល្ពៅចម្លែកមួយនៅប្រទេសអាមេរិច។ 4. ម្ចាស់ល្ពៅទទួលបានប្រាក់យ៉ាងច្រើនសន្ធឹកសន្ធាប់ពីផ្លែល្ពៅនោះ។
កំណែលំហាត់	**លំហាត់ទី1៖** គ. ព្រោះឃើញវត្ថុប្លែកៗជាច្រើន **លំហាត់ទី2៖** ខ. មានគំនិតបង្កើតស្នាដៃប្លែកៗ ដើម្បីបានយកមកដាក់តាំងពិព័រណ៌

មេរៀនទី២	**អំណាន៖ មេសូត្រ៖ បន្លែ និងផ្លែឈើយើង (បទពាក្យប្រាំពីរ)**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីសារប្រយោជន៍ បន្លែ និងផ្លែឈើបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី106 ដល់ទំព័រទី107 រូបភាពទំព័រ106 ប័ណ្ណលំហាត់
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
ចម្លើយនៃសំណួរ	1. នៅក្នុងសួនមាន ស្ពៃក្តោប ជីរ ម្រះ នរោង ត្រឡាច។ 2. ខ្ញុំចូលចិត្តសួនបន្លែព្រោះវាមានទិដ្ឋភាពស្អាត ផ្តល់ជាម្លប់ត្រជាក់និងផ្តល់ជាអាហារសម្រាប់យើងបរិភោគ។ 3. ការប្រើជីធម្មជាតិមិនខូចសុខភាព ចំណេញប្រាក់ ហូបដោយមិនមានការខ្វល់ខ្វាយ។

	4. ខ្ញុំចូលចិត្តត្រសក់ ត្រឡាច ននោង។
កំណែលំហាត់	**លំហាត់ទី1៖** ក. សន្សំ ខ . អន្លក់ គ. សន្ធឹក **លំហាត់ទី2៖** ក. ស្អេកស្គៈ (ន) ដៃលញឹកស្គៈលើគ្នា។ ខ. ឱដារស (គុ) ដៃលមានរសជាតិឆ្ងាញ់។ គ. សន្ធឹក (ន) សូរលាន់ឮខ្លាំង សូរសព្ទដៃលលាន់ឮពៃងគួរឱ្យស្ញើប។ ឧ. សន្ធឹកខ្យល់ព្យុៈ។ ឃ. ធម្មជាតិ (ន) អ្វីៗដៃលកើតមានឡើងដោយឯកឯង អ្វីៗដៃលនៅជុំវិញយើង។ **លំហាត់ទី3៖** ក. បទពាក្យប្រាំពីរ ខ. 3វគ្គ **លំហាត់ទី4៖** ក. ផ្ទៈ ចួន ម្រៈ ខ. ល្អៈ ចួន ស្គៈ គ. ក្លាំ ចួន ដាំ ឃ. សន្ធឹក ចួន ព្រឹក **លំហាត់ទី5៖** បន្លៃនិងផ្លៃឈើដៃលមានប្រយោជន៍ដល់សុខភាពមាន ល្ពៅ ននោង ត្រឡាច ត្រសក់ ត្រកួន...។

មេរៀនទី៣	**សំណេរ៖ រៀបរាប់ពីការដាំដំណាំ**
រយៈពេល	3ម៉
វត្ថុបំណង	រៀបរាប់ពីការដាំដំណាំអ្វីមួយបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី108 រូបភាពទំព័រ108
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** សិស្សចម្លងពាក្យនិងកន្សោមពាក្យក្នុងប្រអប់សៀវភៅទំព័រ108។ **លំហាត់ទី2៖** ដើម្បីដាំដំណាំមុនដំបូងត្រូវកាប់ដីបន្ទាប់មកជាក់ដីរួចយកកូនឈើមកដាំ ចុងបញ្ចប់ត្រូវស្រោចទឹក។ **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង) ក. ខ្ញុំចូលចិត្តដាំល្ពៅ។ ខ. ខ្ញុំដាំវានៅក្នុងចម្ការខាងក្រោយផ្ទៈ។ គ. គេដាំវានៅក្នុងរណ្តៅតូចៗដៃលមានចម្ងាយពីគ្នាប្រហៃល៣ម៉ែត្រ។ ឃ. គេថៃទាំវាដោយស្រោចទឹកបោចស្មៅ ជាក់ដី និងជ្រោយគល់។

ជំពូកទី១០

សត្វនៅភូមិខ្ញុំ

រយៈពេល	11ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី១	ស្តាប់៖ រឿង ឆ្កែនិងសេះ
មេរៀនទី២	និយាយ៖ ការពន្យល់អត្ថន័យនៃរូបគំនូរ
មេរៀនទី៣	វេយ្យាករណ៍៖ សញ្ញាបន្តក់(់)
មេរៀនទី៤	អំណាន៖ មេសូត្រ៖ គោខ្ចឹ
មេរៀនទី៥	សំណេរ៖ ពណ៌នាអំពីសត្វ

មេរៀនទី១	**ស្តាប់៖ រឿង ឆ្កែនិងសេះ**
រយៈពេល	2ម៉
វត្ថុបំណង	ពិចារណាឱ្យបានម៉ត់ចត់មុននឹងធ្វើអ្វីមួយ
សម្ភារៈឧបទេស	ស.ស ទំព័រទី110 ដល់ ទំព័រទី111 រូបភាពបុរសម្នាក់កំពុងវាយសេះ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ24
ចម្លើយនៃសំណួរ	1. ឆ្កែនិងសេះរស់នៅជាមួយអ្នកជ្រលក់ម្នាក់។ 2. ចោរចូលលួចអីវ៉ាន់អ្នកជ្រលក់នៅពេលយប់។ 3. ឆ្កែធ្វើមិនដឹងមិនឮព្រោះវាខឹងនឹងម្ចាស់វាមិនសូវគិតគូពីចំណីអាហាររបស់វាឡើយ។ 4. សេះស្រែកយ៉ាងខ្លាំង ដើម្បីឱ្យម្ចាស់ភ្ញាក់។ វាទទួលបាននូវការឈឺចាប់ដោយម្ចាស់វាយយ៉ាងដំណាំ។ 5. បានជាអ្នកជ្រលក់នោះវាយសេះ ព្រោះសេះធ្វើឱ្យដាច់ដំណេករបស់គាត់។ 6. អ្នកជ្រលក់វាយសេះជាទង្វើមិនត្រឹមត្រូវទេ ព្រោះមុនធ្វើអ្វីត្រូវចេះពិចារណាសិន។ 7. ត្រូវស្រឡាញ់ថែរក្សាឱ្យចំណីឱ្យបានគ្រប់គ្រាន់។
កំណែលំហាត់	**លំហាត់ទី1៖** គ. រឹងរូសមិនធ្វើតាមតួនាទីរបស់ខ្លួន **លំហាត់ទី2៖** គ. ចោរនឹងលួចទ្រព្យអស់ ហើយម្ចាស់ត្រូវវាយឆ្កែ **លំហាត់ទី3៖** ខ. ត្រូវពិចារណាឱ្យច្បាស់លាស់មុននឹងខឹង

មេរៀនទី២	**និយាយ៖ ការពន្យល់អត្ថន័យនៃរូបគំនូរ**
រយៈពេល	2ម៉
វត្ថុបំណង	ពន្យល់អត្ថន័យនៃរូបគំនូរបានត្រឹមត្រូវ។

សម្ភារឧបទេស	ស.ស ទំព័រទី112 ដល់ទំព័រទី113 រូបភាពជំងឺផ្តាសាយបក្សី
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ25
ចម្លើយនៃសំណួរ	1. ដើម្បីបកស្រាយអត្ថន័យនៃផ្នាំងគំនូរគេសង្កេតលើចំណងជើង មើលរូបភាព។ 2. ធីតាពន្យល់ឃុត្តាអំពីផ្នាំងគំនូរ។ 3. ផ្នាំងគំនូរនេះបង្ហាញការហាមប៉ះពាល់មាន់ ឬទាងាប់។ 4. មុនពេលបកស្រាយអត្ថន័យនៃផ្នាំងគំនូរធីតាបានណែនាំឃុត្តាឱ្យសង្កេតចំណងជើង និងរូបភាព។ 5. ធីតាបកស្រាយអត្ថន័យនៃផ្នាំងគំនូរនោះថាៈផ្នាំងរូបភាពនេះមានន័យថាហាមប៉ះពាល់មាន់ទាដែលងាប់ព្រោះវាអាចឆ្លងជំងឺផ្តាសាយបក្សីមកមនុស្ស។
កំណែលំហាត់	**លំហាត់ទី1ៈ** ខ. យល់ដឹង ឃ. ចូលរួមអនុវត្ត **លំហាត់ទី2ៈ** ក. នៅលើពិភពគ្មានអ្នកជក់បារី។ ខ. មិនត្រូវចោលសំរាមផ្តេសផ្តាសនៅទីសាធារណៈ។ គ. ការការពារពីជំងឺផ្តាសាយបក្សី។ ឃ. កុំដើរជាន់ស្មៅនៅសួនច្បារនានា។

មេរៀនទី៣	**វេយ្យាករណ៍ៈ សញ្ញាបន្តក់** (◌់)
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រើប្រាស់សញ្ញាបន្តក់ (◌់) បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស ទំព័រទី114 ដល់ទំព័រទី115 រូបភាពៈ ត្រីក្រាញ់ ត្រីផ្នក់ ត្រប់ ខាត់ណា ត្រសក់ ប័ណ្ណពាក្យៈ ត្រីក្រាញ់ ត្រីផ្នក់ ត្រប់ ខាត់ណា ត្រសក់...
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ21
កំណែលំហាត់	**លំហាត់ទី1ៈ** ខ. ក ង ច ញ ត ន ប ល ស **លំហាត់ទី2ៈ** ក. កង់ ខ. ក្តាន់ គ. ពស់ ឃ. ត្រប់ **លំហាត់ទី3ៈ** ក. ចាន់ ចម្លាក់ ខេត្តពោធិ៍សាត់ ខ. ខេត្តបាត់ដំបង សាច់ត្រី គ. កក់ រត់ ជាន់ គីង្គក់ ឃ. រមាស់ រាល់ថ្ងៃ **លំហាត់ទី4ៈ** (ចម្លើយជាក់ស្តែង) មាន់ ទាន់ មួយ ពាន់ ជាន់ កាន់ ហាត់ រំពាត់ ហាប់ ញាស់ ទាស់

មេរៀនទី៤	**អំណានៈ មេសូត្រៈ គោខ្ចុំ (បទកាកគតិ)**

រយៈពេល	2ម៉ោ
វត្ថុបំណង	ពណ៌នាពីសត្វគោបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស ទំព័រ116 ដល់ទំព័រទី117 រូបភាពរូបគោឈ្មោល ប័ណ្ណពាក្យ៖ ខ្ពស់ ខ្លួន ស្នែង កម្លាំង ធ្វើ ម្ខាស់ ក្តួរ វស្សា
ជំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ23
ចម្លើយនៃសំណួរ	1. អាត្មោតមានខ្លួនមាំ មាឌធំ រាងខ្ពស់ស្រឡះ ស្នែងប្រក់នាគបូកមូលកក្រាស់។ 2. គោនោះមានលក្ខណៈសម្បត្តិដូចជា ដំណើរហ័ស កម្លាំងខ្លាំង ចេះ។ 3. គោផ្តល់ផលប្រយោជន៍ដល់មនុស្សដូចជា ជួយកម្លាំងមនុស្សនិងផ្តល់សាច់ជាអាហារ។
កំណែលំហាត់	**លំហាត់ទី1៖** ក. រហ័ស (គុ) ដែលលឿន ដែលឆាប់រួសរាន់។ ខ. កម្លាំង (ន) អំណាចធាតុដែលធ្វើអោយវៈឱ្យកម្រើក។ គ. វស្សា (ន) រដូវភ្លៀង។ ឃ. ស្នែង (ន) អវយវៈមានសាច់រឹងស្និទ្ធដុះលើក្បាលសត្វពួកខ្លះ មានគោក្របីជាដើម។ **លំហាត់ទី2៖** ក. ២ វគ្គ ខ. រូបរាង គ. ផលប្រយោជន៍ **លំហាត់ទី3៖** វគ្គទី១៖ ខ្ពំ ចួន ធំ ស្រឡះ ចួន ក្រាស់ រហ័ស វគ្គទី២៖ ណាស់ ចួន ម្ខាស់ ចម្ការ ចួន ហិចតា វស្សា ឆ្លងវគ្គ៖ ខ្លាំងក្លា ចួន ហិចតា វស្សា ស្រឡះ ចួន ក្រាស់ រហ័ស ណាស់

មេរៀនទី៥	**សំណេរ៖ ពណ៌នាអំពីសត្វ**
រយៈពេល	3ម៉ោ
វត្ថុបំណង	រៀបរាប់ពីរូបរាងនិងផលប្រយោជន៍សត្វគោបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស ទំព័រ118 ដល់ទំព័រទី119 រូបភាពរូបគោឈ្មោល ប័ណ្ណពាក្យ៖ ខ្ពស់ ខ្លួន ស្នែង កម្លាំង ធ្វើ ម្ខាស់ ក្តួរ វស្សា
ជំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ26
ចម្លើយនៃសំណួរ	
កំណែលំហាត់	**លំហាត់ទី1៖** សិស្សសរសេរពាក្យក្នុងប្រអប់សៀវភៅទំព័រ118។

លំហាត់ទី2៖ (១)ទូលូ (២)ធំ (៣)ខ្មៅ (៤)វែង (៥) វែង (៦)ផ្ទះ (៧)ផ្ទះ (៨)ព្រុស (៩)ម្ចាស់ (១០) វា(១១) ទទួល (១២)ដៃ ជើង (១៣)វា

លំហាត់ទី3៖

ក. អ្នកទេសចរដិះរទេះសេះដើរកម្សាន្ត។

ខ. ពូពេញភ្ជួរដីចម្ការ។

លំហាត់ទី4៖ (ចម្លើយជាក់ស្តែង)

- ខ្ញុំធ្លាប់ឃើញគោនៅឯស្រុកស្រែចម្ការវាមានឈ្មោះ អាចំប៉ា។
- វាមានមាឌធំមាំកម្ពស់ប្រហែល.....ម៉ែត្រ។
- គោនោះមានសម្បុរស មានរោមខ្លីៗស្នែងកោងខ្លុប។
- គោនោះមានចរិតស្លូត។
- យើងត្រូវឱ្យស្មៅវាស៊ីឲ្យទឹកផឹកនិងដុសលាងសម្អាតវា។
- វាផ្តល់ប្រយោជន៍ក្នុងការភ្ជួររាស់ស្រែចម្ការនិងអូសទាញ។

ជំពូកទី១១

កីឡានិងល្បែងកម្សាន្ត

រយៈពេល	18ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី១	បំណិន៖ ព្រឹត្តិការណ៍នៃរឿង
មេរៀនទី២	អំណាន៖ រឿង យ៉ារីមើលថែប្អូន
មេរៀនទី៣	បំណិន៖ ចរិតលក្ខណៈរបស់តួអង្គ
មេរៀនទី៤	បំណិន៖ ការប៉ាន់ស្មានហេតុការណ៍ដែលកើតឡើងបន្ទាប់
មេរៀនទី៥	ស្តាប់៖ រឿង ទន្សាយចាញ់ប្រាជ្ញខ្សង
មេរៀនទី៦	វេយ្យាករណ៍៖ នាមសាធារណៈ ឬសាធារណៈនាម
មេរៀនទី៧	អំណាន៖ កីឡានិងល្បែងមានសុវត្ថិភាព
មេរៀនទី៨	អំណាន៖ រឿង ជ័យជម្នះរបស់តុលា
មេរៀនទី៩	និយាយ៖ ការណែនាំអំពីការលេងល្បែង

មេរៀនទី១	**បំណិន៖ ព្រឹត្តិការណ៍នៃរឿង**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីព្រឹត្តិការណ៍នៃរឿងបានត្រឹមត្រូវ។
សម្ភារៈឧបទេស	ស.ស ទំព័រទី120 ដល់ទំព័រទី 121
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ21
កំណែលំហាត់	**លំហាត់ទី1៖** ខ. 2ព្រឹត្តិការណ៍ **លំហាត់ទី2៖** ឃ. ណានិងជួយសង្គ្រោះអ្នកលង់ទឹក

មេរៀនទី២	**អំណាន៖ រឿង យ៉ារីមើលថែប្អូន**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីសកម្មភាពទទួលខុសប្អូនរបស់ខ្លួនបានត្រឹមត្រូវ។
សម្ភារៈឧបទេស	ស.ស ទំព័រទី122 ដល់ទំព័រទី123 រូបភាពទំព័រ 122 បំណ្ណពាក្យ៖ ដណ្តើម កន្ត្រែ ប្រយ័ត្ន បន្ទោស សុវត្ថិភាព ...
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
ឆ្លើយនៃសំណួរ	1. យ៉ារីនៅចាំផ្ទះនិងមើលប្អូន។ 2. បានជាប្អូនយ៉ារីមុតដៃ ពីព្រោះយ៉ារីទុកដាក់ កន្ត្រែកាំបិតរាយប៉ាយជុំវិញខ្លួន។

	3. ម្តាយយ៉ារីបានទូន្មាននាងថា ការលេងដោយប្រើវត្ថុមានមុខមុត ចុងស្រួចវានាំឱ្យមានគ្រោះថ្នាក់បើយើងមិនប្រុងប្រយ័ត្ន។ 4. ដើម្បីមើលថែប្អូនឱ្យមានសុវត្ថិភាព ខ្ញុំត្រូវនាំប្អូនលេងល្បែងណាដែលមានសុវត្ថិភាព។
កំណែលំហាត់	**លំហាត់ទី1៖** សិស្សបើកសៀវភៅទំព័រ123ចម្លងពាក្យក្នុងប្រអប់។ **លំហាត់ទី2៖** ក. ដណ្តើម ខ. កន្ត្រៃ គ. ប្រយ័ត្ន ឃ. បន្ទោស ង. សុវត្ថិភាព **លំហាត់ទី3៖** ក. ប្រយ័ត្ន (ន) ការប្រុងដោយមិនធ្វេសប្រហែស ។ ខ. ភ័យ (ន) សេក្តីខ្លាច; ហេតុ ឬដំណើរដែលគួរខ្លាច។ គ. បន្ទោស (កិ) ស្តីឱ្យដោយគ្រាន់តែប្រាប់ទោសកំហុសឥតមានដេរវាយ ឬធ្វើទោសអ្វី។ ឃ. សុវត្ថិភាព (ន) ការប្រកបដោយសេចក្តីសុខ។ **លំហាត់ទី4៖** 1. ក 2. គ 3. ឃ 4. ខ

មេរៀនទី៣	**បំណិន៖ ចរិតលក្ខណៈរបស់តួអង្គ**
រយៈពេល	2ម៉ោ
វត្ថុបំណង	កំណត់ពីចរិតលក្ខណៈរបស់តួអង្គបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស ទំព័រទី124ដល់ទំព័រទី125
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ21
កំណែលំហាត់	**លំហាត់ទី1៖** ខ. ស្លូតត្រង់ ចិត្តធ្ងន់ **លំហាត់ទី2៖** ខ. ល្មោភសុី **លំហាត់ទី3៖** ខ. ជាកូនល្អគិតគូរដល់ម្តាយ

មេរៀនទី៤	**បំណិន៖ ការប៉ាន់ស្មានហេតុការណ៍ដែលកើតឡើងបន្ទាប់**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប៉ាន់ស្មានហេតុការណ៍ដែលកើតឡើងបន្ទាប់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស ទំព័រ126 ដល់127
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ21
កំណែលំហាត់	**លំហាត់៖** ខ. មេហ៊ឹងបែកពោះស្លាប់

មេរៀនទី៥	**ស្តាប់៖ រឿង ទន្សាយនិងខ្យង**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីភាពឆ្លាតវៃរបស់សត្វខ្យងបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស ទំព័រ128 ដល់ទំព័រទី129 រូបភាពទំព័រទី128

ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ24
ឆ្លើយនៃសំណួរ	1. បានជាទន្សាយរត់ប្រណាំងជាមួយខ្យង ពីព្រោះទន្សាយមកផឹកទឹកត្រពាំង។ 2. រឿងទន្សាយចាញ់ប្រាជ្ញខ្យងកើតឡើងនៅមាត់ត្រពាំង ពេលទន្សាយមកផឹកទឹកត្រពាំង។ 3. ដើម្បីយកឈ្នះទន្សាយ ខ្យងបានប្រើកលល្បិចបណ្តាក់គ្នាក្នុងទឹកជុំវិញមាត់ត្រពាំង។ 4. ការរត់ប្រណាំងរវាងទន្សាយនិងខ្យងក្នាល់គ្នាថា៖ បើអ្នកណាចាញ់អ្នកនោះនឹងត្រូវឈប់ផឹកទឹកត្រពាំងជារៀងរហូត។ 5. ក្រោយពីបានស្តាប់រឿងនេះរួចមក ខ្ញុំស្រឡាញ់តួអង្គខ្យង ព្រោះខ្យងមិនអួតអាងហើយមានប្រាជ្ញា។ 6. រឿងនេះអប់មិនឱ្យមានអំនួតលើខ្លួនលើខ្លួនឯងនិងមិនត្រូវមាក់ងាយអ្នកដទៃ។ ការមាក់ងាយអ្នកដទៃនាំឱ្យវិនាស។
កំណែលំហាត់	**លំហាត់ទី1៖** ក. ខ្យងបបួលទន្សាយរត់ប្រណាំងគ្នា។ ខ. ទន្សាយនិងខ្យងរត់ប្រណាំងគ្នាជុំវិញត្រពាំង។ **លំហាត់ទី2៖** ក. ខ្យងជាតួអង្គមានប្រាជ្ញា **លំហាត់ទី3៖** គ. ជាតួអង្គមានអំនួតចំពោះខ្លួនឯង។

មេរៀនទី៦	**វេយ្យាករណ៍៖ នាមសាធារណ៍ ឬសាធារណនាម**
រយៈពេល	2ម៉
វត្ថុបំណង	ប្រើប្រាស់នាមសាធារណ៍ ឬសាធារណ៍នាមបានត្រឹមត្រូវ ។
សម្ភារឧបទេស	ស.ស ទំព័រទី130 ដល់ទំព័រទី131 រូបភាព៖ វត្ថុ រុក្ខជាតិ មនុស្ស សត្វ ប័ណ្ណពាក្យ៖ បង្កើតតាមរូបភាពដែលលោកគ្រូ អ្នកគ្រូបង្កើតបាន
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ21
កំណែលំហាត់	**លំហាត់ទី1៖** ក. សិស្សានុសិស្ស កីឡា ខេត្ត ខ. កុមារ ល្បែងកម្សាន្ត សាលារៀន គ. ប្រជាជន ល្បែងប្រជាប្រិយ ឃ. ឆ្កែ **លំហាត់ទី2៖** ក. ខេត្ត ខ. ក្មេងៗ គ. ក្តាម ឃ. សៀវភៅ ង. ឆ្កែ ច. ទីក្រុង **លំហាត់ទី3៖** ផ្ទះ ប្អូន កន្ត្រែ ផ្កា កាំបិត ល្បែង ពណ៌ ភាសា ក្រដាស រឿង

មេរៀនទី៧	**អំណាន៖ កីឡានិងល្បែងមានសុវត្ថិភាព**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីកីឡានិងល្បែងទាំងឡាយណាដែលមានសុវត្ថិភាពបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស ទំព័រទី132 ដល់ទំព័រទី133

	រូបភាពទំព័រទី132
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
ឆ្លើយនឹងសំណួរ	1. ល្បែងកម្សាន្តនាំមកនូវភាពសប្បាយរីករាយ សាមគ្គីភាព ការលូតលាស់ផ្នែកប្រាជ្ញាជាដើម។ 2. ល្បែងកម្សាន្តដែលគួរចៀសវាងមានដូចជា ឡើងដើមឈើ លោតទឹក ព្រោះវាបង្កឱ្យមានគ្រោះថ្នាក់។ 3. ល្បែងកម្សាន្ត ដែលគួរលេងមានដូចជា លោតកៅស៊ូ លោតមឹក វាយសី... ព្រោះវាមានសុវត្ថិភាពនិងធ្វើឱ្យសុខភាពល្អ 4. ល្បែងដែលធ្វើឱ្យមានសុខភាពល្អហើយមានសុវត្ថិភាពដល់រាងកាយដូចជា វាយសី លេងរែក លេងអុក លេងបាយខុំនិងលេងលោតអន្ទាក់។
កំណែលំហាត់	**លំហាត់ទី1៖** ក. អន្ទាក់ ខ. កម្សាន្ត គ. អន្តរាយ ឃ. សមរម្យ **លំហាត់ទី2៖** ក. ប្រាជ្ញា (ន) ការយល់ដាក់ច្បាស់។ ខ. អន្តរាយ (ន) ដំណើរខូចប្រយោជន៍, ការខូចបង់សៀត, សេចក្តីវិនាស។ គ. សមរម្យ (គុ) ដែលត្រូវបែបបទមិនទាស់ភ្នែក។ ឃ. ពិចារណា (ន) ការត្រិះរិះ, រំពឹង, គិតគ្នេរ។ **លំហាត់ទី3៖** គ. ល្បែងដែលមានសុវត្ថិភាព **លំហាត់ទី4៖** កុមារ ដើមឈើ ផ្លូវ ល្បែងកម្សាន្ត

មេរៀនទី៨	**អំណាន៖ រឿង ជ័យជម្នះរបស់តុលា**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីមូលហេតុដែលធ្វើឱ្យតុលាមានជ័យជម្នះបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស ទំព័រទី134ដល់ទំព័រទី135 រូបភាពទំព័រទី134 បណ្ណាពាក្យ៖ កន្ត្រួល សរសើរ ជ័យជម្នះ ដំបូន្មាន...
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
ឆ្លើយនឹងសំណួរ	1. បានជាតុលាទទួលបរាជ័យក្នុងការរត់ប្រណាំងលើកទី១ ព្រោះតុលាមានរាងធាត់កន្ត្រួល ក្បាលពោះសុទ្ធតែខ្លាញ់ភ្នែកលឺបដំណើរអ៊ឹកអ៊ាកៗ។ 2. អ្នកគ្រូបានណែនាំតុលា ហាត់ប្រាណឱ្យបានទៀងទាត់និងលេងកីឡា។ 3. បានជាតុលាទទួលជ័យជម្នះក្នុងការរត់ប្រណាំងលើកទី២ ព្រោះតុលាបានហ្វឹកហាត់តាមដំបូន្មានអ្នកគ្រូ។ 4. ការហាត់ប្រាណទៀងទាត់ផ្តល់នូវ សុខភាពល្អនិងរាងកាយរឹងមាំ។
កំណែលំហាត់	**លំហាត់ទី1៖**ក. កន្ត្រួល ខ. ដង្ហើម គ. អង្គុយ ឃ. ដំបូន្មាន **លំហាត់ទី2៖**

	ក. សរសើរ (កិ) និយាយលើកតម្កើង។ ខ. ជំយជម្នះ (ន) ការឈ្នះ។ គ. ដំបូន្មាន (ន) សេចក្តីទូន្មាន, ឱវាទ, ពាក្យប្រដៅ។ **លំហាត់ទី3៖** ក. ការត់ប្រណាំងលើកទី1និងការត់ប្រណាំងលើកទី2 ខ. ព្យាយាម

មេរៀនទី៩	**និយាយ៖ ការណែនាំអំពីការលេងល្បែង**
រយៈពេល	2ម៉
វត្ថុបំណង	ណែនាំអំពីការលេងល្បែងអ្វីមួយបានត្រឹមត្រូវ។
សម្ភារៈបច្ចេកទេស	ស.ស ទំព័រទី136
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ25
ឆ្លើយនឹងសំណួរ	1. តារាណែនាំល្បែងក្រពើដេញចាប់។ 2. អ្នកប៉ាវចាញ់ត្រូវឈរនៅក្នុងស្នឹងធ្វើជាក្រពើ។
កំណែលំហាត់	**លំហាត់ទី1៖** សិស្សនិទានរឿង ក្រពើដេញចាប់ឡើងវិញរៀងខ្លួន **លំហាត់ទី2៖** ដើម្បីលេងល្បែងដណ្តើមស្លឹកឈើបានត្រឹមត្រូវយើងត្រូវ៖ មុនដំបូងយើងត្រូវចែកគ្នាជាពីក្រុមដោយក្នុងមួយក្រុមៗមានចំនួនមនុស្សស្មើគ្នាហើយត្រូវមានអាជ្ញាកណ្តាលម្នាក់និងស្លឹកឈើមួយមែកតូចល្មម។ បន្ទាប់មកក្រុមទាំងពីរត្រូវរាប់លេខរៀងដូចគ្នា។ បន្ទាប់មកទៀតអាជ្ញាកណ្តាលហៅលេខនៃក្រុមទាំងពីរម្តងមួយគូ ដើម្បីមកដណ្តើមស្លឹកឈើដែល នៅកណ្តាលទី។ បើគូនោះមិនអាចដណ្តើម អាជ្ញាកណ្តាលត្រូវហៅគូផ្សេងទៀតមកជួយ រហូតដល់ដណ្តើមបាន។ សម្រាប់គូបន្ទាប់ត្រូវអនុវត្តដូចមុនដដែល។

ជំពូកទី១២

សហគមន៍ជឿនលឿន

រយៈពេល	13ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី១	បំណិន៖ តួអង្គនិងកាលអាកាស
មេរៀនទី២	អំណាន៖ រឿង គ្រូពេទ្យភូមិយើង
មេរៀនទី៣	បំណិន៖ បរិបទបញ្ជាក់ ឬទីសេចក្តីបញ្ជាក់
មេរៀនទី៤	អំណាន៖ សមាគមវាយនភ័ណ្ឌ
មេរៀនទី៥	អំណាន៖ សហគមន៍ថ្មី
មេរៀនទី៦	សំណេរ៖ តួនាទីសាមជិកក្នុងសហគមន៍

មេរៀនទី១	**បំណិន៖ តួអង្គនិងកាលអាកាស**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រាប់ពីតួអង្គនិងកាលអាកាសបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស ទំព័រ138ដល់ទំព័រ139
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	1. តួអង្គឯកជាតួអង្គសំខាន់បំផុត ហើយមានសកម្មភាពច្រើនជាងគេនៅក្នុងដំណើររឿងទាំងមូល។ 2. តួអង្គរងជាតួអង្គដែលពុំសូវសំខាន់។ 3. កាលអាកាសគឺជាពេលវេលានិងទីកន្លែងដែលដំណើររឿងប្រព្រឹត្តទៅ។
កំណែលំហាត់	**លំហាត់៖**

ចំណងជើងរឿង	ព្រះថោងនាងនាគ
តួអង្គឯក	ព្រះថោងនិងនាងនាគ
តួអង្គរង	ស្តេចនាគ
កាល	កាលពីសម័យមុន
អាកាស	នៅលើកោះមួយ

មេរៀនទី២	**អំណាន៖ រឿង គ្រូពេទ្យភូមិយើង**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីសកម្មភាពរបស់គ្រូពេទ្យក្នុងភូមិបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស ទំព័រ140 ដល់ទំព័រ 141

	រូបភាពទំព័រ 140 ប័ណ្ណពាក្យ៖ មណ្ឌលសុខភាព បារម្ភ ពិនិត្យ គ្រាហ៍...
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
ឆ្លើយនឹងសំណួរ	1. ក្នុងអត្ថបទនេះមានតួអង្គ៖ ជីដូន ម្តាយ អ្នកជិតខាង ពូប្រធានភូមិ លោកគ្រូពេទ្យ 2. អ្នកដែលជាតួអង្គឯកគឺ៖ លោកគ្រូពេទ្យ។ អ្នកដែលជាតួអង្គរង៖ ម្តាយ យាយនិង ពូប្រធានភូមិ។ 3. រឿងនេះកើតឡើងនៅមណ្ឌលសុខភាពភូមិយើង។ នៅពេលយប់។
កំណែលំហាត់	**លំហាត់ទី1៖** ក. ស្មារតី ខ. មណ្ឌល គ. ពិនិត្យ ឃ. បារម្ភ **លំហាត់ទី2៖** ក. បារម្ភណ៍ (ន) ជំណើរនឹកព្រួយទុកជាមុន។ ខ. ពិនិត្យ (កិ) សង្កេតមើលដោយល្អិតល្អន់។ គ. គ្រាហ៍ (កិ) ជំណើរអង។ **លំហាត់ទី3៖** ក. ជីដូនខ្ចុំគ្រុនក្តៅខ្លាំង រហូតដល់សន្លប់បាត់ស្មារតី។ គ. អ្នកជិតខាងភ័យស្លន់ស្លោនឹងជំងឺលោកយាយ។ ឃ. ប្រធានភូមិខ្នះខ្នែងជូនលោកយាយទៅមណ្ឌលសុខភាព។ ង. គ្រូពេទ្យពិនិត្យព្យាបាលលោកយាយរហូតជាសះស្បើយ។

មេរៀនទី៣	**បំណិន៖ បរិបទបញ្ជាក់ ឬទីសេចក្តីបញ្ជាក់**
រយៈពេល	2ម៉
វត្ថុបំណង	ប្រើប្រាស់បរិបទបញ្ជាក់ ឬទីសេចក្តីបញ្ជាក់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស ទំព័រ142 ដល់143 ប័ណ្ណពាក្យ៖ សិប្បកម្ម នេសាទុបករណ៍ ...
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ21
ឆ្លើយនឹងសំណួរ	1. ដែលហៅថាបរិបទបញ្ជាក់ ឬទីសេចក្តីបញ្ជាក់របស់ពាក្យគឺជាពាក្យ ឃ្លា ឬល្បះដែលនៅជុំវិញ(ខាងមុខ ខាងក្រោយ)ពាក្យនោះហើយជួយឱ្យន័យពាក្យពិបាកនោះ។ 2. បរិបទបញ្ជាក់ ឬទីសេចក្តីបញ្ជាក់របស់ពាក្យណាមួយនោះគឺស្ថិតនៅខាងមុខ ខាងក្រោយពាក្យនោះហើយជួយឱ្យន័យពាក្យពិបាកនោះ។
កំណែលំហាត់	**លំហាត់ទី1៖** ក. កណ្តៀង ទទឹម ខ. ពួកគេទៅរៀនបន្ថែម គ. គោរពបូជា **លំហាត់ទី2៖** ក. ទឹកឈូ ឆ្នេរសមុទ្រ ខ. កន្លែងសម្រាប់បណ្តុះបណ្តាល។

	គ. ការធ្វើដំណើរទៅមក។

មេរៀនទី៤	**អំណាន៖ សមាគមវាយនកម្ម**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីការបង្កើតសមាគមថ្មីបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស ទំព័រ144 ដល់145 រូបភាពទំព័រ144 ប័ណ្ណពាក្យ៖ ពលរដ្ឋ សមាគម វាយនកម្ម តម្លៃ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
ឆ្លើយនឹងសំណួរ	1. ប្រជាជនបានបង្កើតសមាគមវាយនកម្ម។ 2. គេជ្រើសរើសតំណាងសមាគមដោយធ្វើការបោះឆ្នោត។ 3. គេបង្កើតសមាគម ដើម្បីងាយស្រួលលក់ផលិតផលគ្រប់ប្រភេទនិងទទួលបានតម្លៃខ្ពស់។ 4. ដើម្បីសមាគមជឿនលឿន គេត្រូវទទួលការអភិវឌ្ឍនិងការពារផលប្រយោជន៍រួមរបស់សមាគម។
កំណែលំហាត់	**លំហាត់ទី1៖** ក. ពលរដ្ឋ ខ. សមាគម គ. វាយនកម្ម ឃ. តម្លៃ **លំហាត់ទី2៖** ក. អប់រំសុខភាព គ្រោះមហន្តរាយ ការបោះឆ្នោត ខ. បង្រៀន

មេរៀនទី៥	**អំណាន៖ សហគមន៍ថ្មី**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីសហគមន៍ថ្មីបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស ទំព័រ146 ដល់147 រូបភាពទំព័រទី146 ប័ណ្ណពាក្យ៖ សហគមន៍ ហេដ្ឋារចនាសម្ព័ន្ធ បង្ហូរ សុខភាព
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
ឆ្លើយនឹងសំណួរ	1. សហគមន៍នេះស្ថិតនៅតំបន់ជាប់ស្រយាល។ 2. ប្រជាជននៅក្នុងសហគមន៍នោះជាមនុស្ស ចេះដឹង ឧស្សាហ៍ព្យាយាមមានគំនិតជឿនលឿន។ 3. នៅក្នុងសហគមន៍នេះមាន ផ្លូវថ្នល់ ស្ពាន ប្រឡាយទឹក លូបង្ហូរទឹក សាលារៀន។ 4. ពួកគេចូលចិត្តស្តាប់ព័ត៌មានទាក់ទងនឹងការអប់រំ បញ្ហាសុខភាព និងខិតខំរៀនបច្ចេកទេសកសិកម្មថ្មី។ 5. បានជាពួកគេមិននិយមប្រើហិង្សា ព្រោះអ្នកស្រុកនេះភាគច្រើនជាមនុស្សចេះដឹងមានគំនិតជឿនលឿន ជាមនុស្សសន្តិភាពនិយម។

កំណែលំហាត់	**លំហាត់ទី1៖** ក. សហគមន៍ ខ. ហេដ្ឋារចនាសម្ព័ន្ធ គ. បង្ហូរ ឃ. សុខភាព **លំហាត់ទី2៖** ក. អហិង្សា ≠ ហិង្សា ខ. សន្តិភាព ≠ សង្គ្រាម គ. ឆ្ងាយ ≠ ជិត ឃ. ច្រើន ≠ តិច **លំហាត់ទី3៖** ផ្លូវថ្នល់ ស្ពាន ប្រឡាយទឹក លូបង្ហូរទឹក សាលារៀន មណ្ឌលសុខភាព សាលាឃុំ និងផ្សារ

មេរៀនទី៦	**សំណេរ៖ តួនាទីសមាជិកក្នុងសហគមន៍**
រយៈពេល	3ម៉ោ
វត្ថុបំណង	រៀបរាប់ពីតួនាទីរបស់សមាជិកក្នុងសហគមន៍បានត្រឹមត្រូវ។
សម្ភារៈឧបទេស	ស.ស ទំព័រទី148 រូបភាពទំព័រ148
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** សៀវភៅសិស្សទំព័រ150ចម្លងពាក្យក្នុងប្រអប់ **លំហាត់ទី2៖** ក. ផ្លូវ ខ. ដាំដំណាំ គ. ព្រៃឈើ **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង) ក. ម្តាយខ្ញុំកំពុងបាចជីជាក់ស្រូវឱ្យលូតលាស់ល្អ។ ខ. ពូចាន់ ពូជានិងអ៊ំជន់កំពុងជួសជុលផ្លូវ។ គ. ប្រជាជននៅភូមិខ្ញុំសុទ្ធតែជាអ្នកមានការព្យាយាមក្នុងការងារ។ ឃ. អ្នកភូមិខ្ញុំស្រឡាញ់បរិស្ថានគ្រប់ៗគ្នា។ **លំហាត់ទី4៖** (ចម្លើយជាក់ស្តែង) ក. ប្រធានភូមិមានតួនាទីសម្របសម្រួលបញ្ហារបស់ប្រជាពលរដ្ឋ។ ខ. ភូមិខ្ញុំស្ថិតនៅជិតមណ្ឌលសុខភាព។ គ. រាល់ថ្ងៃខ្ញុំទៅរៀនដោយជិះកង់។ ឃ. នៅក្នុងសហគមន៍ខ្ញុំមានមណ្ឌលសុខភាព សាលារៀន វត្ត និងផ្សារ។

ជំពូកទី១៣

ការគួរសម

រយៈពេល	21ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី១	អំណាន៖ ការគោរពឪពុកម្តាយ
មេរៀនទី២	សំណេរ៖ ទម្រង់នៃការសរសេរកថាខណ្ឌ
មេរៀនទី៣	ស្តាប់៖ រឿង សេដ្ឋី និងអ្នកលក់ធ្យូង
មេរៀនទី៤	បំណិន៖ ដំណើររឿងនិងព្រឹត្តិការណ៍សំខាន់ៗនៃរឿង
មេរៀនទី៥	អំណាន៖ រឿង កុមារចេះគួរសម
មេរៀនទី៦	វេយ្យាករណ៍៖ អត្ថន្តរសញ្ញា ឬសញ្ញាក្បៀសបើកបិទ «...»ឬ “...”
មេរៀនទី៧	អំណាន៖ មេសូត្រ៖ ច្បាប់ប្រុស
មេរៀនទី៨	សំណេរ៖ សំណេរកថាខណ្ឌ
មេរៀនទី៩	សំណេរ៖ ការសរសេររឿងខ្លី

មេរៀនទី១	**អំណាន៖ ការគោរពឪពុកម្តាយ**
រយៈពេល	2ម៉ោ
វត្ថុបំណង	គោរពឪពុក ម្តាយបានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស. ទំព័រទី150ដល់ទី151 រូបភាពទំព័រ150
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. ពេលឪពុកម្តាយហៅកូន កូនត្រូវឆ្លើយបាទ ឬចាស។ 2. ពេលឪពុកម្តាយនិយាយ កូនត្រូវយកចិត្តទុកដាក់ស្តាប់ដោយទឹកមុខញញឹម។ 3. កូនត្រូវចៀសវាងនូវចរិតរឹងរូសមិនស្តាប់ដំបូន្មានឪពុកម្តាយនិងនិយាយកុហកលោកទាំងពីរឡើយ។ 4. មុនពេលទៅនិងត្រឡប់មកពីសាលារៀនវិញ កូនត្រូវជម្រាបសួរ ពុកម៉ែ ឬប៉ាម៉ាក់! កូនទៅរៀនហើយ ឬកូនមកពីរៀនវិញហើយ។ 5. បើកូនចង់ទៅណាមកណាកូនត្រូវជម្រាបគាត់ឱ្យបានសមរម្យថាយើងទៅណាទៅជាមួយអ្នកណា ទៅធ្វើអ្វី ពេលណាត្រឡប់វិញ។
កំណែលំហាត់	**លំហាត់ទី1៖** ក. ឥរិយាបថ ខ. ឫកពា គ. ដំបូន្មាន ឃ. អាកប្បកិរិយា **លំហាត់ទី2៖** ក. ឥរិយាបថ (ន) ការដើរ ដេក ឈរ អង្គុយ

	ខ. ប្រសាសន៍ (ន) ពាក្យផ្តាំផ្ញើ។ គ. អាកប្បកិរិយា (ន) ដំណើរបែបភាពនៃរាងកាយ។ ឃ. ឫកពា (ន) បែបបទ សណ្តាប់ធ្នាប់ (រូបកាយ) ឧ. សុភាពមានឫកពាសមរម្យ។ **លំហាត់ទី3៖** អ្នកត្រូវមានឥរិយាបថ ដេក ដើរ ឈរ អង្គុយ ឱ្យបានត្រឹមត្រូវ **លំហាត់ទី4៖** កូនល្អគឺជាកូន ដែលស្តាប់តាមដំបូន្មានមាតាបិតា មានឫកពាសមរម្យមិន និយាយកុហក គោរពស្រឡាញ់ និងបម្រើលោកទាំងពីរ។

មេរៀនទី២	**សំណេរ៖ ទម្រង់នៃការសរសេរកថាខណ្ឌ**
រយៈពេល	3ម៉ោ
វត្ថុបំណង	កំណត់ទម្រង់នៃការសរសេរកថាខណ្ឌបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី152ដល់ទី153
ដំណើរការបង្រៀន	មើលលំនាំបង្រៀបទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** (ក) កូនត្រូវគោរពស្រឡាញ់គាត់។ (ខ) ត្រូវប្រុងចាំស្តាប់ប្រសាសន៍គាត់ដោយយកចិត្តទុកដាក់។ (គ) មិនតែប៉ុណ្ណោះកូនល្អ ត្រូវប្រើសម្តីទន់ភ្លន់ជានិច្ចទៅកាន់មាតាបិតា។ (ឃ) កុមារគ្រប់រូបត្រូវប្រតិបត្តិដូចខាងលើ ដើម្បីឱ្យឪពុកម្តាយអ្នកសប្បាយចិត្ត។ (ង) ឪពុកម្តាយជាអ្នកមានគុណ។ (ច) បើគាត់ហៅ កូនត្រូវឆ្លើយបាទ ឬចាសហើយរត់ទៅជិតដោយទឹកមុខញញឹម។ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង) **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង)

មេរៀនទី៣	**ស្តាប់៖ រឿង សេដ្ឋីនិងអ្នកលក់ធ្យូង**
រយៈពេល	2ម៉ោ
វត្ថុបំណង	ទទួលកំហុសបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី154ដល់ទី155 រូបភាពទំព័រ154
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ24
ចម្លើយនៃសំណួរ	1. គីមនិងវាសនាឈ្លោះគ្នាដោយវាសនាជជែកដណ្តើមសៀវភៅមើលពីកុមារគីម។ 2. វាសនាបានតិះដៀលគីមថា ឪពុកគីមជាអ្នកទីទ័លក្រ រកស៊ីលក់ធ្យូងថោកទាបណាស់ គ្មានពូជអំបូរទេ! 3. ឪពុកគីមបាននាំគីមទៅជម្រាបលោកនាយក។ 4. ឪពុកវាសនាប្រាប់វាសនាឱ្យសុំទោសគីម ពីព្រោះវាសនាបានប្រមាថមើលងាយឪពុកគីម។ 5. រឿងនេះចង់អប់រំឱ្យ "មនុស្សកុំមើលងាយមនុស្ស ត្រូវគោរពសិទ្ធិគ្នាទៅវិញទៅមក" ។

កំណែលំហាត់	**លំហាត់ទី1៖** ក. វាសនានិងគឹមឈ្លោះគ្នាដណ្តើមសៀវភៅ។ វាសនានិងគឹមក្លាយជាមិត្តនឹងគ្នា។ វាសនាសុំទោសគឹម តាមការណែនាំរបស់ឪពុក។ ខ. តួអង្គទំនាស់ក្លាយជាមិត្តនឹងគ្នា **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង)

មេរៀនទី៤	**បំណិន៖ ដំណើររឿងនិងព្រឹត្តិការណ៍សំខាន់នៃរឿង**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីដំណើររឿងនិងព្រឹត្តិការណ៍សំខាន់ៗបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី156ដល់ទី157
ដំណើរការបង្រៀន	មើលលំនាំបង្រៀបទំព័រ21
ចម្លើយនៃសំណួរ	1. ដែលហៅថាដំណើររឿងគឺ ជាលំដាប់លំដោយព្រឹត្តិការណ៍ក្នុងរឿងតាំងពីដើមដល់ចប់ 2. ព្រឹត្តិការណ៍សំខាន់ៗនៃដំណើររឿងគឺ ជាបណ្តុំព្រឹត្តិការណ៍បន្ទាប់បន្សំនៅក្នុងរឿងមួយ
កំណែលំហាត់	**លំហាត់៖** ព្រឹត្តិការណ៍សំខាន់ៗនៃ «រឿងបងប្អូនបីនាក់ » ដែលបង្កើតបានជាដំណើររឿងគឺ៖ - បុរសមានកូនបីនាក់ធ្លាក់ខ្លួនឈឺធ្ងន់ហៅកូនមកផ្តាំ - បុរសនោះឱ្យកូនកាច់អំពៅ ដើម្បីឱ្យយល់ន័យ «សាមគ្គីគ្នាជាកម្លាំង» - កូនទាំងបីធ្វើតាមដំបូន្មានឪពុកហើយរស់នៅដោយសុខសាន្ត

មេរៀនទី៥	**អំណាន៖ កុមារចេះគួរសម**
រយៈពេល	2ម៉
វត្ថុបំណង	ប្រាប់ពីរបៀបគួរសមចំពោះភ្ញៀវបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី158ដល់ទី159 រូបភាពទំព័រ158
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. គន្ធាបានចាប់ឆ្កែចង បើកទ្វារ អញ្ជើញភ្ញៀវអង្គុយលេង និងយកទឹកជូនគាត់មុននឹងទៅជម្រាបឪពុកម្តាយនាង។ 2. ពេលឪពុកម្តាយកំពុងនិយាយជាមួយភ្ញៀវ ប្អូនប្រុសរបស់គន្ធាបានរត់កាត់មុខភ្ញៀវ។ 3. ឪពុកម្តាយពោលសរសើរគន្ធា ព្រោះគន្ធាជាក្មេងចេះគួរសម។ 4. ខ្ញុំចង់យកតម្រាប់តាមកុមារីគន្ធា ព្រោះនាងជាក្មេងចេះគួរសមធ្វើឱ្យឪពុកម្តាយសប្បាយចិត្ត។ 5. រឿងនេះកើតនៅផ្ទះឪពុកម្តាយគន្ធា នៅថ្ងៃអាទិត្យ វេលារសៀល។ 6. រឿងនេះមានព្រឹត្តិការណ៍សំខាន់ៗបី៖ - ភ្ញៀវមកលេងផ្ទះគន្ធា

	- គន្ធាណែនាំប្អូនកុំឱ្យដើរកាត់មុខភ្ញៀវ - ឪពុកម្តាយគន្ធាសរសើរគន្ធា។
កំណែលំហាត់	**លំហាត់ទី1៖** ក. ព័ទ្ធ ខ. អង្គុយ គ. កន្លែង ឃ. រក្សា **លំហាត់ទី2៖** ក. អញ្ជើញ (កិ) ជូនដំណឹង ឬហៅរកដោយគោរព។ ខ. ទន់ភ្លន់ (គុ) ល្វាសល្វន់ សុភាព។ គ. សន្ទនា (កិ) និយាយគ្នា។ ឃ. រក្សា (កិ) ថែទាំ បីបាច់ ការពារ។ **លំហាត់ទី3៖** - ភ្ញៀវមកលេងផ្ទះរបស់ឪពុកម្តាយគន្ធា - ប្អូនប្រុសនាងរត់រឹងបម្រុងទៅរកឪពុកម្តាយស្រាប់តែឃើញឪពុកម្តាយមានភ្ញៀវក៏ឱនក្បាលគោរពបន្តិចរួចត្រឡប់ថយក្រោយវិញ។ - គន្ធាណែនាំប្អូន - ឪពុកម្តាយគន្ធាសរសើរគន្ធា

មេរៀនទី៦	**វេយ្យាករណ៍៖ អព្ភន្តរសញ្ញា ឬសញ្ញាក្បៀសបិទបើក** "……" ឬ «……»
រយៈពេល	2ម៉
វត្ថុបំណង	ប្រើប្រាស់អព្ភន្តរសញ្ញា ឬក្បៀសបើកបិទ« » បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី160ដល់ទី161
ដំណើរការបង្រៀន	មើលលំនាំបង្រៀបទំព័រ22
ចម្លើយនៃសំណួរ	1. សញ្ញាក្បៀស ឬអព្ភន្តរសញ្ញាប្រើសម្រាប់អមពាក្យ ឬឃ្លៈ ដើម្បីពន្លេចឡើងនៅឈ្មោះមនុស្ស សត្វ ឬវត្ថុអ្វីមួយដែលសំខាន់ ឬសម្តីផ្ទាល់របស់អ្នកនិយាយ។ 2. កាលណាក្បៀសបើកបិទប្រើអមសម្តីផ្ទាល់របស់អ្នកនិយាយគេប្រើសញ្ញា [ ] នៅខាងមុខ។ ឧ. ឪពុកខ្ញុំមានប្រសាសន៍៖ " កុមារគ្រប់រូបត្រូវចេះគួរសមទើបសមជាពលរដ្ឋខ្មែរ"។
កំណែលំហាត់	**លំហាត់ទី1៖** ក. អ្នកគ្រូនិយាយទៅកាន់សិស្ស៖ "ពេលទៅផ្ទះអ្នកត្រូវជម្រាបសួរអ្នកមានគុណ"។ ខ. នៅក្នុងរឿងកុលាបប៉ៃលិន តាចឹមផ្តាំចៅចិត្រ "ខ្លួនទីពឹងខ្លួន"។ គ. រឿងនេះដកស្រង់ចេញពី "គតិលោកភាគទី១"។ ឃ. សុភាសិតខ្មែរចែងថា "លួចគេវាគ្រាន់ គេទាន់វាក្រែល"។ **លំហាត់ទី2៖** ក. "ពុកម៉ែរបស់ក្មួយនៅឬទេ?" ខ. "ចាស លោកអ៊ំម៉ែខ្ញុំនៅក្នុងផ្ទះបាយចំណែកពុកកំពុងធ្វើរបងព័ទ្ធចម្ការខាងក្រោយ។ សូមលោកអ៊ំអញ្ជើញចូលទៅក្នុងផ្ទះសិនខ្ញុំនឹងជម្រាបគាត់"។ គ. "លោកអ៊ំ! អញ្ជើញពិសាទឹក"។

	ឃ. "អរគុណក្មួយ" ង. "អូនឯងកុំរត់កាត់មុខភ្ញៀវឬទៅរំខានពុកម៉ែមិនគួរសមទេ"។ ច. "កូនចេះគួរសមចំពោះភ្ញៀវណាស់! ចូរកូនរក្សាការគួរសមចំពោះអ្នកដទៃឱ្យបានជាប់ជានិច្ច"។ **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង) សុភាសិតខ្មែរពោលថា៖ " ងើយស្តុក អោនដាក់គ្រាប់ " " ចេះមកពីរៀនមានមកពីរក " " ប្រហែសបាត់ប្រយ័ត្នគង់ "

មេរៀនទី៧	**អំណាន៖ ច្បាប់ប្រុស (បទព្រហ្មគីតិ)**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីច្បាប់ប្រុសបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី162ដល់ទំព័រទី163 រូបភាពទម្រង់ចំណាប់ចុងចួន
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
ចម្លើយសំណួរ	1. ច្បាប់នេះរៀបចំតាក់តែងឡើងសម្រាប់អប់រំកូនចៅជំនាន់ក្រោយដើម្បីការពារពូជអម្បូរចៀសវាងការជៀលគ្នះពីអ្នកដទៃ។ 2. ច្បាប់នេះអប់រំកូនចៅឱ្យចេះនិយាយពាក្យពេចន៍សមរម្យ ឆ្លើយបាទ ចាសទៅរៀមច្បង និងមិនឱ្យនិយាយ អឺ អើ អញ ឯង រ៉ឺ ចំពោះអ្នកដទៃ។ 3. កាលណាកូនចៅនិយាយស្តីមិនសមរម្យ គេជៀលថាកូនឥតពូជ។ 4. កាលណាកូនចៅមិនចេះគួរសម គេជៀលដល់ម៉ែឪ។
កំណែលំហាត់	**លំហាត់ទី1៖** ក. ច្រឡាស (កិ) ច្រឡោតទៅខាង។ ខ. អាស្រូវ (ន) ដែលលេចឮទៅថាមិនល្អ។ គ. ដំណៀល (ន) ដំណើរលេចឮខ្ទរខ្ទាយកេរ្តិ៍ឈ្មោះសៅហ្មង។ **លំហាត់ទី2៖** ក. ច្បង ចួន ផង ខ. ប្រដៅ ចួន ចៅ គ. ឪ ចួន អាស្រូវ ឃ. អប្រិយ ចួន ដី

មេរៀនទី៨	**សំណេរ៖ សំណេរកថាខណ្ឌ**
រយៈពេល	3ម៉
វត្ថុបំណង	សរសេរកថាខណ្ឌបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី164ដល់ទំព័រទី165
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26

កំណែលំហាត់	**លំហាត់ទី1៖** **ក. ការប្រមូលគំនិត** ឈ្មោះ.....កេទ ... អាយុ ... រស់នៅភូមិ ..... ចេះគួរសមឧស្សាហ៍ព្យាយាមធ្វើកិច្ចការផ្ទះមើលប្អូន ថៃដំណាំ ស្តាប់បង្គាប់ឪពុកម្តាយក្មេងល្អគួរយកតម្រាប់តាម **ខ. សំណេរព្រាង** ពង្រីកកន្សោមពាក្យជាល្អ៖ រៀបតាមលំដាប់ ប្រើឈ្នាប់ឈ្លាពីល្អមួយទៅល្អមួយឱ្យបានសមស្រប។ **គ. កំណែលម្អ** កែអក្ខរាវិរុទ្ធ លុបល្អដែលមិនគាំទ្រ **ឃ. សំណេរសម្រេច** ចម្លងដាក់សៀវភៅ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង)

មេរៀនទី៩	**សំណេរ៖ ការសរសេររឿងខ្លី**
រយៈពេល	3ម៉ោ
វត្ថុបំណង	សរសេររឿងខ្លីមួយបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី167ដល់ទំព័រទី168
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** ចំណងជើង : ដង្កូវនិងមេអំបៅ តួអង្គឯក : ដង្កូវ តួអង្គរង : មេអំបៅ ចំនួនតួអង្គសរុប : ២ ព្រឹត្តិការណ៍ : - កូនមេអំបៅដើរលេង បានជួបនឹងដង្កូវ ដៀលគ្នៈដង្កូវ - ដង្កូវបានថាឱ្យមេអំបៅវិញ ធ្វើឱ្យមេអំបៅដឹងខ្លួន រួចហើរចេញទៅ។ ពេលវេលា : កាលពីព្រឹកមិញ ទីកន្លែង : ពីកន្លែងមួយទៅកន្លែងមួយជិតផ្ការំយោលមួយ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង)

ជំពូកទី១៤

រុក្ខជាតិប្រទេសយើង

រយៈពេល	18ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី១	បំណិន៖ រឿងពិត ឬពិតកថា
មេរៀនទី២	អំណាន៖ ការផ្សព្វផ្សាយពីផលអាក្រក់នៃថ្នាំជក់
មេរៀនទី៣	វេយ្យាករណ៍៖ នាមអសាធារណ៍
មេរៀនទី៤	អំណាន៖ ភូមិពណ៌បៃតង
មេរៀនទី៥	សំណេរ៖ ដើមគ្នោត
មេរៀនទី៦	បំណិន៖ ប្រធានបទរបស់កថាខណ្ឌ
មេរៀនទី៧	អំណាន៖ ដំណាំស្រូវ
មេរៀនទី៨	សំណេរ៖ អត្ថបទព័ត៌មាន

មេរៀនទី១	**បំណិន៖ រឿងពិត ឬពិតកថា**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រាប់ពីរឿងពិត ឬពិតកថាបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី170
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	1. សម្តេចព្រះសង្ឃរាជ ជួន ណាតបានបួលជាសាមណេរនៅវត្តពោល្យុំ។ 2. រឿងខាងលើជារឿងពិត ព្រោះមានបញ្ជាក់ពីព្រះនាមសម្តេចព្រះសង្ឃរាជនិងប្រវត្តិរបស់លោក ជារឿងពិត។
កំណែលំហាត់	**លំហាត់៖** - កាលពីថ្ងៃពុធទី២៧សីហាឆ្នាំ២០០៨ - មន្ត្រីរដ្ឋបាលព្រៃឈើ ខេត្ត កំពង់ចាម - ស្រុកសំបូរ ខេត្តក្រចេះ - ឡូត៍លេខ៧ ស្ថិតនៅក្នុងស្រុកស្អាង ខេត្តកណ្តាល

មេរៀនទី២	**អំណាន៖ ការផ្សព្វផ្សាយពីផលអាក្រក់នៃថ្នាំជក់**
រយៈពេល	2ម៉ោ
វត្ថុបំណង	ផ្សព្វផ្សាយពីផលអាក្រក់នៃថ្នាំជក់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី171ដល់ទី172

ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. បុគ្គលិកកសិកម្មទៅពន្យល់ប្រជាកសិកររនៅស្រុកក្រូចឆ្មារពីផលអាក្រក់នៃការដាំថ្នាំជក់។ 2. បុគ្គលិកកសិកម្មពន្យល់ពីផលអាក្រក់នៃការដាំថ្នាំជក់ ទាមទារពលកម្មខ្លាំងនិងចំណាយប្រាក់ច្រើនសម្រាប់ទិញដីនិងថ្នាំសម្លាប់សត្វល្អិត ហើយបានចំណេញតិចតួច។ ម្យ៉ាងទៀតអ្នកដាំថ្នាំជក់រងគ្រោះថ្នាក់ ខូចសុខភាពដោយការប៉ះពាល់ថ្នាំសម្លាប់សត្វល្អិតនិងការពុលដោយសារធាតុគីមីពុលនីកូទីន។ ម្យ៉ាងទៀតជាហេតុធ្វើឱ្យជាតិបាត់បង់យ៉ាងច្រើនដោយសារ ការកាប់បំផ្លាញព្រៃឈើ។ 3. គេចង់ឱ្យប្តូរពីដំណាំថ្នាំជក់ទៅដាំដំណាំឧស្សាហកម្មវិញ ពីព្រោះវាផ្តល់ប្រាក់ចំណូលច្រើនជាងការដាំថ្នាំជក់ ហើយមិនបង្កគ្រោះថ្នាក់ទៀតផង។ 4. បើសិនមានសមាជិកក្នុងគ្រួសារខ្ញុំជក់បារីខ្ញុំត្រូវណែនាំគេមិនឱ្យគេជក់និងត្រូវប្រាប់ពីផលវិបាកនៃការជក់បារី។
កំណែលំហាត់	**លំហាត់ទី1៖** ក. រដ្ឋាភិបាល ខ. អាស្រ័យ គ. ពលកម្ម ឃ. សម្លាប់ **លំហាត់ទី2៖** ក. សេដ្ឋកិច្ច (ន) មុខការរបរដែលមានប្រយោជន៍ដ៏សំខាន់ក្នុងប្រទេស។ ខ. កសិកម្ម (ន) ការធ្វើស្រែចម្ការ។ គ. ឧស្សាហកម្ម (ន) ការបង្កើតរបស់ប្រើប្រាស់តាមសម័យនិយម។ **លំហាត់ទី3៖** ចំណុចដែលបញ្ជាក់ថាអត្ថបទខាងលើនេះជាពិតកថា ឬរឿងពិត កាលពីចុងខែមិថុនា ឆ្នាំ២០០៧កន្លងទៅនេះ បុគ្គលិកមន្ទីរកសិកម្ម ខេត្តកំពង់ចាម បានចុះទៅសួរសុខទុក្ខប្រជាជនក្នុងស្រុកក្រូចឆ្មារដែលនិយមដាំដំណាំថ្នាំជក់ តាំងពីយូរណាស់មកហើយ។

មេរៀនទី៣	**វេយ្យាករណ៍៖ នាមអសាធារណ៍**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រើប្រាស់នាមអសាធារណៈបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី173ដល់ទំព័រទី174 រូបភាព៖ សាលារៀន មន្ទីរពេទ្យ ផែនទី
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	
ចម្លើយលំហាត់	**លំហាត់ទី1៖** ក. ឮព្រឺងគាបទឹកត្នោតធ្វើស្ករ។ ខ. តាសុខដឹកអាពាលទៅលាងទឹកត្រពាំង។ គ. នៅខេត្តតេនគីរីមានចម្ការកាហ្វេច្រើន។ ឃ. រាជធានីភ្នំពេញជាទីក្រុងនៃព្រះរាជាណាចក្រកម្ពុជា។ **លំហាត់ទី2៖** គ. ស្រះយក្សឡោម

	ច. ផែនទីប្រទេសកម្ពុជា ឆ. ព្រះបរមរាជវាំងនៃព្រះរាជាណាចក្រកម្ពុជា **លំហាត់ទី3៖** ប្រទេសកម្ពុជា ខេត្តកំពង់ចាម ខេត្តមណ្ឌលគីរី ខេត្តរតនគីរី ទន្លេមេគង្គ ខេត្តកំពត ខេត្តបាត់ដំបង ខេត្តកំពង់ចាម

មេរៀនទី៤	**អំណាន៖ ភូមិពណ៌បៃតង**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីទិដ្ឋភាពភូមិពណ៌បៃតងបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី175ដល់ទី176 រូបភាពទំព័រ175
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. សុភាពមានគម្រោងចង់ដាំដំណាំនិងបន្លែផ្សេងៗនៅខាងក្រោយផ្ទះ។ 2. ឱ្យកូនលើករងបន្លែនៅក្រោយផ្ទះ។ 3. បានជាឪពុកជំទាស់នឹងយោបល់របស់ម្តាយ ព្រោះខាងក្រោយផ្ទះត្រូវទឹកលិចនាំឱ្យដំណាំរលួយ។ 4. សុភានិងគ្រួសារបានដាំដំណាំគ្រប់ ម្ទេស ប៉េងប៉ោះ ជីរ ស្លឹកគ្រៃ។ 5. ដំណាំទាំងនោះអាចផ្គត់ផ្គង់គ្រួសារសុភាបាន។ 6. សុភាមានអារម្មណ៍រីករាយយ៉ាងខ្លាំង ពេលឮពាក្យសរសើររបស់អ្នកភូមិ។ 7. ដើម្បីឱ្យដំណាំបានល្អត្រូវថែទាំជាប្រចាំដូចជា៖ ស្រោចទឹក ដាក់ជី ... ។
កំណែលំហាត់	**លំហាត់ទី1៖** ក. សមុទ្រ ខ. បង្គង គ. បៃកគុម្ព ឃ. បន្តិចបន្តួច **លំហាត់ទី2៖** ក. ពិគ្រោះ (កិ) ប្រឹក្សាគ្នា គិតគ្នា. ខ. បង្គង (ន) ប្រដាប់សម្រាប់គង សម្រាប់ទ្រ. គ. ផ្គត់ផ្គង់ (កិ) ទំនុកបំរុងមិនឱ្យខ្វះខាត. **លំហាត់ទី3៖** ក. បន្តិច ≠ ច្រើន ខ. ទុកព្រួយ ≠ សប្បាយ គ. ចាស់ ≠ ថ្មី ឃ. ខ្លាំង ≠ ខ្សោយ

មេរៀនទី៥	**សំណេរ៖ ពណ៌នាអំពីដើមត្នោត**
រយៈពេល	3ម៉ោ
វត្ថុបំណង	ពណ៌នាពីដើមត្នោតបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី177
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
ចម្លើយនៃសំណួរ	1. ដើមត្នោតមានរាងមូល ខ្ពស់ មានពណ៌ប្រផេះ មានសភាពគ្រើមមានកម្ពស់រហូតដល់ ១៣ម៉ែត្រ។ 2. គេច្រើនដាំដើមត្នោតនៅតាមព្រំចម្ការ ភ្លឺស្រែ ឬទីទួល។

	3. ដើមត្នោតធំៗផ្តល់ដើម ស្លឹក ធាង គាវ ផ្កា ផ្លែ។ 4. គេយកដើមត្នោតធ្វើធ្វើជាគ្រឿងសំណង់ដូចជា ផ្ទះស្ពាន ទូក របងផ្ទះជាដើម។ 5. គេយកស្លឹកវាមកដេរជាស្លឹកកណ្តបប្រក់ផ្ទះ។ ធាងវាគេបិតជាបន្ទះស្តើងៗ រៀបជាខ្សែសម្រាប់ប្រើប្រាស់តាមតម្រូវការ។ គាវត្នោតដែលកាប់មកភ្លាមៗគេដំ យកជក់មកធ្វើជាអំបោស ឬខ្សែ។ចំណែកផ្កាវិញគេកៀបយកទឹកមករាំងាស់ ធ្វើជាស្ករមានរសជាតិ ផ្អែមឈ្ងុយឆ្ងាញ់។ ផ្លែខ្ចីគេកាប់យកគ្រាប់មកបរិភោគ ឆៅ ឬធ្វើជាបង្អែមហើយគេអាចយក ផ្លែខ្ចីៗមកចិតឱ្យស្តើងធ្វើជាបន្លែក៏បាន។ លុះ ផ្លែមួយចំនួនទៀតដែលទុំ គេច្របាច់វាយកសាច់មកលាយជាមួយម្សៅរវេចខ្ចប់ ហើយចម្អិនបានជានំដ៏មានឱជារសឈ្ងុយឆ្ងាញ់។ 6. ខ្ញុំនឹងបន្តការដាំដើមត្នោតបន្តទៀត ពីព្រោះវាជាចំណែកមួយសម្រាប់ជួយ លើកស្ទួយសេដ្ឋកិច្ចជាតិផងដែរ។

មេរៀនទី៦	**បំណិនៈ ប្រធានបទរបស់កថាខណ្ឌ**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រាប់ប្រធានបទរបស់កថាខណ្ឌបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី178ដល់ទំព័ទី179
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយលំហាត់	**លំហាត់ទី1៖** ខ. ផលប្រយោជន៍នៃដំណាំឈូក **លំហាត់ទី2៖** ការសម្តែងការគួរសមចំពោះគ្នា

មេរៀនទី៧	**អំណាន៖ ដំណាំស្រូវ**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីដំណាំស្រូវបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី180ដល់ទំព័រទី182 រូបភាព៖ ស្នួងស្រូវ ដើមស្រូវ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. ដំណាំសំខាន់ជាងគេនៅប្រទេសកម្ពុជាគឺដំណាំស្រូវ។ 2. នៅប្រទេសកម្ពុជាគេធ្វើដំណាំស្រូវ ២ដងក្នុងមួយឆ្នាំ។ 3. បានជាកសិករធ្វើស្រូវប្រពលវប្បកម្មនិងស្រូវមួយដើមដើម្បីសន្សំសំចៃពូជនិងទទួលបានផលច្រើន។ 4. ក្រសួងកសិកម្មបានណែនាំឱ្យកសិកររប្រើប្រាស់ជីធម្មជាតិនិងជីកំប៉ុស។ 5. កសិកម្មនៅកម្ពុជាមានការអភិវឌ្ឍ ពីព្រោះប្រជាកសិកររច្រើនធ្វើស្រែប្រពលវប្បកម្មនិងស្នួងស្រូវមួយដើមតាមការណែនាំរបស់ក្រសួងកសិកម្ម។
ចម្លើយលំហាត់	**លំហាត់ទី1៖** ក. វស្សា ខ. ឱជារស គ. អភិវឌ្ឍ ឃ. បច្ចុប្បន្ន ង. កសិកម្ម ច. ជីវភាព **លំហាត់ទី2៖** ក. កសិកម្ម (ន) ការធ្វើស្រែចំការ។

	ខ. អភិវឌ្ឍ (កិ) ចម្រើនក្រៃលែង។ គ. បច្ចុប្បន្ន (ន) ពេលដែលមាននៅចំពោះមុខ គឺពេលឥឡូវនេះ។ ឃ. វស្សា (ន) រដូវភ្លៀង។ **លំហាត់ទី3៖** ប្រទេសកម្ពុជា ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ **លំហាត់ទី4៖** ក. ពេលវេលា ទីកន្លែងសម្រាប់ធ្វើស្រូវប្រាំង ខ. ការធ្វើស្រូវប្រពលវប្បកម្ម **លំហាត់ទី5៖** គោយន្ត ម៉ាស៊ីនស្ទួង ម៉ាស៊ីនច្រូត...។

មេរៀនទី៨	**សំណេរ៖ អត្ថបទព័ត៌មាន**
រយៈពេល	3ម៉
វត្ថុបំណង	សរសេរអត្ថបទព័ត៌មានបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី183ដល់ទំព័រទី184
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
ចម្លើយលំហាត់	**លំហាត់ទី1៖** ក. អត្ថបទនេះដកស្រង់និងកែសម្រួលចេញពីhttp://news.cam111.com/ pages/news/ khiso/detail.jsp ?id=83615) ខ. ព្រឹត្តិការណ៍នោះកើតឡើងនៅព្រឹកថ្ងៃទី10 ខែ ឧសភា ឆ្នាំ 2012 វេលាម៉ោង 10 និង 40នាទី។ គ. ព្រឹត្តិការណ៍នោះកើតឡើងនៅក្រុងតាខ្មៅ នៅតាមដងផ្លូវជាតិ ក្រុងតាខ្មៅខេត្តកណ្តាល រហូតមកដល់ ផ្លូវជាតិលេខ២ មុខមន្ទីរពេទ្យជ័យជំនះ។ ឃ. អ្នកបង្កហេតុការណ៍នោះ គឺក្មេងទំនើងបានជ្រុលទៅបុកអ្នករត់ម៉ូតូកង់បី។ ង. ហេតុនោះបណ្តាលឱ្យក្រឡាប់ម៉ូតូកង់បីហើយរងរបួសយ៉ាងធ្ងន់ធ្ងរ។ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង) កាលពីថ្ងៃទី27 ខែមករា ឆ្នាំ 2013 នៅឯមណ្ឌលប្រល័យពូជសាសន៍គេបានប្រារព្ធពិធីដាំដើមឈើក្នុងបរិវេណនោះ។ ការដាំដើមឈើច្រើនធ្វើឱ្យមានម្លប់ត្រជាក់និងខ្យល់អាកាសបរិសុទ្ធ ជាពិសេសជាងនេះទៅទៀតបានទាក់ទាញទឹកភ្លៀងនិងកាត់បន្ថយគ្រោះទឹកជំនន់។ ដូចនេះយើងគ្រប់គ្នាត្រូវចូលរួមដាំដើមឈើឱ្យបានច្រើន។

ជំពូកទី១៥

មិត្តជិតស្និទ្ធ

រយៈពេល	20ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី១	បំណិន៖ តម្លៃអប់រំនៃរឿង
មេរៀនទី២	អំណាន៖ រឿង ស្មាន់ ទីទុយ និងអណ្តើក
មេរៀនទី៣	សំណេរ៖ កថាខណ្ឌពណ៌នាអំពីមនុស្ស
មេរៀនទី៤	បំណិន៖ ការពណ៌នាអំពីតួអង្គ
មេរៀនទី៥	ការស្តាប់៖ រឿង នាយល្អ
មេរៀនទី៦	វេយ្យាករណ៍៖ សព្វនាម
មេរៀនទី៧	អំណាន៖ កល្យាណមិត្ត
មេរៀនទី៨	និយាយ៖ ការពណ៌នាអំពីមិត្ត
មេរៀនទី៩	សំណេរ៖ អត្ថបទពណ៌នាអំពីមនុស្ស

មេរៀនទី១	**បំណិន៖ តម្លៃអប់រំនៃរឿង**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រាប់ពីតម្លៃអប់រំនៃរឿងបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី186ដល់ទំព័រទី187
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
កំណែលំហាត់	**លំហាត់ទី1៖** ខ. អំពើល្អតែងទទួលបានផលល្អ **លំហាត់ទី2៖** មុននឹងជឿរឿងអ្វីមួយត្រូវពិចារណាឱ្យបានហ្មត់ចត់

មេរៀនទី២	**អំណាន៖ រឿង ស្មាន់ ទីទុយ និងអណ្តើក**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីការជួយគ្នាបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី189ដល់ទំព័រទី190 រូបភាពទំព័រ189
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. ស្មាន់ទីទុយនិងអណ្តើកជាភ្លើនឹងគ្នា។ 2. ទីទុយហើរទៅពាំទឹកមកស្រោចខ្សែអន្ទាក់ឱ្យទន់។ ឯអណ្តើកក៏ខំខាំកកេរផ្តាច់ខ្សែអន្ទាក់ ទីទុយ និងអណ្តើកព្យាយាមខាំកាត់អន្ទាក់បានពីរឆ្លុងក៏ជួនជាព្រានព្រៃមកដល់។

	សត្វទាំងពីរ ប្រាប់ស្មាន់ថា ព្រានមកជិតដល់ហើយឱ្យស្មាន់ខំប្រឹងបោលកន្ត្រាក់ខ្លួនឯង ព្រោះខ្សែអន្ទាក់នៅសល់តែមួយឆ្លុងទៀតទេ។ ស្មាន់ខំរើបម្រះរហូតបានរួចខ្លួន។ 3. ទីទុយនិងស្មាន់ជួយអណ្តើកដោយទីទុយឱ្យស្មាន់ប្រើឧបាយកលមាយាឱ្យព្រានព្រៃដេញ។ ស្មាន់ដើរជិតដល់ព្រានក៏ធ្វើអាការៈជាបាក់ជើងម្ខាងបោលបោះតែជើងបីចំពោះមុខព្រាន។ ព្រានស្មានថាស្មាន់បាក់ជើងមែនក៏ចោលអណ្តើកទៅលើគុម្ពស្បូវ រត់តាមស្មាន់ ។ ស្មាន់ដឹងថាព្រានចោលអណ្តើកហើយ ក៏រិតតែធ្វើកលបោកឱ្យព្រានដេញចេញផុតពីព្រៃស្បូវ។ បានឱកាសល្អ ស្មាន់បោលគេចមកក្រោយពាំអណ្តើកនោះបោលផ្លោះចូលទៅក្នុងព្រៃធំ។ ទទុយហើរនាំផ្លូវដរាបដល់ព្រៃមួយដែលផុតព្រានដើរទៅដល់។ 4. ចំណាប់អារម្មណ៍ចំពោះរឿងមានតម្លៃអប់រំល្អ ពីព្រោះបានបង្ហាញពីការជួយគ្នាទៅវិញទៅមករហូតផុតគ្រោះថ្នាក់។
កំណែលំហាត់	**លំហាត់ទី1៖** ក. អន្ទាក់ ខ. កន្ត្រាក់ គ. អណ្តើក **លំហាត់ទី2៖** ក. ព្រាន (ន) អ្នកបរបាញ់សត្វ ប្រមាញ់។ ខ. ស្មាន់ (ន) សត្វចតុប្បាទព្រៃមួយប្រភេទពួកក្តាន់ ឈ្លូស រមាំង។ គ. កន្ត្រាក់ (កិ) ទាញកញ្ឆក់យ៉ាងប្រញាប់។ ឃ. ក្លើ (ន) មិត្តជិតស្និទ្ធ។ ង. អន្តរាយ (ន) ដំណើរខូចប្រយោជន៍ សេចក្តីវិនាស។ **លំហាត់ទី3៖** ក. មិត្តល្អត្រូវជួយគ្នាក្នុងគ្រាមានអាសន្ន។ ខ. បានទទួលជោគជ័យ។

មេរៀនទី៣	**សំណេរ៖ កថាខណ្ឌពណ៌នាអំពីមនុស្ស**
រយៈពេល	3ម៉ោ
វត្ថុបំណង	សរសេរកថាខណ្ឌពីមនុស្សបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី191
ជំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់៖** (ចម្លើយជាក់ស្តែង) ឪពុករបស់ខ្ញុំឈ្មោះ ចែម។ គាត់មានអាយុ45ឆ្នាំ។ ឪពុកខ្ញុំជាគ្រូពេទ្យនៅមន្ទីរពេទ្យគន្ធបុប្ផា។ គាត់មានសម្បុរស សក់ខ្មៅ មុខមូល ក្អែកធំៗ។ ពេលទៅមន្ទីរពេទ្យគាត់តែងស្លៀកខោសនិងពាក់អាវស។ គាត់ជាមនុស្សសុភាព រួសរាយរាក់ទាក់ និងចិត្តល្អ តែម៉ត់ចត់ក្នុងការងារ។ ពេលទំនេរគាត់ចូលចិត្តអានកាសែត ទស្សនាវដ្តី និងមើលព័ត៌មានតាមទូរទស្សន៍។

មេរៀនទី៤	**បំណិន៖ ការពណ៌នាអំពីតួអង្គ**
រយៈពេល	2ម៉ោ
វត្ថុបំណង	ពណ៌នាតួអង្គនៃរឿងបានត្រឹមត្រូវ។

សម្ភារឧបទេស	ស.ស. ទំព័រទី192 ដល់ទី193
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	1. ការពណ៌នាអំពីតួអង្គ គឺការរៀបរាប់ពីរូបរាង តួនាទី ចរិតលក្ខណៈ (គុណសម្បត្តិ គុណវិបត្តិ) សកម្មភាព ចំណង់ចំណូលចិត្តរបស់តួអង្គ ដែលអ្នកនិពន្ធបានបង្ហាញនៅក្នុងសាច់រឿង។ 2. នៅក្នុងសាច់រឿងនីមួយៗអ្នកនិពន្ធបានឱ្យតួអង្គធ្វើសកម្មភាពដើម្បីបង្ហាញចរិតលក្ខណៈ និងចំណង់ចំណូលចិត្តរបស់តួអង្គ។
កំណែលំហាត់	**លំហាត់៖** - ស្មាន់ជាតួអង្គចេះតស៊ូ មានសាមគ្គីភាព មិនបោះបង់ចោលគ្នា។ទីទុយជាតួអង្គឆ្លាត ឈ្លាសវៃ តស៊ូ ព្យាយាមមិនបោះបង់ចោលគ្នាក្នុងគ្រាមានអាសន្ន - អណ្តើកជាតួអង្គ : មានសាមគ្គីភាព តស៊ូ ព្យាយាម

មេរៀនទី៥	**ស្តាប់៖ នាយល្អ**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីសាមគ្គីភាពគ្នាបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី194 រូបភាពទំព័រទី194
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ24
ចម្លើយនៃសំណួរ	1. ក្នុងរឿងនាយល្អមានតួអង្គ មេហ្វូងព្រាប ហ្វូងព្រាប ព្រានវាយលុប។ 2. នែ! សម្លាញ់ ទាំងអស់! ចំណីអាហារដែលយើងបានឃើញដោយងាយយ៉ាងនេះ ពុំមែនជាចំណីដែលគួរឱ្យចុះទៅបរិភោគឡើយ ព្រោះវាជានុយសម្រាប់ពួកយើងក៏សឹងមាន។
កំណែលំហាត់	**លំហាត់ទី1៖** ក. មិនស្តាប់តាមដំបូន្មានមេហ្វូង។ ខ. ចេះសាមគ្គីគ្នា **លំហាត់ទី2៖** សាមគ្គីភាពជាកម្លាំងនាំឱ្យរួចផុតពីសេចក្តីស្លាប់។ **លំហាត់ទី3៖** មានមេហ្វូងព្រាបមួយហ្វូងនាំព្រាបទៅរកចំណី។ ពេលឃើញចំណីសន្ធឹកសន្ធាប់យ៉ាងនេះពួកព្រាបបម្រុងនឹងចុះស៊ីតែមេហ្វូងឃាត់តែហ្វូងព្រាបមិនជឿទេ។ ហ្វូងព្រាបបានចុះទៅស៊ីចំណីព្រានឃើញក៏កន្ត្រាក់លប់។ ព្រាបទាំងអស់ជាប់ក្នុងលប់។ មេហ្វូងព្រាបឃើញក្តីអន្តរាយក៏រិះរកមធ្យោបាយជួយហ្វូងព្រាប។ មេហ្វូងនិយាយថា៖ ពួកយើងទាំងអស់គ្នាត្រូវតែស្រុះគ្នាហើយទទះស្លាបហើរព្រមៗគ្នាដើម្បីឱ្យរួចជីវិតពីអន្ទាក់ព្រាន។ ដោយកម្លាំងទទះស្លាបហើរព្រមគ្នាព្រាបបានហើរឡើងលើអាកាសជាប់ទាំងលប់ទៅជាមួយផង។

មេរៀនទី៦	**វេយ្យាករណ៍៖ សព្វនាម**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រើប្រាស់សព្វនាមបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី195

ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
កំណែលំហាត់	**លំហាត់៖** (ចម្លើយជាក់ស្តែង) - ខ្ញុំមានមិត្តម្នាក់ឈ្មោះបូរិន។ - ពួកយើងរៀនថ្នាក់ជាមួយគ្នា។ - បុប្ផាជាប្អូនជីដូនមួយរបស់ខ្ញុំ។ វាចូលចិត្តលេងបាល់។ - តើឯងបានទៅសួរសុខទុក្ខឪពុកវីរៈឬទេ ? - ឪពុកវីរៈគាត់សុខសប្បាយជាទេ ?

មេរៀនទី៧	**អំណាន៖ កល្យាណមិត្ត**
រយៈពេល	2ម៉ោ
វត្ថុបំណង	កំណត់លក្ខណៈរបស់កល្យាណមិត្តបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី196ដល់ទំព័រទី197
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយសំណួរ	1. នៅសាលារៀនខ្ញុំមានមិត្តច្រើនណាស់។ 2. មិត្តរបស់ខ្ញុំមានសន្តានចិត្តស្មោះស បរិសុទ្ធ ឥតលាក់លៀម ឥតពុតត្បុតស្រឡាញ់គ្នាដូចបងប្អូនបង្កើត។ 3. មនុស្សដែលគួរយកជាមិត្តគឺមនុស្សដែលចេះជួយធុរៈគ្នា ជួយឧបត្ថម្ភគ្នានិងមិនបោះបង់ចោលគ្នាពេលមានអាសន្នអន្ទក្រ។ 4. ពុទ្ធសុភាសិត "ត្រូវរាប់រកបុគ្គលល្អ ប្រកបដោយសប្បុរសធម៌ដ៏ឧត្តមដែលមានលក្ខណៈជាកល្យាណមិត្ត " ។
កំណែលំហាត់	**លំហាត់ទី1៖** ក. មិត្តភក្តិ ខ. សន្តាន គ. ទូន្មាន ឃ. ឧបត្ថម្ភ ង. កល្យាណ **លំហាត់ទី2៖** ក. មិត្តភក្តិ (ន) អ្នកដែលស្រឡាញ់គ្នាជិតជិត។ ខ. ឧទរ (ន) ពោះ ផ្ទៃ គ. ពុតត្បុត (ន) ដំណើរបិញ្ញរបុញ្ញ កិច្ចកលមាយា។ ឃ. កល្យាណមិត្ត (ន) មិត្តល្អ **លំហាត់ទី3៖** ក. ស្រឡាញ់ ≠ ស្អប់ ខ. ល្អ ≠ អាក្រក់ គ. សេចក្តីសុខ ≠ សេចក្តីទុក្ខ ឃ. បរិសុទ្ធ ≠ សៅហ្មង **លំហាត់ទី4៖** ក. ជួយគ្នាទៅវិញទៅមក **លំហាត់ទី5៖** ខ្ញុំ យើង

មេរៀនទី៨	**ការនិយាយ៖ ការពណ៌នាអំពីមិត្ត**
រយៈពេល	2ម៉ោ
វត្ថុបំណង	ពណ៌នាពីមិត្តល្អណាម្នាក់ប្រាប់ទៅមិត្តភក្តិបានត្រឹមត្រូវ។

សម្ភារឧបទេស	ស.ស. ទំព័រទី198 រូបភាពទំព័រទី198
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ25
ចម្លើយសំណួរ	1. ការុនជាមនុស្សមានចិត្តស្លូតបូត ស្មោះត្រង់ ចិត្តល្អ និងមានអធ្យាស្រ័យល្អចំពោះមិត្តភក្តិ។ 2. ពេលទំនេរ ការុននាំបូរិនទៅបណ្ណាល័យ ដើម្បីអានសៀវភៅ។ 3. ចូលចិត្តមិត្តភក្តិដែលមានចរិតលក្ខណៈដូចការុន ពីព្រោះមិត្តបែបនេះ នឹងនាំយើងទៅរកសេចក្តីរីកចម្រើន។ 4. អត្ថបទសន្ទនាខាងលើនេះពណ៌នាអំពីមិត្ត។
កំណែលំហាត់	**លំហាត់៖** (ចម្លើយជាក់ស្តែង) ក្រោយពេលទំនេរពីការសិក្សានារីជួយធ្វើកិច្ចការផ្ទះដូចជាឱ្យចំណីសត្វ។ ម៉ោង6និង20នាទីនារីញុំអាហារពេលព្រឹកជាមួយគ្រួសាររួចទៅសាលារៀន។ ពេលគោរពទង់ជាតិគេច្រៀងចម្រៀងជាតិ នៅពេលមិត្តភក្តិជួលគេចេះជួយលើកមិត្តភក្តិ។ នៅក្នុងថ្នាក់រៀននារីយកចិត្តទុកដាក់ស្តាប់និងរៀន។

មេរៀនទី៩	**សំណេរ៖ អត្ថបទពណ៌នាអំពីមនុស្ស**
រយៈពេល	3ម៉ោ
វត្ថុបំណង	សរសេរអត្ថបទអំពីមនុស្សបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី199 ដល់ទំព័រទី200
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់៖** (ចម្លើយជាក់ស្តែង) បងស្រីខ្ញុំឈ្មោះ សុភាព។ គាត់មានអាយុ 15ឆ្នាំ។ បងស្រីខ្ញុំមានរាងស្តើង ខ្ពស់ស្រឡះ សម្បុរសស្អាត សក់ស្លូត ភ្លឺរលោងហើយវែង។ គាត់មានមុខរាងមូល បបូរមាត់ស្តើងច្រមុះស្រួច ត្រចៀកវែង ចង្កាសមនឹងទម្រង់មុខរបស់គាត់ ដៃជើងស្រឡូនគួរឱ្យស្រឡាញ់។ ជាទូទៅគាត់ចូលចិត្តស្លៀកពាក់តាមបែបនារីខ្មែរ។ បងស្រីខ្ញុំជាមនុស្សរួសរាយ រាក់ទាក់ និងមានចិត្តល្អ។ មិនតែប៉ុណ្ណោះគាត់មានចរិតស្លូតបូតតែម៉ឺងម៉ាត់ក្នុងការងារ។ គាត់ឧស្សាហ៍ព្យាយាមនិងមានអធ្យាស្រ័យល្អជានិច្ច។ ពេលប្អូនៗ មានកំហុស គាត់ពុំដែលស្តីបន្ទោសឬប្រើអំពើហិង្សាចំពោះប្អូនៗឡើយ។ គាត់តែងនិយាយទូន្មាននិងលួងលោមប្អូនឱ្យខិតខំរៀនសូត្រនិងស្តាប់តាមដំបូន្មានឪពុកម្តាយ។ អ្នកជិតខាងតែងតែស្រឡាញ់រាប់អានបងស្រីខ្ញុំគ្រប់គ្នា។ បងស្រីខ្ញុំជាមនុស្សឧស្សាហ៍ធ្វើការងារ។ នៅពេលទំនេរពីការសិក្សាគាត់ឆ្លៀតរៀបចំផ្ទះ សម្អាតចានឆ្នាំង ជួយមើលថែប្អូន។ ខ្ញុំគោរពស្រឡាញ់បងស្រីខ្ញុំដូចជាឪពុកម្តាយខ្ញុំដែរ ព្រោះគាត់ខំធ្វើការងារជាច្រើនដើម្បីគ្រួសារ និងអប់រំប្អូនៗឱ្យក្លាយជាមនុស្សល្អ។

ជំពូកទី១៦

មធ្យោបាយធ្វើទំនាក់ទំនង

រយៈពេល	14ម៉ោង
	ចំណងជើងសមត្ថភាព
មេរៀនទី១	វេយ្យាករណ៍៖ សញ្ញាអស្តា ឬ សញ្ញាលេខប្រាំបី (៏)
មេរៀនទី២	អំណាន៖ មេសូត្រ៖ មធ្យោបាយទាក់ទងគ្នា
មេរៀនទី៣	សំណេរ៖ ការទទួលព័ត៌មាន
មេរៀនទី៤	អំណាន៖ ទំនាក់ទំនងនៅសម័យវិទ្យាសាស្ត្រ
មេរៀនទី៥	និយាយ៖ ការនិយាយទូរស័ព្ទទៅកាន់មិត្ត
មេរៀនទី៦	សំណេរ៖ ការសរសេររឿងនិទាន

មេរៀនទី១	**វេយ្យាករណ៍៖ សញ្ញាអស្តា ឬ សញ្ញាលេខប្រាំបី (៏)**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រើប្រាស់សញ្ញាអស្តា ឬសញ្ញាលេខប្រាំបី (៏)បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី202ដល់ទំព័រទី203
ដំណើរការបង្រៀន	មើលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	
កំណែលំហាត់	**លំហាត់ទី1៖** គ. ក ន ហ ដ **លំហាត់ទី2៖** ក. កាលពីម្សិលមិញខ្ញុំរើសបានវត្ថុមួយ**ដ៏**មានតម្លៃ។ ខ. អុញ **ន៏**! ទូរទស្សន៍នេះខូចបាត់! គ. **ហ៏**! ឯងយកសៀវភៅរឿងនេះទៅអានចុះ។ ឃ. ឯង**ក៏**ចូលចិត្តមើលសិល្បៈតាមទូរទស្សន៍ដែរមែនឬទេ? **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង) ក. សាលារៀននេះសង់លើទីវាលមួយដ៏ធំទូលាយ។ ខ. ខ្ញុំក៏ចូលចិត្តមើលសៀវភៅរឿងដូចឯងដែរ។ គ. ហ៏! ឯងយកបន្ទាត់នេះទៅប្រើចុះ។ ឃ. អុញ ន៏ខ្មៅដៃនេះបាក់ចុងស្រេច។ **លំហាត់ទី4៖**(១)ដ៏ (២)ក៏ (៣)ន៏ (៤)ដ៏ (៥)ហ៏

មេរៀនទី២	**អំណាន៖ មេសូត្រ៖ មធ្យោបាយទាក់ទងគ្នា (បទពាក្យប្រាំពីរ)**

រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីមធ្យោបាយទាក់ទងគ្នាមួយចំនួនបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី204ដល់ទំព័រទី205 រូបភាពទំព័រ204
ដំណើរការបង្រៀន	មើលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. មធ្យោបាយសម្រាប់ទាក់ទងគ្នាមាន សំបុត្រ ទូរស័ព្ទ វិទ្យុ ទូរទស្សន៍។ 2. មធ្យោបាយដែលទំនើបក្នុងការទាក់ទងគ្នាគឺទូរស័ព្ទ។
កំណែលំហាត់	**លំហាត់ទី1៖** ក. ៤វគ្គ ខ. មធ្យោបាយទាក់ទងគ្នា **លំហាត់ទី2៖** ក. អនេក ចួន ប្លែក ខ. អស្ចារ្យ ចួន អក្ខរា សារ **លំហាត់ទី3៖** 2. ក 4. ខ 1. គ 3. ឃ

មេរៀនទី៣	**សំណេរ៖ ការទទួលព័ត៌មាន**
រយៈពេល	3ម៉ោ
វត្ថុបំណង	ទទួលព័ត៌មាន(សំបុត្រ ទូរស័ព្ទ វិទ្យុ ទូរទស្សន៍) បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី206
ដំណើរការបង្រៀន	មើលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** (១)ទូរស័ព្ទ (២)របៀបប្រើ (៣)ព័ត៌មាន (៤)រៀនសូត្រ (៥)ទំនិញ (៦)ផ្ទះ **លំហាត់ទី2៖** ក. ទូរទស្សន៍ ខ. ឆ្មាដេញចាប់កណ្តុរ គ. សប្បាយចិត្តណាស់ **លំហាត់ទី3៖** ក. ព័ត៌មាន ខ. ទូរទស្សន៍ វិទ្យុ គ. វិទ្យុ ទូរទស្សន៍ គ្រួសារ សាច់ញាតិ **លំហាត់ទី4៖** ក. ខ្ញុំសរសេរសំបុត្រសួរសុខទុក្ខមិត្តភក្តិ។ ខ. ខ្ញុំទូរស័ព្ទទៅពុករបស់ខ្ញុំ។ គ. ម្តាយខ្ញុំស្តាប់ព័ត៌មានតាមវិទ្យុ។ ឃ. ទូរទស្សន៍ច្រើនផ្សាយព័ត៌មានទាន់ហេតុការណ៍។

មេរៀនទី៤	**អំណាន៖ ទំនាក់ទំនងនៅសម័យវិទ្យាសាស្ត្រ**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីទំនាក់ទំនងនៅសម័យវិទ្យាសាស្ត្របានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី207ដល់ទំព័រទី208 រូបភាពទំព័រ207
ដំណើរការបង្រៀន	មើលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. វិទ្យុផ្សព្វផ្សាយ រឿងល្ខោនយីកេ ចម្រៀងតន្ត្រី ព័ត៌មានសំខាន់ៗព្រឹត្តិការណ៍ជាតិ អន្តរជាតិ ព័ត៌មានកីឡា ខ្សែភាពយន្ត...។ 2. ការទទួលព័ត៌មាន ឬដំណឹងផ្សេងៗតាមរយៈវិទ្យុខុសគ្នាពីទូរទស្សន៍ត្រង់ទូរទស្សន៍ឮ

	សំឡេងផង និងមើលរូបភាពឃើញផង។ 3. បណ្តាយទំនាក់ទំនងនៅសម័យវិទ្យាសាស្ត្រមាន ទូរស័ព្ទ ទូរទស្សន៍ និងវិទ្យុ។ 4. នៅសម័យវិទ្យាសាស្ត្រគេនិយមបញ្ជូព័ត៌មានតាម ទូរស័ព្ទ ទូរទស្សន៍ និងវិទ្យុ។ 5. មានពីរបែបគឺ ទូរស័ព្ទចល័ត និងទូរស័ព្ទដាក់នៅលើតុ។
កំណែលំហាត់	**លំហាត់ទី1៖** គ. ៤កថាខណ្ឌ **លំហាត់ទី2៖** ក. វិទ្យាសាស្ត្រ (ន) ការសិក្សាពីបច្ចេកវិទ្យា។ ខ. ចល័ត (គុ) ដែលមិនបិតនៅនឹងតែមួយកន្លែង។ គ. បណ្តាញ (ន) អ្វីៗដែលមានក្រឡាទាក់គ្នា។ ឃ. មធ្យោបាយ (ន)ដំណើរទំនងដ៏ល្មមសមគួរសម្រាប់ធ្វើកិច្ចការឱ្យបានសម្រេចតាមបំណង។ **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង)

មេរៀនទី៥	**ការនិយាយ៖ ការនិយាយទូរស័ព្ទទៅកាន់មិត្ត**
រយៈពេល	2ម៉ោ
វត្ថុបំណង	និយាយទូរស័ព្ទទៅកាន់មិត្តភក្តិបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី209
ដំណើរការបង្រៀន	មើលំនាំនៃការបង្រៀនទំព័រ25
ចម្លើយនៃសំណួរ	1. គន្ធានិយាយទូរស័ព្ទទៅសុខា។ 2. ពួកគេនិយាយគ្នាពីការសួរសុខទុកនិងការរៀនធ្វើលំហាត់នៅថ្ងៃស្អែក។ 3. អ្នកទទួលត្រូវចាប់ផ្តើមនិយាយសួស្តីគន្ធា។ 4. នៅពេលបញ្ចប់ការនិយាយ អ្នកហៅប្រើពាក្យថា លាសិនហើយ!
កំណែលំហាត់	**លំហាត់៖** (ចម្លើយជាក់ស្តែង)

មេរៀនទី៦	**សំណេរ៖ ការសរសេររឿងនិទាន**
រយៈពេល	3ម៉ោ
វត្ថុបំណង	សរសេររឿងនិទានបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី210 ដល់ទំព័រ211 រូបភាពទំព័រ211
ដំណើរការបង្រៀន	មើលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** ទន្សាយឃើញយាយទូលចេកដើរតាមដងផ្លូវ។ ពេលយាយដើរជិតដល់វាក៏ធ្វើពុតជាងាប់ស្តូក យាយឃើញទន្សាយស្លាប់ក៏រើសទន្សាយដាក់ក្នុងកញ្ជើ។ ទន្សាយស៊ីចេករួចលោតចេញពីកញ្ជើ។ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង)

ជំពូកទី១៧

ម្ហូបអាហារខ្មែរ

រយៈពេល	17ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី១	បំណិន៖ ទំនាក់ទំនងរវាងហេតុនិងផល
មេរៀនទី២	អំណាន៖ ការបរិភោគអាហារនៅភោជនីយដ្ឋាន
មេរៀនទី៣	សំណេរ៖ ការបំពេញបែបបទងាយៗ
មេរៀនទី៤	ការស្តាប់៖ ជំងឺផ្តាសាយថ្មី អេ អេច១ អិន១(AH1 N1)
មេរៀនទី៥	វេយ្យាករណ៍៖ គុណកិរិយា
មេរៀនទី៦	អំណាន៖ រឿង អន្ធង់វែងឆ្នាំងវែង
មេរៀនទី៧	អំណាន៖ មេសូត្រ៖ បញ្ជីម្ហូបខ្មែរ
មេរៀនទី៨	និយាយ៖ ការសម្តែងការចូលចិត្តនិងមិនចូលចិត្ត

មេរៀនទី១	**បំណិន៖ ទំនាក់ទំនងរវាងហេតុនិងផល**
រយៈពេល	2ម៉
វត្ថុបំណង	ប្រាប់ទំនាក់ទំនងហេតុនិងផលបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី213
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ21
កំណែលំហាត់	**លំហាត់ទី1៖** ប្រហុក ផ្អកឆ្នាំនេះទៀងថ្លៃ ព្រោះប្រទេសយើងមិនសូវសម្បូរត្រី។ **លំហាត់ទី2៖** មីងសនពូកែធ្វើម្ហូប ទើបគាត់លក់ដាច់ជាងគេ។ **លំហាត់ទី3៖** សុខាឈឺពោះ ព្រោះនាងញ៉ាំចំណីអាហារមិនស្អាត។ **លំហាត់ទី4៖** អ្នកជំងឺពក ក ភាគច្រើនបណ្តាលមកពីបរិភោគអាហារប្រចាំថ្ងៃខ្វះជាតិអ៊ីយ៉ូត។

មេរៀនទី២	**អំណាន៖ ការបរិភោគអាហារនៅភោជនីយដ្ឋាន**
រយៈពេល	2ម៉
វត្ថុបំណង	ជ្រើសរើសកន្លែងបរិភោគអាហារបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី214 ដល់ទំព័រ 2015 រូបភាព៖ ទំព័រ214
ដំណើរការបង្រៀន	មើលលំនាំនាំការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. គ្រួសារនោះបាននាំគ្នាទៅបរិភោគអាហារនៅភោជនីយដ្ឋាន។

	2. ផ្នែកខាងក្រៅនៃភោជនីយដ្ឋានមានការរៀបចំតុបតែងលម្អគួរឱ្យចាប់អារម្មណ៍។ 3. ផ្នែកខាងក្នុងនៃភោជនីយដ្ឋានមានការរៀបចំទីកន្លែងស្អាតបាតសមរម្យប្រកបដោយផាសុកភាព។ 4. ម្ហូបអាហារនៅទីនោះមានឱជារសឆ្ងាញ់និងមានតម្លៃសមរម្យ។
កំណែលំហាត់	**លំហាត់ទី1៖** ក. ម្ហូបឆ្ងាញ់គ្រប់មុខ តម្លៃសមរម្យ និងមានអនាម័យសេវាកម្មល្អចំពោះភ្ញៀវ ខ. ពាកថាខណ្ឌ គ. បរិស្ថាននៅភោជនីយដ្ឋាន **លំហាត់ទី2៖** សម្លកកូរ ប្រហុកខ្ទិះ សម្លប្រហើរ សម្លម្ជូរ ម្ជូរគ្រឿង សម្លការី ញាំ ស្ងោរជ្រក់ ត្រីអាំង ឆាខ្ទី **លំហាត់ទី3៖** ក. ភោជនីដ្ឋាននេះលក់ដាច់ជាងគេ ព្រោះម្ហូបមានអនាម័យ។ ខ. ភោជនីដ្ឋាននេះមានម្ហូបឆ្ងាញ់គ្រប់មុខ និងមានអនាម័យ ទើបខ្ញុំមកញ៉ាំញឹកញាប់។ គ. ចំណីអាហារមានអនាម័យនាំឱ្យមានសុខភាពល្អ។ **លំហាត់ទី4៖** ជ្រើសរើសកន្លែងបរិភោគអាហារ

មេរៀនទី៣	**សំណេរ៖ ការបំពេញបែបបទងាយៗ**
រយៈពេល	3ម៉
វត្ថុបំណង	បំពេញបែបបទងាយៗបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រ216 ដល់ទំព័រ218
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់៖** (ចម្លើយជាក់ស្តែង)

មេរៀនទី៤	**ការស្តាប់៖ ជំងឺផ្តាសាយថ្មី អេ អេច១ អិន១** (A/H1/N1)
រយៈពេល	2ម៉
វត្ថុបំណង	ការពារជំងឺផ្តាសាយថ្មីបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី219 ដល់ទំព័រទី220 រូបភាពទំព័រ219
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ24
ចម្លើយនៃសំណួរ	1. ជំងឺផ្តាសាយបក្សីបង្កដោយវីរុស H5N1។ 2. ជំងឺផ្តាសាយបក្សីឆ្លងទៅមនុស្សតាមរយៈការប៉ះពាល់ផ្ទាល់ជាមួយមាន់ឈឺ ឬងាប់ មេរោគជំងឺផ្តាសាយបក្សី។ 3. ជំងឺនេះមានអាការៈសង្ស័យស្រដៀងនឹងជំងឺផ្តាសាយធម្មតាដែរ គឺមានគ្រុនក្តៅខ្លាំង ឈឺក្បាល រួយដៃជើង អស់កម្លាំង ឈឺក ក្អក ហៀរសំបោរដកដង្ហើមថប់ៗ។ 4. ពេលជំងឺកំពុងរាលដាល អង្គការសុខភាពពិភពលោកណែនាំដូចជា ស្នាក់នៅតែក្នុង

	ផ្ទះចៀសវាងនៅកន្លែងដែលអ៊ូអរនិងចាប់ដៃគ្នា មិនទៅជិតអ្នកក្អក ឬកណ្តាស់ត្រូវពាក់ម៉ាស់ការពារ លាងសម្អាតដៃឱ្យបានស្អាតជានិច្ច រាយការណ៍ជាបន្ទាន់ពីស្ថានភាពរាតត្បាតជំងឺនិងអ្នកស្លាប់ ចៀសវាងទៅសួរសុខទុក្ខអ្នកជំងឺផ្តាសាយ។ 5. ជំងឺនេះកាចសាហាវ ព្រោះបើឆ្លងមកមនុស្សនឹងបណ្តាលឱ្យស្លាប់។
កំណែលំហាត់	**លំហាត់ទី1៖** ក. ការយកបក្សីឈឺ ឬងាប់ធ្វើជាអាហារ ⇨ បណ្តាលឱ្យមានជំងឺផ្តាសាយបក្សី។ ខ. យើងត្រូវពាក់ម៉ាស់ការពារ ⇨ ទើបមិនឆ្លងជំងឺផ្តាសាយបក្សី។ គ. ការចាក់វ៉ាក់សាំងការពារជំងឺផ្តាសាយបក្សី ⇨ យើងចៀសផុតពីជំងឺនេះ។ **លំហាត់ទី2៖** ក. ☑ លាងដៃឱ្យបានស្អាតនឹងសាប៊ូ ឬផេះ ក្រោយពេលប៉ះពាល់មាន់ ទា។ ☑ ចម្អិនឱ្យឆ្អិនល្អចំពោះអាហារដែលប្រើសាច់មាន់ ទា ឬស៊ុតរបស់វា។ ☑ ត្រូវរាយការណ៍ជាបន្ទាន់បើមានមាន់ ទាឈឺ ឬងាប់។ ☑ បញ្ជូនអ្នកជំងឺទៅជួបគ្រូពេទ្យជាបន្ទាន់បើសង្ស័យថាមានជំងឺផ្តាសាយបក្សីលើមនុស្ស។ ខ. ☑ ចៀសវាងកន្លែងដែលមានមនុស្សកកកុញច្រើន។ ☑ ពាក់ម៉ាស់ ឬក្រមា ទោះបីជាអ្នកគ្មានរោគសញ្ញាអ្វីក៏ដោយ។ គ. ☑ ជំងឺផ្តាសាយថ្មី (អេ អេច១អិន១) និងវិធីការពារ។

មេរៀនទី៥	**វេយ្យាករណ៍៖ គុណកិរិយា**
រយៈពេល	2ម៉
វត្ថុបំណង	ប្រើប្រាស់គុណកិរិយាបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រ221 ដល់ទំព័រទី222
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	
កំណែលំហាត់	**លំហាត់ទី1៖** ក. ធ្នើម ខ. ល្មម គ. គើមៗ ឃ. លឿន ង. រន្ទើន ច. ស្រងាត់ **លំហាត់ទី2៖** ក. ឯក ខ. ពូកែ គ. រណ្តំា ឃ. រស់រវើក ង. ច្រើន **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង) នារីចូលចិត្តនិយាយលេងច្រើន។ សុខាធ្វើដំណើរទៅផ្សារយ៉ាងយូរ។ ខ្យល់បក់ខ្លាំងនៅពេលមានព្យុះ។ សេះផាយលឿន។ សុខាមានសម្លេងពិរោះរណ្តំា

មេរៀនទី៦	**អំណាន៖ រឿង អន្ទង់វែងឆ្នាំងវែង**
រយៈពេល	2ម៉
វត្ថុបំណង	ប្រាប់ពីភាពល្ងង់ខ្លៅរបស់តួអង្គស្រីបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី223 ដល់ទំព័រទី224 រូបភាព៖ ទំព័រ223
ដំណើរការបង្រៀន	មើលលំនាំនៃបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. បុរសនោះបានអន្ទង់មកធ្វើម្ហូប។ 2. នៅពេលប្តីប្រគល់អន្ទង់ឱ្យប្រពន្ធឆ្លើយថា៖ ចុះអន្ទង់នេះវែងម្ល៉េះបានឆ្នាំងវែងមកពីណាស្មើរអន្ទង់នេះបាន? 3. ប្តីជាអ្នកចម្អិនអន្ទង់នោះ។ 4. បុរសជាប្តីមានមុខរបរធ្វើស្រែ។ 5. ខ្ញុំយល់ថាប្រពន្ធបុរសនោះជាមនុស្សល្ងង់តែមិនទទួលស្គាល់ថាខ្លួនល្ងង់។
កំណែលំហាត់	**លំហាត់ទី1៖** គេច (កិ) ចៀសវាង។ ធ្ងាញ់ (គុ) ដែលមានរសជាតិគាប់មាត់ ឬដែលមានក្លិនគាប់ច្រមុះ។ សង្សុីយ (ន) សេចក្តីឆ្ងល់ , ដំណើររឿងឆ្ងល់ , ដំណើរមិនអស់មិនហើយក្នុងចិត្ត ប្រពន្ធ (ន) ស្ត្រីជាចំណងគូនឹងបុរស។ **លំហាត់ទី2៖** គ. មិនចេះច្នៃប្រឌិត **លំហាត់ទី3៖** អត្ថបទនេះអប់រំដល់មនុស្សឱ្យចេះច្នៃប្រឌិតបត់បែនតាមកាលៈទេសៈ។

មេរៀនទី៧	**អំណាន៖ មេសូត្រ៖ បញ្ជីម្ហូបខ្មែរ (បទកាកគតិ)**
រយៈពេល	2ម៉
វត្ថុបំណង	រៀបរាប់ពីម្ហូបអាហារខ្មែរបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី225 ដល់ទំព័រទី226 រូបភាពទំព័រ225
ដំណើរការបង្រៀន	មើលលំនាំនៃបង្រៀនទំព័រ23
ចម្លើយនៃសំណួរ	1. ប្រហុកត្រីឆ្អើរ ត្រីងៀត ត្រីប្រៃ កកូរ ស្ងោរជ្រក់ ទឹកគ្រឿងអន្លក់ ប្រហើរ ហ្មុកត្រី ខួរក្តាម ម្ហូរព្រៃ ត្រីកប់។ 2. ដើម្បីរក្សាឈ្មោះម្ហូបខ្មែរដល់ជំនាន់ក្រោយគេត្រូវចងក្រងមុខម្ហូបនិងរបៀបគ្រឿងផ្សំទុកជាឯកសារ។ 3. មេសូត្រនេះអប់រំឱ្យស្គាល់និងរក្សាមុខម្ហូបខ្មែរកុំឱ្យបាត់បង់។
កំណែលំហាត់	**លំហាត់ទី1៖** ក. លំនាំបទកាគតិ ខ. អំពីឈ្មោះម្ហូបខ្មែរ **លំហាត់ទី2៖** មុខ ចួន ទុក ប្រសើរ ចួន ដំណើរ

	ជ្រក់ ចួន អន្លក់ ខ្លួន ចួន ក្រមួន

មេរៀនទី៨	**ការនិយាយ៖ ការសម្តែងការចូលចិត្តនិងមិនចូលចិត្ត**
រយៈពេល	2ម៉
វត្តបំណង	សម្តែងការចូលចិត្តនិងមិនចូលចិត្តបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី227 ដល់ទំព័រទី228
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ25
ចម្លើយនៃសំណួរ	1. បុប្ផាបបួលសុខាទៅទិញចំណីញុំា។ 2. សុខាមិនព្រមទៅទេ ព្រោះគេមានបាយកញ្ចប់មកពីផ្ទះ។ 3. បានជាសុខាមិនចូលចិត្តញុំាចំណីអាហារនៅសាលា ព្រោះគេចូលចិត្តចំណីអាហារដែលម្តាយគេចម្អិន និងម្យ៉ាងទៀតអាហារមកពីផ្ទះមានសុវត្ថិភាពជាង។ 4. ម្តាយឪពុកបុប្ផាណែនាំបុប្ផាឱ្យញុំាតែចំណីអាហារដែលមានអនាម័យល្អ។
កំណែលំហាត់	**លំហាត់ទី1៖** ញុំា ស្ងោមាន់ ព្រោះវាមានរសជាតិឆ្ងាញ់។ **លំហាត់ទី2៖** ក. ប្រៃ ត្រី ខ. ហិរ ដូង សណ្តែកដី ដំឡូង ខ្ទឹមបារាំង ត្រប់ គ. ត្រីងៀត ព្រោះវាងាយស្រួលខ្ចប់ ឃ. ឆាខ្ញី ង. ទឹកត្រឹង ត្រកួន ផ្កាស្នោ ស្ពៃ ត្រប់ ត្រសក់ ជីរ **លំហាត់ទី3៖** សិស្សសន្ទនាដោយផ្ទាល់ក្នុងថ្នាក់។

ជំពូកទី១៨

សណ្ឋានដីប្រទេសយើង

រយៈពេល	13ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី១	អំណាន៖ មេសូត្រ៖ សម្រស់ទឹកដីប្រទេសកម្ពុជា
មេរៀនទី២	ស្តាប់៖ សម្រស់បរិស្ថាន
មេរៀនទី៣	វេយ្យាករណ៍៖ ល្បះនិងផ្នែកទាក់ទងនៃល្បះ
មេរៀនទី៤	អំណាន៖ ទេសភាពភ្នំបូកគោ
មេរៀនទី៥	អំណាន៖ រឿង កំណើតភ្នំ និងទន្លេ
មេរៀនទី៦	សំណេរ៖ ការពណ៌នាពីទីកន្លែង

មេរៀនទី១	**អំណាន៖ មេសូត្រ៖ សម្រស់ទឹកដីប្រទេសកម្ពុជា (បទកាកគតិ)**
រយៈពេល	2ម៉ោ
វត្ថុបំណង	ពណ៌នាពីសម្រស់ទឹកដីកម្ពុជាបានត្រឹមត្រូវ។
សំភារៈឧបទ្ទេស	ស.ស. ទំព័រទី230 ដល់ទំព័រទី231 រូបភាពទំព័រ230
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
ចម្លើយនៃសំណួរ	1. ប្រជាជននៅតំបន់វាលទំនាបដាំដំណាំ ធ្វើចម្ការ ស្រែ 2. ដំបន់ភ្នំសម្បូរព្រៃឈើ សត្វព្រៃ 3. ម្រឹគីម្រឹគាខ្លា ប្រើស ក្តាន់ ឈ្លូស រមាំង (សត្វឈ្មោល ញី) 4. ម្រឹគ្រីម្រឹគារស់នៅក្នុងព្រៃ 5. ដើម្បីឱ្យទឹកដីប្រទេសនៅគង់វង្សយើងត្រូវការពារនិងថែរក្សា។
កំណែលំហាត់	**លំហាត់ទី1៖** ក. សម្រស់ទឹកដីកម្ពុជា ខ. 4វគ្គ គ. សម្រស់ទឹកដីកម្ពុជានៅតាមតំបន់នានា **លំហាត់ទី2៖** កម្ពុជា ចួន សោភា កន្លែង ចួន ស្ងែង បវរ ចួន បន្ត ផ្កា ចួន ដូនតា អស្ចារ្យ ចួន បក្សា

មេរៀនទី២	**ការស្តាប់៖ សម្រស់បរិស្ថាន (បទពាក្យប្រាំពីរ)**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីសម្រស់បរិស្ថានបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី232 ដល់ទំព័រទី233 រូបភាពទំព័រ232
ជំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ24
ចម្លើយនៃសំណួរ	1. អត្ថបទកំណាព្យនេះរៀបរាប់ពៅសម្រស់បរិស្ថាន។ 2. វគ្គទី៦ដែលចាប់អារម្មណ៍ជាងគេ 3. បើបរិស្ថានធម្មជាតិយើងល្អស្រស់ត្រកាល យើងទទួលបានចំណូលពីភ្ញៀវទេសចរជាតិ និងអន្តរជាតិ។
កំណែលំហាត់	**លំហាត់ទី1៖** ក. សម្រស់បរិស្ថាន ខ. កុមារទាំងអស់ត្រូវរួមគ្នាថែរក្សា និងការពារបរិស្ថាន **លំហាត់ទី2៖** ក. អនេក ប្លែក ប្រណីត ខ. ព្រឹក្សា រុក្ខា

មេរៀនទី៣	**វេយ្យាករណ៍៖ ល្បះនិងផ្នែកទាក់ទងនៃល្បះ**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រាប់ពីល្បះនិងផ្នែកទាក់ទងនៃល្បះបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី234 ដល់ទំព័រទី236
ជំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	1. ល្បះគឺជាក្រុមពាក្យមានន័យគ្រប់គ្រាន់ស្តាប់បានហើយបញ្ចប់ដោយសញ្ញាខណ្ឌ សញ្ញាសួរ សញ្ញាឧទាន។ 2. ល្បះមាន២ផ្នែក គឺកន្សោមនាមប្រធាននិងកន្សោមកិរិយា។ 3. កន្សោមនាមប្រធានគឺអ្វីដែលគេលើកយកមកនិយាយ។ 4. កន្សោមកិរិយាគឺនិយាយពីសកម្មភាព ឬអំពើរបស់កន្សោមប្រធាន។
កំណែលំហាត់	**លំហាត់ទី1៖** ក ខ ឃ ង **លំហាត់ទី2៖** ក. ⇨ ឈរចាំរថយន្តក្រុង។ ខ. ⇨ កំពុងព្យាបាលជំងឺ។ គ. ⇨ ជាម្ចាស់ហាងនំប៉័ង។ ឃ. ⇨ ស្ថិតនៅតាមដងទន្លេមេគង្គ។ **លំហាត់ទី3៖** ក. <u>ជនជាតិភាគតិចច្រើនរស់នៅតំបន់ភ្នំ</u> ខ. <u>កូនច្បងរបស់យាយសំធ្វើការងារល្អជាងគេ។</u>

មេរៀនទី៤	**អំណាន៖ ទេសភាពភ្នំបូកគោ**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីទេសភាពភ្នំបូកគោបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី237 ដល់ទំព័រទី238 រូបភាពទំព័រ237
ជំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. ភ្នំបូកគោស្ថិតនៅក្នុងខេត្តកំពត។ 2. គេឃើញមានសំណង់ចាស់ៗបាក់បែក ផ្នាំងសិលាធំៗ និងមានពពករសាត់។ 3. ភ្ញៀវទេសចរមានអារម្មណ៍ស្រស់ថ្លា ទឹកចិត្តសប្បាយរីករាយ ភ្លេចអស់ទុក្ខកង្វល់ ភ្លេចការនឿយហត់។ 4. សម្រស់ភ្នំបូកគោអាចទាក់ទាញភ្ញៀវទេសចរជាតិនិងអន្តរជាតិទៅកម្សាន្ត។ 5. រមណីយដ្ឋានបូកគោមានចម្ងាយ១៨៩គីឡូម៉ែត្រពីភ្នំពេញ។
កំណែលំហាត់	**លំហាត់ទី1៖** ក. អស្ចារ្យ (គុ) ដែលគួរឱ្យស្ងើចសរសើរក្រៃលែង។ ខ. ធំល្វឹងល្វើយ (គុ) លួលល្វើក្រៃពេក , ធំធេង។ គ. បរិសុទ្ធ (គុ) ដែលស្អាតឥតសៅហ្មង។ **លំហាត់ទី2៖** ក. ការធ្វើដំណើរទៅភ្នំបូកគោ ខ. សម្រស់ភ្នំបូកគោ

មេរៀនទី៥	**អំណាន៖ រឿង កំណើតភ្នំនិងទន្លេ**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីប្រវត្តិកំណើតភ្នំនិងទន្លេបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី239ដល់ទំព័រទី240 រូបភាពទំព័រ239
ជំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. កូនសួរឪពុកពីភ្នំនិងទន្លេ។ 2. ទន្លេកើតឡើងដោយព្រះរាមអូសព្រះខ័នចុងវាឆ្លូតព្រះធរណី ប្រេះជាពីរ ក្លាយជាស្ទឹងទន្លេ។ 3. ភ្នំកើតឡើងដោយហនុមានយកដីនិងថ្មមកចងនឹងរោមជើងដីមួយដុំៗមានទំហំប៉ុនភ្នំមួយ ពេលហោះដញ្ជូនថ្មនិងដុំដីហនុមានជួបព្យុះភ្លៀងធ្វើឱ្យដាច់រោមជើងជ្រុះថ្មនិងដុំដីរប៉ាត់រប៉ាយក្លាយជាកូនភ្នំ តូចធំជាច្រើន។ 4. ពេលធ្វើដំណើរហនុមានលួងលោមនាងសុវណ្ណមច្ឆាឱ្យនាំពួកត្រីដញ្ជូនថ្មរៀបគ្រឹះថ្កល់នៅបាតសមុទ្រ ចំណែកខ្លួនឯងបានយកដីនិងថ្មមកចងនិងរោមជើង។
កំណែលំហាត់	**លំហាត់ទី1៖** ខ. កំណើតភ្នំ **លំហាត់ទី2៖** ខ. ក្រុងរាពណ៍ឆក់នាងសីតាព្រះរាមទៅតាមយកនាងសីតាមកវិញ **លំហាត់ទី3៖**

	ក. ព្រះរាមត្រូវធ្វើដំណើរទៅនគរលង្កា ព្រោះព្រះអង្គចង់ដណ្តើមយកនាងសីតាពីក្រុងរាពណ៍វិញ។ គ. ពេលហោះហនុមានជួបនឹងព្យុះភ្លៀង ទើបធ្វើឱ្យដាច់រោមដើងជ្រុះឬ ដុំដី។

មេរៀនទី៦	**សំណេរ៖ ការពណ៌នាពីទីកន្លែង**
រយៈពេល	3ម៉
វត្ថុបំណង	ពណ៌នាពីរមណីយដ្ឋានណាមួយបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី241 ដល់ទំព័រទី242 រូបភាពទំព័រ242
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖** (ចម្លើយជាក់ស្តែង) វត្តស្អាងភ្នំស្ថិតនៅក្នុងស្រុកស្អាង ខេត្តកណ្តាល។ វត្តនេះតាំងនៅជើងភ្នំ។ បើយើងមើលពីចម្ងាយ យើងនឹងឃើញកំពូលព្រះវិហារខ្ពស់ត្រដែតផុតចុងព្រឹក្សានានា។ នៅរដូវវស្សា ព្រះវិហារហាក់ដូចជាអណ្តែតឡើងនៅលើផ្ទៃទឹកដ៏ធំល្វឹងល្វើយ។ ទេសភាពនៅជុំវិញនោះមិនខុសប្លែកពីសមុទ្រដ៏ធំធេងនោះឡើយ។ រុក្ខជាតិទាំងឡាយត្រូវផ្ទៃទឹកគ្របសង្កត់យ៉ាងដំណាំ។ ទោះជាយ៉ាងនេះក្តីក៏នៅរាល់ពេលបុណ្យទាន ពិសេសពេលបុណ្យភ្ជុំបិណ្ឌ វត្តស្អាងភ្នំមានសភាពអ៊ូអរ និងមានបរិយាកាសរីករាយប្លែកពីធម្មតា។ នៅរដូវទឹកស្រក ទេសភាពជុំវិញបានក្លាយទៅជាវាលស្រែពណ៌ខៀវស្រងាត់ លាតសន្ធឹងធំវែងមើលឃើញឆ្ងាយសន្លឹមជាប់នឹងជើងមេឃ។ វត្តស្អាងភ្នំជារមណីយដ្ឋានដ៏សែនមនោរម្យ។ ធាតុអាកាសត្រជាក់ល្អបរិសុទ្ធប្រៀបបាននឹងឱសថទិព្វបំបាត់កង្វល់ និងការនឿយហត់ ចេញពីជនទាំងឡាយដែលបានចូលទៅដល់ទីនោះ។ ដោយមានទេសភាពល្អប្លែកតាមរដូវកាលនីមួយៗ និងជារមណីយដ្ឋានដ៏មនោរម្យផងនោះ វត្តស្អាងភ្នំធ្វើឱ្យយើងមានអារម្មណ៍ជិតជាប់ជានិច្ច។ **លំហាត់ទី2៖** (ចម្លើយជាក់ស្តែង) វត្តភ្នំស្ថិតនៅក្នុងរាជធានីភ្នំពេញ។ វត្តភ្នំគឺជាកូនភ្នំតូចមួយនៅក្នុងរាជធានីភ្នំពេញ បើយើងមើលពីចម្ងាយទៅឃើញកំពូលព្រះវិហារខ្ពស់ផុតចុងឈើ។ ទាំងរដូវប្រាំងនិងរដូវវស្សាវត្តភ្នំមានអ្នកទេសចរទៅទស្សនាឥតដាច់ ព្រោះនៅទីមានទេសភាពស្រស់បំព្រងនិងមានម្លប់ដ៏ត្រជាក់គួរឱ្យចង់កម្សាន្តនិងគយគន់ ជាពិសេសជាងនេះនៅទៀតនៅទីនោះមាននាឡិកាមួយដ៏ធំសម្រាប់មើលម៉ោង។ ទេសចរដែលបានមកកម្សាន្តនៅទីនេះ តែងមានអារម្មណ៍រីករាយជិតជាប់នូវទេសភាពដ៏ស្រស់ត្រកាលនេះហើយនឹងចង់មកទស្សនាម្តងទៀត។

ជំពូកទី១៩

ប្រភពទឹកនៅកម្ពុជា

រយៈពេល	13ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី១	អំណាន៖ ការសន្សំសំចៃទឹក
មេរៀនទី២	ស្តាប់៖ ការពារប្រភពទឹក
មេរៀនទី៣	វេយ្យាករណ៍៖ សញ្ញាបដិសេធ ឬទណ្ឌឃាត(ែ)
មេរៀនទី៤	អំណាន៖ មេសូត្រ៖ ទំនួញព្រះគង្គា
មេរៀនទី៥	និយាយ៖ ការសម្តែងមតិអំពីទឹកស្អាត
មេរៀនទី៦	សំណេរ៖ ការពណ៌នាអំពីប្រយោជន៍នៃទឹក

មេរៀនទី១	**អំណាន៖ ការសន្សំសំចៃទឹក**
រយៈពេល	2ម៉ោ
វត្ថុបំណង	សន្សំសំចៃទឹកបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី244 ដល់ទំព័រទី245
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. មនុស្ស សត្វ រុក្ខជាតិត្រូវការទឹកចាំបាច់ដាងគេ។ 2. បរិមាណទឹកសាបមិនអាចឱ្យមនុស្សប្រើប្រាស់គ្រប់គ្រាន់ទេ ព្រោះមនុស្សកាន់តែច្រើន 3. ប្រទេសជាច្រើននៅលើពិភពលោកនឹងខ្សត់ទឹកប្រើប្រាស់នៅឆ្នាំ2015។ 4. យើងត្រូវសន្សំសំចៃទឹកដោយ បើកបង្ហូរតិចៗ បោកខោអាវត្រូវប្រើទឹកតាមបរិមាណខោអាវ មិនត្រូវបង្ហូរទឹកសម្រាប់ដុសធ្មេញ ឬលាងវត្ថុផ្សេងៗចោល ហើយត្រូវបិទក្បាលម៉ាស៊ីនទឹកឱ្យបានជិតល្អនៅពេលប្រើរួច។
កំណែលំហាត់	**លំហាត់ទី1៖** ក. ចំនួន ខ. ការយល់ឃើញ **លំហាត់ទី2៖** ខ. ការសន្សំសំចៃទឹក

មេរៀនទី២	**ការស្តាប់៖ ការពារប្រភពទឹក**
រយៈពេល	2ម៉ោ
វត្ថុបំណង	ការពារប្រភពទឹកបានត្រឹមត្រូវ។

សម្ភារឧបទេស	ស.ស. ទំព័រទី246ដល់ទំព័រទី247
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ24
ចម្លើយនៃសំណួរ	1. ទឹកមានសារប្រយោជន៍ដូចជា ហូប លាងសម្អាត ស្រោចដំណាំ ងូត 2. ទឹកអាចផ្តល់គ្រោះភ័យដូចជា ខូចសុខភាពស្បែក និងខូចសុខភាពរាងកាយ។ 3. ទឹកមានគ្រោះថ្នាក់ជាទឹកមានមេរោគដែលបណ្តាលឲ្យខូចសុខភាព។ 4. ទឹកមិនស្អាតប៉ះពាល់ដូចជាមានជំងឺរាកមូល ដង្កូវពោះវៀន អាសន្នរោគ...។
កំណែលំហាត់	**លំហាត់ទី1៖** ក. ទឹកមានសារៈសំខាន់ដល់មនុស្ស រុក្ខជាតិនិងសត្វ ខ. មនុស្សនិងធម្មជាតិ គ. ទឹកជំនន់ ឃ. ចាក់សំរាម ឬបោះខ្មោចសត្វចូលក្នុងទន្លេ ឬស្ទឹង។ - បញ្ចេញកាកសំណល់ពីទីក្រុង ឬរោងចក្រហើយបង្ហូរចូលស្ទឹងទន្លេ - ចុះមុជ បោកខោអាវ ឬលាងសត្វពាហនៈ។ - សង់បង្គន់ចូលក្នុងស្ទឹង ឬទន្លេ។ - បន្ទោរបង់នៅមាត់ស្រះ ឬត្រពាំង។ **លំហាត់ទី2៖** ផ្សព្វផ្សាយពីរបៀបថែរក្សាប្រភពទឹកនិងផលប៉ះពាល់ការបំពុលប្រភពទឹក

មេរៀនទី៣	**វេយ្យាករណ៍៖ សញ្ញាបដិសេធ ឬទណ្ឌឃាត(ៈ)**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រើប្រាស់សញ្ញាបដិសេធ ឬទណ្ឌឃាតបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី248
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
កំណែលំហាត់	**លំហាត់ទី1៖** ទ័ ម័ ន័ តិ៍ ទ័ ន៍ ព្រោះសញ្ញា ៍ ប្រើសម្រាប់លុបសូរព្យញ្ជនៈ ឬស្រៈមិនឱ្យអានតាមសំណេរ។ **លំហាត់ទី2៖** ឧស្សាហ៍ របាយការណ៍ ឧបករណ៍ អភិវឌ្ឍន៍ វេយ្យាករណ៍ អារម្មណ៍ **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង) នាឡិកាអោទ៍ អាពាហ៍ពិពាហ៍ វេយ្យាករណ៍ កេរ្តិ៍ ទូរទស្សន៍

មេរៀនទី៤	**អំណាន៖ មេសូត្រ៖ ទំនួញព្រះគង្គា (លំនាំបទកាកគតិ)**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីផលប៉ះពាល់ប្រភពទឹកបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី249ដល់ទំព័រទី250 រូបភាពទំព័រ249
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
ចម្លើយនៃសំណួរ	1. ការកាប់ព្រៃឈើនាំឱ្យមានផលអាក្រក់ដូចជាជួបគ្រោះរាំងស្ងួត គ្រោះទឹកជំនន់

	បាត់បង់សត្វព្រៃ។ 2. មនុស្សយើងបានធ្វើឱ្យមានផលប៉ះពាល់ដល់ប្រភពទឹកដូចជា សង់ផ្ទះ បង្គន់ ផៃចិញ្ចឹមត្រីក្នុងប្រភពទឹក ចោលកាកសំណល់ ឬបង្ហូរទឹកកខ្វក់ចូលក្នុងប្រភពទឹក។ 3. ទឹកអង្វរយើងឱ្យប្រើទឹកឲ្យបានល្អ ត្រូវសន្សំសំចៃ កែច្នៃក្នុងការប្រើប្រាស់ ព្រោះទឹកពិតជាមានគុណ ទឹកជាជីវិត។ 4. ដើម្បីថែរក្សានិងការពារប្រភពទឹកយើងមិនត្រូវសង់ផ្ទះ បង្គន់ ឬផៃចិញ្ចឹមត្រីក្នុងប្រភពទឹកមិនចោលកាកសំណល់ឬបង្ហូរទឹកកខ្វក់ចូលប្រភពទឹកទេ។
កំណែលំហាត់	**លំហាត់ទី1៖** ក. បទកាកគតិ ខ. ផលអាក្រក់នៃការកាប់ព្រៃឈើ **លំហាត់ទី2៖** ក. អង្វរ ចួន ល្អ ខ. ក្រៃ ចួន ច្នៃ **លំហាត់ទី3៖**(១)នាំដល់ (២)មនុស្ស សត្វ (៣)កខ្វក់ពន្លឺក (៤)អនាម័យ

មេរៀនទី៥	**និយាយ៖ ការសម្តែងមតិអំពីទឹកស្អាត**
រយៈពេល	2ម
វត្ថុបំណង	សម្តែងមតិអំពីទឹកស្អាតបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី251 ដល់ទំព័រទី252
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ25
ចម្លើយនៃសំណួរ	1. អំពីទឹកស្អាត។ 2. រ៉ានីសម្តែងមតិ : ខ្ញុំយល់ថា ទឹកដែលយើងផឹកទៅពុំមានគ្រោះថ្នាក់ដល់សុខភាពនោះ ហើយជាទឹកស្អាត ឬទឹកមានអនាម័យ។ ម្យ៉ាងទៀតទឹកស្អាតមិនសម្គាល់លើទឹកគ្មានពណ៌ថ្លាគ្មានភាពល្អក់ឡើយ។ 3. ពិជោសម្តែងមតិ : ខ្ញុំយល់ថាទឹកស្អាតប្រកបដោយសុវត្ថិភាព ជាប្រភពទឹកដែលគ្មានក្លិនគ្មានមេរោគបង្កជំងឺនិងគ្មានជាតិគីមី។
កំណែលំហាត់	**លំហាត់ទី1៖** ខ្ញុំយល់ថា ចំណែកខ្ញុំវិញ ម្យ៉ាងទៀត **លំហាត់ទី2៖** សុខា : ខ្ញុំយល់ថា សុខា : ខ្ញុំគិតថា រតនា : គំនិតខ្ញុំ ឬខ្ញុំយល់ **លំហាត់ទី3៖** សិស្សសម្តែងតួតាមការជាក់ស្តែង

មេរៀនទី៦	**សំណេរ៖ ការពណ៌នាអំពីប្រយោជន៍នៃទឹក**
រយៈពេល	3ម៉
វត្ថុបំណង	ពណ៌នាផលប្រយោជន៍នៃទឹកបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី253 ដល់ទំព័រទី254
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់ទី1៖**(១)ប្រភពទឹក (២)ផ្តល់ទឹក (៣)ស្រោចបន្លែ (៤)ងាយស្រួល (៥)អាហារ (៦)ធ្វើដំណើរ (៧)ថែរក្សា

លំហាត់ទី2៖ (ចម្លើយជាក់ស្តែង)

នៅក្នុងភូមិរបស់ខ្ញុំមានព្រែកមួយឈ្មោះ ព្រែកឆ្លូង។ ព្រែកនេះផ្តល់ទឹកសម្រាប់មនុស្សប្រើប្រាស់បានទាំងខួបប្រាំងខួបវស្សា។ ក្រៅពីការប្រើប្រាស់និងបរិភោគគេយកទឹកព្រែកនោះទៅស្រោចដំណាំ ឬបូបដាក់ស្រែ។ ព្រែកឆ្លូងសម្បូរត្រីណាស់ប្រជាជនភាគច្រើនចូលចិត្តរស់នៅតាមមាត់ព្រែកនេះណាស់ ព្រោះងាយស្រួលក្នុងការរស់នៅនិងសម្បូរសាច់សម្រាប់ធ្វើជាអាហារ។ នៅរដូវវស្សាទឹកឡើងព្រៀបមាត់ព្រែកហើយមានទេសភាពខៀវស្រងាត់ប្រជាជនធ្វើដំណើរតាមទូក ឬកាណូតពីភូមិមួយទៅភូមិមួយ។ ដោយសារព្រែកឆ្លូងមានទេសភាពប្លែក និងផ្តល់ប្រយោជន៍ច្រើនដល់ប្រជាជនទើបអ្នកស្រុកនាំគ្នាចូលរួមថែរក្សាបានស្អាតជានិច្ច។

ជំពូកទី២០

សត្វនៅប្រទេសយើង

រយៈពេល	17ម៉ោង
ចំណងជើងសមត្ថភាព	
មេរៀនទី១	បំណិន៖ កំណាព្យបទកាកគតិ
មេរៀនទី២	អំណាន៖ មេសូត្រ៖ ប្រយោជន៍នៃសត្វស្រុក
មេរៀនទី៣	សំណេរ៖ ការរៀបឃ្លាកំណាព្យ
មេរៀនទី៤	បំណិន៖ គំនិតសំខាន់
មេរៀនទី៥	អំណាន៖ រឿង កង្កែងនិងមាន់ចៃ
មេរៀនទី៦	ស្តាប់៖ ត្រូវការពារសត្វព្រៃ
មេរៀនទី៧	វេយ្យាករណ៍៖ សញ្ញាលេខទោ “ ៗ ”
មេរៀនទី៨	អំណាន៖ ជីវិតសត្វព្រៃ

មេរៀនទី១	**បំណិន៖ កំណាព្យបទកាកគតិ**
រយៈពេល	2ម៉ោ
វត្ថុបំណង	កំណត់លក្ខណៈកំណាព្យ “ បទកាកគតិ”បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី256 ដល់ទី258
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	1. កំណាព្យជាអត្ថបទដែលសរសេរជាពាក្យកាព្យដោយរៀបចំជាវគ្គតាមក្បួនខ្នាតត្រឹមត្រូវប្រកបដោយចំណាប់ជួននិងចង្វាក់ដែលអាចនាំអារម្មណ៍អ្នកអាន ស្តាប់ ឱ្យរំភើប ឬអន្លង់អន្លោចតាមបទនីមួយៗ។ 2. ចួនក្នុងវគ្គជាពាក្យចួនពីឃ្លាមួយទៅឃ្លាមួយ ក្នុងវគ្គតែមួយ ទៅតាមក្បួនខ្នាត។ 3. ចួនឆ្លងវគ្គជាពាក្យចួនចុងវគ្គឆ្លងពីវគ្គមួយទៅវគ្គមួយទៀត។ 4. ទីន្លែង តួអង្គ ធម្មជាតិ និងការសម្តែងទុក្ខសោក
កំណែលំហាត់	**លំហាត់ទី1៖** ក. 7ឃ្លា ខ. 4ព្យាង្គ **លំហាត់ទី2៖** (១)គប់ (២)ឱ៉ា (៣)មេបា (៤)រស់ (៥)ល្បីឈ្មោះ (៦)ថ្កើងថ្កាន (៧)គ្រប់ប្រាណ

មេរៀនទី២	**អំណាន៖ មេសូត្រ៖ ប្រយោជន៍នៃសត្វស្រុក (លំនាំបទកាកគតិ)**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីប្រយោជន៍សត្វស្រុកបានត្រឹមត្រូវ។

សម្ភារឧបទេស	ស.ស. ទំព័រទី259 ដល់ទី260 រូបភាពទំព័រ259
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ23
ចម្លើយនៃសំណួរ	1. សត្វឆ្កែ ឆ្មាជួយចាំផ្ទះ ឆ្មាចាប់កណ្តុរ។ 2. គោក្របីជួយភ្ជួររាស់និងដឹកជញ្ជូន។ 3. ក្ងានជ្រូកមាន់ទាផ្តល់សាច់និងស៊ុតជាអាហារ។ 4. ការចិញ្ចឹមសត្វស្រុកជួយសម្រាលការងារពលកម្មនិងថវិកា។
កំណែលំហាត់	**លំហាត់ទី1៖** ក. ស្រែ ជួន កែ ដែរ ខ. គ្រួសារ ជួន អាហារ ថវិកា **លំហាត់ទី2៖** ក. ឆ្កែនិងឆ្មា ខ. គេចិញ្ចឹមមាន់ទា ជ្រូក ក្ងាន ដើម្បីយកសាច់ស៊ុតជាអាហារ។ គ. គេជាស់តឿនកូនឱ្យខំចិញ្ចឹមនិងជួយថែរក្សាសត្វ។

មេរៀនទី៣	**សំណេរ៖ ការរៀបឃ្លាកំណាព្យ**
រយៈពេល	3ម៉ោ
វត្ថុបំណង	រៀបឃ្លាកំណាព្យ “បទកាកគតិ” បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី261
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ26
កំណែលំហាត់	**លំហាត់៖** បក្សីចង់មានសេរីភាព បក្សីបក្សា **រស់នៅត្រូវការ** **សិទ្ធិសេរីភាព** **មិនចង់ជាប់ទ្រុង** **រស់ក្រោមគំនាប** **ក្នុងវង់ដ៏ទាប** ម្ចាស់គៀបទៀតណា។ យើងចង់ហោះហើរ **ចង់ធ្វើដំណើរ** **ទៅគ្រប់ទិសា** **តាមចិត្តយើងចង់** **ចំណង់ប្រាថ្នា** **រីករាយកាយា** មិនដូចជាប់ទ្រុង។

មេរៀនទី៤	**បំណិន៖ គំនិតសំខាន់**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រាប់ពីគំនិតសំខាន់ក្នុងអត្ថបទបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី262ដល់ទំព័រទី264
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
ចម្លើយនៃសំណួរ	1. គំនិតសំខាន់របស់អត្ថបទគឺខ្លឹមសារគាំទ្រអត្ថបទទាំងមូល។ 2. អានអត្ថបទទាំងមូលដោយវិភាគគំនិតនៅក្នុងឃ្លាឈ្នះនីមួយៗ រួចសំយោគគំនិតតូចៗ ឬសេចក្តីលម្អិតសំខាន់ៗនៅក្នុងអត្ថបទនោះ។

កំណែលំហាត់	**លំហាត់ទី1៖** ខ. ប្រទេសកំណើតខ្លួន **លំហាត់ទី2៖** មនុស្ស សត្វ ត្រូវការរុក្ខជាតិជាចាំបាច់ **លំហាត់ទី3៖** ផលវិបាកនៃការបាត់បង់ព្រៃឈើនៅតំបន់ភ្នំ។

មេរៀនទី៥	**អំណាន៖ រឿង កញ្ជ្រោងនិងមាន់ចែ**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីភាពឆ្លាតវៃរបស់មាន់ចែបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី265ដល់ទំព័រទី266
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. រឿងនេះមានតួអង្គ កញ្ជ្រោង មាន់ចែ 2. នែមាន់ចែសម្លាញ់អើយ! ព្រះឥន្ទ្រទ្រង់ត្រាស់ប្រើខ្ញុំឱ្យកាន់អាជ្ញាមកប្រកាសប្រាប់បណ្តាមិត្តដែលធ្លាប់ចងពៀរសត្រូវនឹងគ្នា ឱ្យរាប់អានគ្នាពីថ្ងៃនេះទៅ។ 3. បានជាកញ្ជ្រោងប្រើឧបាយកលនេះ ព្រោះកញ្ជ្រោងចង់ស៊ីមាន់ចែ។ 4. បានជាកញ្ជ្រោងរត់ចូលព្រៃព្រោះខ្លាចឆ្កែខាំស៊ី។
កំណែលំហាត់	**លំហាត់ទី1៖** ក. អាជ្ញា (ន) អំណាច។ ខ. សុនខ (ន) ឆ្កែ **លំហាត់ទី2៖** ក. មានប្រាជ្ញាវាងវៃជាមួយសត្រូវ ខ. ត្រូវប្រើប្រាស់ប្រាជ្ញាទប់ទល់ចំពោះឧបាយកលសត្រូវដែលខ្លាំងជាងខ្លួន។

មេរៀនទី៦	**ការស្តាប់៖ ត្រូវការពារសត្វព្រៃ**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រាប់បានពីវិធីការពារសត្វព្រៃបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី268ដល់ទំព័រទី269 រូបភាពទំព័រ272
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ24
ចម្លើយនៃសំណួរ	1. អត្ថបទនេះនិយាយពីការការពារសត្វព្រៃ។ 2. សត្វព្រៃក្នុងអត្ថបទនេះរស់នៅភូមិភាគល្បាសានតំបន់ខ្ពង់រាបជួរភ្នំក្រវាញនិងវាលទំនាប។ 3. នៅរដូវប្រាំងសត្វទាំងនេះរស់នៅតាមចង្កេះភ្នំ ជើងភ្នំនិងរហូតដល់ទំនាបកណ្តាលតាមមាត់បឹងស្ទឹងទៀតផង។ 4. សត្វព្រៃមានប្រយោជន៍ដល់ប្រទេសជាតិដូចជាទាក់ទាញភ្ញៀវទេសចរមកកម្សាន្តប្រទេសយើង។
កំណែលំហាត់	**លំហាត់ទី1៖** គ. យើងត្រូវការពារសត្វព្រៃ

	លំហាត់ទី2៖ ខ. យើងទាំងអស់គ្នា **លំហាត់ទី3៖** ខ. ការពារនិងថែរក្សាសត្វព្រៃ គ. ផ្សព្វផ្សាយពីផលប្រយោជន៍សត្វព្រៃ ឃ. ពន្យល់ដល់ប្រជាជនឱ្យស្គាល់ពីប្រយោជន៍សត្វព្រៃ ង. ដាំដើមឈើបន្ថែម ច. ការពារកុំឱ្យភ្លើងឆេះព្រៃ ឆ. រាយការណ៍ដល់អាជ្ញាធរដែនដីចំពោះជនប្រមាញ់

មេរៀនទី៧	**វេយ្យាករណ៍៖ សញ្ញាលេខទោ ״ ״**
រយៈពេល	2ម៉ោ
វត្ថុបំណង	ប្រើប្រាស់សញ្ញាលេខ(״)បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី270 ដល់ទំព័រទី271
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ21
កំណែលំហាត់	**លំហាត់ទី1៖** ផ្សេងៗ នីមួយៗ តូចៗ ស្អាតៗ ធំៗ **លំហាត់ទី2៖** ក. រឿយៗ ខ. ប្លែកៗ គ. ថ្នមៗ ឃ. គ្រប់ៗ ង. ដដែលៗ **លំហាត់ទី3៖** (ចម្លើយជាក់ស្តែង) នារីមានសម្លៀកបំពាក់ស្អាតៗជាច្រើន។ បូណាចូលចិត្តមើលទេសភាពប្លែកៗ។ ណារាជដើរថ្នមៗព្រោះខ្លាចឪពុកគេភ្ញាក់ពីដំណេក។ ជារឿយៗសិស្សទាំងអស់តែងតែឆ្លៀតពេលជួយសម្អាតបរិស្ថានសាលា។

មេរៀនទី៨	**អំណាន៖ ជីវិតសត្វព្រៃ**
រយៈពេល	2ម៉ោ
វត្ថុបំណង	រៀបរាប់ពីជីវិតសត្វព្រៃបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី272ដល់ទំព័រទី273 រូបភាពទំព័រ276
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រ22
ចម្លើយនៃសំណួរ	1. កត្តាដែលបណ្តាលឱ្យសត្វទាំងនោះបាត់បង់គឺ សង្គ្រាម ការកាប់ទន្ទ្រានព្រៃ 2. សត្វដែលស្ទើរតែផុតពូជនាពេលបច្ចុប្បន្នមាន រមាស គោព្រៃ ខ្លាដំបង ក្ងោក 3. ដើម្បីទប់ស្កាត់ការបាត់បង់សត្វព្រៃត្រូវហាមបរបាញ់សត្វនិងកាប់ព្រៃឈើ
កំណែលំហាត់	**លំហាត់៖** គ. ការពារសត្វព្រៃឱ្យបានគង់វង្ស

ក្រសួងអប់រំ យុវជន និងកីឡា

និង

អង្គការដើម្បីភាពញញឹមនៃកុមារ





សូមថ្លែងអំណរគុណ

ចំពោះអ្នកខ្ចប់ត្តម្ភថវិកាដល់ដំណើរការគម្រោងចងក្រង និងបោះពុម្ពស្បៀវភៅពន្លឿនការសិក្សាដូចជា ៖













រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

មាត្រា៦៥៖ *រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាដំហានៗ ដើម្បីឱ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប។ រដ្ឋយកចិត្តទុកដាក់លើវិស័យអប់រំកាយនិងកីឡាដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប។*

មាត្រា៦៦៖ *រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេសដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានកព្វសំណាងគ្រប់គ្រាន់ស្មើគ្នាក្នុងការកសាងជីវិត។*

មាត្រា៦៧៖ *រដ្ឋអនុវត្តកម្មវិធីសិក្សានិងគោលការណ៍គរុកោសល្យទំនើបរាប់បញ្ចូលទាំងបច្ចេកវិទ្យានិងភាសាបរទេស។ រដ្ឋគ្រប់គ្រងគ្រឹះស្ថានសិក្សានិងថ្នាក់សិក្សាសាធារណៈនិងឯកជននៅគ្រប់ភូមិសិក្សា។*

មាត្រា៦៨៖ រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈសម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតមានបង់ថ្លៃយ៉ាងតិច ៩ឆ្នាំ។

ច្បាប់ស្តីពីការអប់រំនៃព្រះរាជាណាចក្រកម្ពុជា

មាត្រា៣១៖ *ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលបានការអប់រំយ៉ាងតិច៩(ប្រាំបួន)ឆ្នាំប្រកបដោយគុណភាពដោយឥតបង់ថ្លៃនៅសាលារៀនសាធារណៈ។ ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវរៀបចំគោលនយោបាយផែនការយុទ្ធសាស្ត្រ និងវិធានការជាដំហានៗ ដើម្បីធានាឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព ស្របតាមបទបញ្ញត្តិដែលមានចែងក្នុងច្បាប់នេះ។*

ការអប់រំសម្រាប់ទាំងអស់គ្នា!

ទាំងអស់គ្នាសម្រាប់ការអប់រំ!